# មាតិកា

ជំពូកទី ១៖ សេចក្តីផ្តើម
១.១. "ការលើកកម្ពស់កិច្ចគាំពារសង្គម និងបង្កើនការងារ"
១.២. កម្ពុជា៖ ការរំលឹកដោយសង្ខេបពីប្រវត្តិសាស្ត្រ និងសង្គម-នយោបាយ
១.៣. ការអភិវឌ្ឍសេដ្ឋកិច្ច
១.៤. កំណែទម្រង់ស្ថាប័ន៖ វិមជ្ឈការ និងអភិបាលកិច្ចកាន់តែប្រសើរឡើង
ជំពូកទី ២៖ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ក្នុងទស្សនៈជាសកល
២.១. សេចក្តីផ្តើម
២.២. កំណើនសេដ្ឋកិច្ច និងគោលដៅសង្គម
២.៣. ការអភិវឌ្ឍពាណិជ្ជកម្ម បច្ចេកវិទ្យា និងទីផ្សារការងារ
២.៤. ម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌគោលនយោបាយឧស្សាហកម្ម
២.៥. កិច្ចគាំពារសង្គម
២.៦. ទម្រង់កិច្ចគាំពារសង្គម
២.៧. មាតិកាអំពីយុទ្ធសាស្ត្ររួមបញ្ចូលមុខរបរ និងកិច្ចគាំពារសង្គម
ជំពូកទី ៣៖ គំនិតផ្តួចផ្តើមកំពុងដំណើរការរបស់រាជរដ្ឋាភិបាលកម្ពុជា
៣.១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ និងយុទ្ធសាស្ត្រចតុកោណ
៣.២. យុទ្ធសាស្ត្រជាតិកិច្ចគាំពារសង្គម
ជំពូកទី ៤៖ ទំនាក់ទំនងដែលមិនផ្សារភ្ជាប់៖ យុទ្ធសាស្ត្រជាតិស្តីពីមុខរបរ
៤.១. សេចក្តីផ្តើម
៤.២. ស្ថានភាពទីផ្សារការងារបច្ចុប្បន្ន
៤.៣. ការដាក់យុទ្ធសាស្ត្រជាតិស្តីពីមុខរបរនៅក្នុងក្របខណ្ឌអភិវឌ្ឍន៍ទូលំទូលាយ
៤.៤. ការបង្កើតយុទ្ធសាស្ត្រជាតិស្តីពីមុខរបរ និងការងារ
ជំពូកទី ៥៖ កម្មវិធីទម្រង់កិច្ចគាំពារសង្គម ALMPs (គោលនយោបាយទីផ្សារការងារសកម្ម និងអកម្ម) និងការធានារ៉ាប់រងសង្គម
៥.១. សេចក្តីផ្តើម
៥.២. "វិសាលភាពអ័ក្សដេក"៖ ទម្រង់កិច្ចគាំពារសង្គម
៥.៣. កម្មវិធីសំណាញ់សុវត្ថិភាពសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ
៥.៤. ALMPs និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
៥.៥. សុខភាពសង្គម
៥.៦. ការពង្រីកបន្ថែមលើគម្រោងធានារ៉ាប់រងសង្គម
ជំពូកទី ៦៖ ក្របខណ្ឌអភិបាលកិច្ចមុខរបរ និងកិច្ចគាំពារសង្គម
៦.១. សេចក្តីផ្តើម
៦.២. ការសម្របសម្រួលនៅថ្នាក់ក្រសួង
៦.៣. ការបង្កើតស្ថាប័នសន្តិសុខសង្គម (SSO)
៦.៤. ការផ្តល់សេវាកម្ម

ជំពូកទី ៧៖ ការអនុវត្តយុទ្ធសាស្ត្រជាតិកិច្ចគាំពារសង្គម និងយុទ្ធសាស្ត្រជាតិស្តីពីមុខរបរ និងការងារ

## ជំពូកទី ១៖ សេចក្តីផ្តើម

### ១.១. "ការលើកកម្ពស់កិច្ចគាំពារសង្គម និងបង្កើនការងារ"

គម្រោង៖ "ការបង្កើនកិច្ចគាំពារសង្គម និងមុខរបរ"

កម្ពុជាជាប្រទេសមួយដែលអនុវត្តគម្រោងនេះក្នុងចំណោមប្រទេសដែលជ្រើសរើសចំនួនបី

អង្គការពលកម្មពិភពលោក (ILO) និងគណៈកម្មាការសហភាពអឺរ៉ុប (EC) បានផ្តួចផ្តើមគម្រោងមួយដែលមានឈ្មោះថា៖ "ការបង្កើនកិច្ចគាំពារសង្គម និងលើកកម្ពស់មុខរបរ"។ គម្រោងមានគោលដៅសំដៅដល់ការអភិវឌ្ឍក្របខណ្ឌគោលនយោបាយកិច្ចគាំពារសង្គម និងមុខរបរដែលមានលក្ខណៈចម្រុះគ្នា។ ប្រទេសក្រោមការសាកល្បងចំនួនបី ត្រូវបានជ្រើសរើសឡើង ហើយលទ្ធផលនៃការជ្រើសរើសនេះគឺពឹងផ្អែកលើទិន្នន័យសម្លេង និងឧបករណ៍វិភាគ និងត្រូវរួមបញ្ចូលការចូលរួមយ៉ាងសកម្មពីសំណាក់ដៃគូសង្គម។ ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសទាំងបី ដែលត្រូវបានជ្រើសរើសដើម្បីអនុវត្តគម្រោងនេះ។ ចំពោះប្រទេសដែលបានជ្រើសរើស គម្រោងមានគោលដៅបន្ថែមសំដៅគាំទ្រការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សស្តីពីការកាត់បន្ថយភាពក្រីក្រស្របជាមួយនឹងការព្រមព្រៀងអឺរ៉ុបស្តីពីការអភិវឌ្ឍ និងការព្រមព្រៀងរបស់សហភាពអឺរ៉ុបស្តីពីការងារសមរម្យសម្រាប់ជនគ្រប់រូប ក៏ដូចជាសេចក្តីប្រកាសរបស់ ILO ឆ្នាំ ២០០៨ ស្តីពីយុត្តិធម៌សង្គមសម្រាប់សកលភាវូបនីយកម្មស្មើភាព។ គម្រោងប្រមើមើលលើគោលបំណងផែនការថ្នាក់ជាតិ ដើម្បីពង្រីកវិសាលភាពកិច្ចគាំពារសង្គម និងដើម្បីលើកកម្ពស់មុខរបរ ក្នុងបរិបទការឆ្លើយតបយុទ្ធសាស្ត្រការងារសមរម្យទៅនឹងវិបត្តិសេដ្ឋកិច្ច។ លើសពីនេះ លទ្ធផលនៃបទពិសោធន៍ថ្នាក់ជាតិ នឹងបម្រើដល់ការលើកកម្ពស់យុទ្ធនាការអន្តរជាតិក្នុងការបង្កើនការយល់ដឹង និងផ្លាស់ប្តូរការអនុវត្តល្អស្តីពីការពង្រីកវិសាលភាពកិច្ចគាំពារសង្គម និងការលើកកម្ពស់មុខរបរ។

គម្រោងនេះអាចចាត់ទុកថាស្ថិតនៅក្នុងកម្មវិធីការងារសមរម្យសម្រាប់ប្រទេស (DWCP) កម្រិតដំបូង ដែលសំដៅលើគោលដៅចំនួន ២ គឺពង្រឹងមុខរបរសមរម្យ និងពង្រីកវិសាលភាពកិច្ចគាំពារសង្គម

របាយការណ៍នេះតាមដាននូវកម្មវិធី ការងារសមរម្យសម្រាប់ប្រទេសនៅក្នុងប្រទេសកម្ពុជា ដែលរបាយការណ៍នេះត្រូវបានរៀបចំឡើងដោយសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនិយោជិត និងនិយោជក។ របាយការណ៍នេះផ្តោតទៅលើការកាត់បន្ថយភាពក្រីក្រតាមរយៈការលើកកម្ពស់ការងារ និងជីវភាពរស់នៅសំដៅទៅលើអភិបាលកិច្ចល្អ ដោយពង្រឹងស្ថាប័នពលកម្ម និងការការពារសិទ្ធិមូលដ្ឋាននៅកន្លែងធ្វើការ និងពង្រីកកិច្ចគាំពារសង្គមជាមូលដ្ឋានទៅដល់កម្មករដែលងាយរងគ្រោះបំផុតនៅកម្ពុជា។ វាត្រូវបានជ្រើសរើសជាគោលដៅ និងលទ្ធផលចំបងសម្រាប់ (i) បង្កើនឱកាសការងារ និងភាពមានការងាររបស់យុវជន និងយុវនារី និងជនពិការ ជាពិសេសនៅជនបទ និង (ii) ពង្រីកវិសាលភាពកិច្ចគាំពារសង្គមដល់ពលករ និងពលការិនីដែលធ្វើការនៅក្នុងវិស័យរៀបរយ និងមិនផ្លូវការ។

បទបញ្ញត្តិស្តីពីកិច្ចគាំពារសង្គមបច្ចុប្បន្ន មានលក្ខណៈដាច់ឆ្ងាយពី

ចំពោះកិច្ចគាំពារសង្គម កម្ពុជាបានប្រកាសឱ្យប្រើច្បាប់ស្តីពីសុវត្ថិភាពសង្គមសម្រាប់កម្មករនៅក្នុងវិស័យឯកជន នៅក្នុងឆ្នាំ ២០០២ ប៉ុន្តែការអនុវត្តច្បាប់នេះឱ្យបានពេញលេញ ត្រូវការវិធានការ និងសកម្មភាពនយោបាយជាច្រើន ដើម្បីពង្រឹងសមត្ថភាព

**សកលលោក ហើយសមត្ថភាពស្ថាប័ន និងរដ្ឋបាលត្រូវការការពង្រឹងបន្ថែម**

អ្នករៀបចំគោលនយោបាយ និងដៃគូសង្គម ក៏ដូចជាកសាងសមត្ថភាពស្ថាប័ន និងរដ្ឋបាល ដើម្បីធ្វើការលើសុវត្ថិភាពសង្គម នេះ។ បន្ថែមពីលើនេះ កម្មករនៅក្នុងប្រទេសកម្ពុជា ស្ទើរតែមិនទទួលបានកិច្ចគាំពារសង្គម នៅពេលមានរបួសក្នុងម៉ោងការងារ គ្រោះថ្នាក់ ឬទទួលមរណៈភាពទេ។ ប្រទេសកម្ពុជាបានព្រមព្រៀងស្របតាម DWCP ក្នុងការសម្របសម្រួលគោលនយោបាយ និងវិធានការមុខរបររបស់ខ្លួន សម្រាប់វិសាលភាពនៃកិច្ចគាំពារសង្គម ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ចាប់តាំងពីពេលលំបាក រហូតដល់ចុងទសវត្សឆ្នាំ ៩០ ក៏ដូចជាឆ្លងកាត់ផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចថ្មីៗនេះសំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សស្តីពីការកាត់បន្ថយភាពក្រីក្រ។

## ១.២. កម្ពុជា - ការរំលឹកដោយសង្ខេបពីប្រវត្តិសាស្រ្ត និងសង្គម-នយោបាយ

**១៩៥៣-១៩៧០ យុគសម័យមាសនៃការអភិវឌ្ឍ**

បន្ទាប់ពីទទួលបានឯករាជ្យភាពនាឆ្នាំ ១៩៥៣ ប្រទេសកម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូរដ៏ច្របូកច្របល់នៅក្នុងរបបនយោបាយ និងសេដ្ឋកិច្ចរបស់ខ្លួនអស់រយៈពេល ៤ ទសវត្ស។ ក្រោមការដឹកនាំរបស់សម្តេច នរោត្តម សីហនុ ប្រទេសកម្ពុជាជាប្រទេសមួយដែលមានសេដ្ឋកិច្ចរីកចម្រើន និងសុវត្ថិភាពល្អមួយ ក្នុងទសវត្សឆ្នាំ ៦០ បើប្រៀបទៅនឹងប្រទេសជិតខាង។ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានមួយចំនួនធំ ត្រូវបានកសាងឡើងក្នុងអំឡុងពេលនោះ ហើយហេដ្ឋារចនាសម្ព័ន្ធខ្លះនៅមានបន្សល់ដល់សព្វថ្ងៃ។ ប៉ុន្តែ រដ្ឋប្រហារដែលធ្វើឡើងដោយលោកឧត្តមសេនីយ៍លន់ នល់ បានបង្ខំសម្តេចនរោត្តម សីហនុ ចុះចេញពីតំណែង នាឆ្នាំ ១៩៧០ ហើយប្រទេសកម្ពុជាបានក្លាយជាសាធារណៈរដ្ឋ។

**របបខ្មែរក្រហម**

កងកម្លាំងប្រឆាំងនឹងរដ្ឋាភិបាលសាធារណៈថ្មី ត្រូវបានបង្កើតឡើងជាកងកម្លាំងជាតិជួរមុខនៃកម្ពុជា ដោយមានការគាំទ្រពីវៀតណាមខាងជើង។ នាខែ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានកាន់កាប់ភ្នំពេញ និងបង្កើតជារបបមៅឡើង ដែលហៅថា ប្រជាធិបតេយ្យកម្ពុជា ក្រោមការដឹកនាំរបស់ប៉ុល ពត។ សេដ្ឋកិច្ចទីផ្សារត្រូវបានលុបបំបាត់ចោលទាំងស្រុង។ ប្រជាជនរស់នៅក្នុងទីក្រុងត្រូវបានបង្ខំឱ្យជំលៀសខ្លួនទៅជនបទដើម្បីធ្វើការងារកសិកម្ម ហើយអ្នកចេះដឹងធំៗ ត្រូវសម្លាប់ចោល។ តាមការប៉ាន់ស្មានបានបង្ហាញឱ្យឃើញថា ប្រជាជនប្រហែលជាង ១ លាននាក់ ត្រូវបានស្លាប់ ឬអត់អាហាររហូតដល់ស្លាប់ក្នុងអំឡុងសម័យប៉ុល ពត។

របបប៉ុល ពត ត្រូវបានផ្តួលរលំនៅឆ្នាំ ១៩៧៩ ដោយកងកម្លាំងវៀតណាម និងកងកម្លាំងតស៊ូកម្ពុជា។ កងកម្លាំងខ្មែរក្រហម នៅតែបន្តកាន់កាប់តំបន់ខ្លះនៅតាមព្រំដែនថៃ-កម្ពុជា រហូតដល់ឆ្នាំ ១៩៩៨។ រដ្ឋាភិបាលថ្មី ហៅថា សាធារណៈរដ្ឋប្រជាមានិតកម្ពុជា (PRK) ត្រូវបានបង្កើតឡើង និងទទួលបានជំនួយភាគច្រើនពីអតីតសហភាពសូវៀត។ របបនេះ គ្រប់គ្រងដោយបក្សកុម្មុយនីស ហៅថាបក្សបដិវត្តន៍ប្រជាមានិតកម្ពុជា ដែលបន្ទាប់មកវិវត្តជាគណបក្សប្រជាជនកម្ពុជា (CPP)។

**អំឡុងពេលផ្សះផ្សា**

ការផ្សះផ្សាគ្នា ចាប់ផ្ដើមនៅឆ្នាំ ១៩៨៧ ហើយទ័ពជំនួយចុងក្រោយបំផុតរបស់ទ័ពវៀតណាម ដកខ្លួននៅឆ្នាំ ១៩៨៩។ រដ្ឋធម្មនុញ្ញត្រូវបានធ្វើវិសោធនកម្ម រដ្ឋកម្ពុជាក៏កើតមានឡើង។ នាឆ្នាំ ១៩៩១ ភាគីនយោបាយធំៗទាំង ៤ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលនាំឱ្យមានការបោះឆ្នោតទូទៅមួយនៅឆ្នាំ ១៩៩៣ និងបង្កើតឱ្យមានប្រព័ន្ធនយោបាយសេរី និងពហុគណបក្ស។ ប្រទេសកម្ពុជា ក៏ជួបប្រទះនូវអន្តរកាលឈានទៅរកសេដ្ឋកិច្ចទីផ្សារនៅឆ្នាំ ១៩៨៩ ដោយស្វែងរកជំនួយខាងក្រៅពីលោកខាងលិច បន្ទាប់ពីអតីតសហភាពសូវៀតបានដួលរលំ។ របបថ្មីនេះ អនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជនមានកម្រិតលើទ្រព្យសម្បត្តិ និងសហគ្រាសឯកជន ហើយសហគ្រាសរបស់រដ្ឋ (SOEs) ត្រូវបានក្លាយជាស្វយ័ត។

**រដ្ឋធម្មនុញ្ញ (ទី ៦)៖ ការផ្ដើមកសាងស្ថាប័នប្រជាធិបតេយ្យថ្មី**

អាជ្ញាធរអន្តរកាលរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩២ ដើម្បីជួយគ្រប់គ្រងប្រទេសរហូតដល់ប្រទេសកម្ពុជាមានរដ្ឋាភិបាលស្របច្បាប់ថ្មីមួយដែលកើតឡើងចេញពីការបោះឆ្នោតជាសកល។ ការបោះឆ្នោតជាសកល ប្រព្រឹត្តទៅក្រោមការរៀបចំរបស់ UNTAC នៅខែឧសភា ឆ្នាំ ១៩៩៣ ហើយរដ្ឋាភិបាលរួមគ្នាមួយត្រូវបានបង្កើតឡើងដោយគណបក្សនយោបាយធំៗចំនួន ៣ គឺគណបក្ស ហ៊្វុនស៊ិនប៉ិច (FUNCINPEC) គណបក្សប្រជាជនកម្ពុជា (CPP) និងគណបក្សប្រជាធិបតេយ្យសេរីព្រះពុទ្ធសាសនា។ ការសម្របសម្រួលខាងផ្នែកនយោបាយនេះ បណ្ដាលឱ្យមានការរៀបចំដ៏ទើសទាល់មួយ ដូចជានាយករដ្ឋមន្ត្រី ២, សហរដ្ឋមន្ត្រីនៃក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិជាដើម។ រដ្ឋធម្មនុញ្ញថ្មី ត្រូវបានប្រកាសឱ្យប្រើដោយរដ្ឋសភា នៅឆ្នាំ ១៩៩៣។ រដ្ឋធម្មនុញ្ញមានចែងពីការបង្កើតប្រទេសកម្ពុជាជាប្រទេសរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានព្រះមហាក្សត្រសោយរាជ្យ ប៉ុន្តែមិនគ្រប់គ្រងប្រទេសនោះទេ និងកាន់របបប្រជាធិបតេយ្យសេរី និងសេដ្ឋកិច្ចទីផ្សារ។

រដ្ឋធម្មនុញ្ញក៏មានចែងពីពហុគណបក្ស ប្រជាធិបតេយ្យសេរី ដែលប្រជាជនអាចប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលកម្ពុជា និងអំណាចតុលាការ។ នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ ស្ថិតនៅដាច់ដោយឡែកពីគ្នា ហើយប្រជាពលរដ្ឋទាំងអស់មានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ រដ្ឋធម្មនុញ្ញទទួលស្គាល់នីតិរដ្ឋ និងសិទ្ធិមនុស្ស ដូចមានកំណត់នៅក្នុងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងធានាសេរីភាពបញ្ចេញមតិ សេរីភាពសារព័ត៌មាន (ច្បាប់ស្ដីពីរបបសារព័ត៌មាន ឆ្នាំ ១៩៩៥) និងសេរីភាពប្រមូលផ្ដុំ។

**រដ្ឋទទួលខុសត្រូវសកម្មនៅក្នុងវិស័យអប់រំ សុខភាព និងការឧបត្ថម្ភសង្គមដល់ជនក្រីក្រ និងជនងាយរងគ្រោះ**

រដ្ឋការពារសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានការអប់រំស្មើគ្នាយ៉ាងតិចណាស់ ៩ ឆ្នាំដោយឥតគិតថ្លៃ ទាំងនៅបឋមសិក្សា និងអនុវិទ្យាល័យ។ ជាចុងបញ្ចប់ កម្ពុជាត្រូវតែរៀបចំនូវប្រព័ន្ធអប់រំមួយដែលមានលក្ខណៈទូលំទូលាយ និងមានស្តង់ដារទូទាំងប្រទេស រៀបចំកាលវិភាគសិក្សាដែលផ្អែកលើគោលការណ៍គរុកោសល្យសម័យទំនើប និងគ្រប់គ្រងលើសាលាសាធារណៈ និងឯកជនទាំងអស់។

រដ្ឋក៏ត្រូវមានទំនួលខុសត្រូវក្នុងការផ្តល់សេវាសុខភាព និងឧបត្ថម្ភដល់ជនងាយរងគ្រោះនៅក្នុងសង្គម ដោយសង្កត់ធ្ងន់លើការបង្ការជម្ងឺ ការព្យាបាលជម្ងឺ និងការពិគ្រោះជម្ងឺដោយឥតគិតថ្លៃ និងសេវាកម្មសម្ភពសម្រាប់ប្រជាជនក្រីក្រ ជាពិសេសនៅតាមជនបទ។ រដ្ឋត្រូវតែឧបត្ថម្ភដល់កុមារ មាតា ជនពិការ និងគ្រួសារយុទ្ធជនដែលពលីជីវិតដើម្បីប្រទេសជាតិ ហើយរដ្ឋក៏ត្រូវបង្កើតប្រព័ន្ធសុវត្ថិភាពសង្គមដែរ។

### ១.៣. ការអភិវឌ្ឍសេដ្ឋកិច្ច

៣ ដំណាក់កាល នៃការអភិវឌ្ឍសេដ្ឋកិច្ច

ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ១៩៨៩ ត្រូវបានបែងចែងជា ៣ ដំណាក់កាលៈ (i) ដំណាក់កាលស្តារនិតសម្បទាឡើងវិញ ចាប់ពីឆ្នាំ ១៩៨៩ ដល់ឆ្នាំ ១៩៩៨ ដោយផ្តោតសំខាន់ទៅលើឯកជនភាវូបនីយកម្ម និង ការមិនប្រមូលផ្តុំ និងជួបនូវការលំបាកជាច្រើនទៀតដូចនឹងប្រទេសផ្សេងទៀតដែលស្ថិតក្នុងភាពអន្តរកាលដូចគ្នា (ii) ដំណាក់កាលកសាងឡើងវិញ ចាប់ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៣ ដែលចាត់ទុកជាដំណាក់កាលសម្រាប់កំណែទម្រង់ស្ថាប័ន និងការពង្រឹងកំណែទម្រង់ទីផ្សារ រួមទាំងសេរីភាវូបនីយកម្មរួមជាមួយនឹងសម្មាមតិសេដ្ឋកិច្ចរបស់កិច្ចព្រមព្រៀងវ៉ាស៊ីងតោន និង (iii) ដំណាក់កាលកំណើនខ្ពស់ ចាប់ពីឆ្នាំ ២០០៤ រហូតដល់ឆ្នាំ ២០០៨ និងបញ្ចប់នៅពេលមានផ្ទុះវិបត្តិហិរញ្ញវត្ថុសកលលោក ដោយមានអត្រាកំណើន GDP ត្រឹម 10.2% ជាមធ្យមក្នុងមួយឆ្នាំ។

ដោយមានកំណត់ត្រាពីកំណើន GDP គួរឱ្យកត់សម្គាល់

ក្នុងអំឡុងចន្លោះឆ្នាំ ២០០២-២០១០ កំណើន GDP ប្រចាំឆ្នាំ មានជាមធ្យមកើនដល់ 7.9% ។ អត្រាកំណើននេះមានកម្រិតខ្ពស់ជាងពីពេលមុនមានវិបត្តិហិរញ្ញវត្ថុក្នុងអត្រា 9.9% ក្នុងមួយឆ្នាំ ក្នុងអំឡុងឆ្នាំ ២០០៨-២០០៨។ ក្នុងអំឡុងពេលដដែលនេះ លទ្ធផលពិតប្រាកដនៅក្នុងវិស័យចំបង (កសិកម្ម, រុក្ខាប្រមាញ់ និងនេសាទ) កើនឡើងជាមធ្យមដល់ 6.8% ក្នុងមួយឆ្នាំ ក្នុងខណៈពេលដែលវិស័យឧស្សាហកម្មកើនឡើងដល់ 11.9% ។ កំណើនសេដ្ឋកិច្ច ក៏មានកម្រិតខ្ពស់នៅក្នុងវិស័យទី ៣ (ពាណិជ្ជកម្ម និងសេវាកម្ម) ត្រឹម 10.2% ក្នុងមួយឆ្នាំ *(មើល SPER)*។ ក្រៅពីកំណើនយ៉ាងលឿននៃវិស័យឧស្សាហកម្ម និងសេវាកម្មតាមជាក់ស្តែង ចំណែកនៃកសិកម្មនៅក្នុងសេដ្ឋកិច្ចសរុប ដែលវាស់ក្នុងតម្លៃបច្ចុប្បន្ន កើនឡើងលើស (២០០២-២០១០) ចាប់ពី 31.1% ដល់ 36% ដោយសារតែការកើនឡើងតម្លៃសំខាន់ៗនៃទំនិញកសិកម្មក្នុងអំឡុងពេលនោះ។

និងអត្រាអតិផរណាដែលអាចគ្រប់គ្រងបាន

សន្ទស្សន៍ GDP កើនឡើងជាមធ្យមត្រឹម 5.6% ក្នុងមួយឆ្នាំ ក្នុងអំឡុងពេល ២០០២-២០១០។ ការកើនឡើងប្រចាំឆ្នាំខ្ពស់បង្ហាញឱ្យឃើញគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ ២០០៧ និង ២០០៨ ដែលបណ្តាលមកពីតម្លៃទំនិញកើនឡើងទូទាំងពិភពលោកយ៉ាងខ្លីមុនមានវិបត្តិហិរញ្ញវត្ថុ។ ថ្លៃរបស់អ្នកប្រើប្រាស់ដែលបានកំណត់ដោយ CPI កើនឡើងយ៉ាងលឿនប្រហែលជា6.5% ជាមធ្យមនៅក្នុងអំឡុងពេលដូចគ្នា។ ការកើនឡើង CPI មានកម្រិតខ្ពស់យ៉ាងពិសេសនៅឆ្នាំ ២០០៨ នៅពេលដែលថ្លៃរបស់អ្នកប្រើ

កើនឡើងដល់ 25% ជាមធ្យម។ ប៉ុន្តែដោយសារតែវិបត្តិហិរញ្ញវត្ថុសកលលោក និងការធ្លាក់ចុះសេដ្ឋកិច្ច ធ្វើឱ្យសម្ពាធខាងតម្លៃជាបញ្ហាមួយចាប់តាំងពីពេលនោះមក។ នៅឆ្នាំ ២០១០ ការកើនឡើង CPI មានត្រឹមតែ 4% តែប៉ុណ្ណោះ។

### ១.៤. កំណែទម្រង់ស្ថាប័នៈ វិមជ្ឈការ និងអភិបាលកិច្ចកាន់តែប្រសើរ

**ក្របខណ្ឌសម្រាប់កំណែទម្រង់វិមជ្ឈការ**

ក្នុងទសវត្សចុងក្រោយនេះ របៀបវារៈកំណែទម្រង់អភិបាលកិច្ចបានផ្តោតទៅលើវិមជ្ឈការ ដែលចាត់ទុកជាការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិនៅកម្ពុជា។ នៅឆ្នាំ ២០០១ ច្បាប់ស្តីពីការគ្រប់គ្រងឃុំ/សង្កាត់ ត្រូវបានអនុម័តឡើង ហើយការបោះឆ្នោតឃុំ/សង្កាត់ ត្រូវបានធ្វើឡើងនៅឆ្នាំ ២០០២ ដើម្បីបង្កើតក្រុមប្រឹក្សាឃុំ/សង្កាត់ដែលជ្រើសរើសបែបប្រជាធិបតេយ្យ។

នៅឆ្នាំក្រោយមក គោលដៅនៃកំណែទម្រង់ D&D ត្រូវបានបញ្ចូលបន្ថែមនៅក្នុង *ក្របខណ្ឌយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ* (ក្របខណ្ឌយុទ្ធសាស្ត្រ) ដែលជាដំណើរការកំណែទម្រង់មួយសំដៅ (i) រួមបញ្ចូល និងស៊ីជម្រៅពីដំណើរការប្រជាធិបតេយ្យនីយកម្មនៅថ្នាក់ក្រោម និង (ii) ជំរុញការអភិវឌ្ឍក្នុងស្រុក និងកាត់បន្ថយភាពក្រីក្រ។ កំណែទម្រង់នេះនាំឱ្យមានការបង្កើតជាក្រុមប្រឹក្សាឃុំ/សង្កាត់ និងខេត្ត និងការបង្កើតរដ្ឋបាលដែលមានគណនេយ្យភាព និងជារួមនៅថ្នាក់ក្រោមជាតិ ដើម្បីជួយដល់ក្រុមប្រឹក្សា។

**ជាមួយនឹងវិភាជន៍ថវិកាមូលដ្ឋាន**

ស្របជាមួយនឹងការអភិវឌ្ឍគោលនយោបាយ និងក្របខណ្ឌគតិយុត្តិ សកម្មភាពវិមជ្ឈការ ត្រូវបានចាប់ផ្តើមនៅថ្នាក់មូលដ្ឋាន។ នៅឆ្នាំ ២០០៧ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រព្រឹត្តទៅនៅឃុំ និងសង្កាត់ចំនួន ១៦២១ ហើយនៅឆ្នាំ ២០០៩ ការបោះឆ្នោតត្រូវបានរៀបចំសម្រាប់ក្រុមប្រឹក្សាខេត្ត និងក្រុង។

ជាមួយនឹងអាជ្ញាធរនយោបាយ ប្រភពខ្លះត្រូវបានធ្វើវិមជ្ឈការមុនការកំណែទម្រង់។ មូលនិធិឃុំ/សង្កាត់ (C/S Fund) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០១ ដែលជាជំហានទី ១ នៃប្រព័ន្ធឧបត្ថម្ភសារពើភណ្ឌអន្តររដ្ឋាភិបាល ដើម្បីផ្តល់ហិរញ្ញប្បទានទាំងចំណាយរដ្ឋបាល និងអភិវឌ្ឍន៍ ដែលគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ/សង្កាត់។ វិភាជន៍សម្រាប់មូលនិធិឃុំ/សង្កាត់ បានពីប្រាក់ចំណូលជារឿយៗ កើនឡើងជារៀងរាល់ឆ្នាំរហូតដល់ 2.8% នៃប្រាក់ចំណូលប្រចាំឆ្នាំសរុបក្នុងឆ្នាំ ២០១០។ បទពិសោធន៍មូលនិធិឃុំ/សង្កាត់មានលក្ខណៈវិជ្ជមាន។ ក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រើប្រាស់មូលនិធិឃុំ/សង្កាត់ ដើម្បីផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មមូលដ្ឋាន។ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនេះទទួលបានអំណាចតាមរយៈថវិកាតូចមួយ ដែលផ្តល់នូវភាពបត់បែនខ្លះ និងត្រូវការដំណើរការរៀបចំដែលមានការចូលរួម និងតម្រូវការដាក់នូវយន្តការគណនេយ្យភាពចុះ ដែលមានរួមបញ្ចូលនៅក្នុងក្របខណ្ឌគោលនយោបាយ។

និងដំណើរការស្របនៃការលើកកម្ពស់ PFM

ការខំប្រឹងលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ចាប់ផ្តើមនៅឆ្នាំ ១៩៩៥។ កំណែទម្រង់ PFM ត្រូវបានចាត់ទុកថាជាធាតុផ្សំគន្លឹះមួយនៅក្នុងការផ្តល់សេវាកម្ម និងវិភាជន៍មូលធនកាន់តែប្រសើរ។ ប៉ុន្តែការប្រឹងប្រែងកែទម្រង់ដំបូងមានផលប៉ះពាល់រឹងមាំតិចតួច។ នាឆ្នាំ ២០០២ រាជរដ្ឋាភិបាលកម្ពុជាបានផ្សព្វផ្សាយការប្រឹងប្រែងជាច្រើន ដើម្បីភ្ជាប់ដៃគូទាំងអស់នៅក្នុងការវិនិច្ឆ័យពីបញ្ហា និងការលំបាកដែលពាក់ព័ន្ធនឹង PFM នៅកម្ពុជា។ លទ្ធផលនៃការពិភាក្សាទាំងនេះត្រូវបានចងក្រងឡើងនៅក្នុង ការត្រួតពិនិត្យគណនេយ្យភាពហិរញ្ញវត្ថុ និងចំណាយសាធារណៈដែលរួមបញ្ចូលនៅឆ្នាំ ២០០៣ (IFAPER)។ សេចក្តីសន្និដ្ឋានជាគន្លឹះជាតម្រូវការសម្រាប់បង្កើនចំណូល ដោះស្រាយហានិភ័យខ្ពស់ក្រដាសប្រាក់របស់ប្រព័ន្ធ ភ្ជាប់ការចំណាយឱ្យកាន់តែជិតទៅនឹងលទ្ធផល និងផ្តល់នូវអាទិភាពខ្ពស់ដល់កំណែទម្រង់សេវាកម្មស៊ីវិល រួមទាំងទម្រង់លើកទឹកចិត្តដោយផ្អែកលើការបំពេញការងារ។

នៅខែធ្នូ ឆ្នាំ ២០០៤ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសផ្សព្វផ្សាយនូវកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេល ១០ ឆ្នាំ (PFMRP) ។ ក្នុងករណីនេះ PFMRP រៀបចំឡើងជាដំណើរការកំណែទម្រង់មួយជំហានម្តងៗ ឬជាអភិក្រមកម្មវិធីនយោបាយដែលផ្អែកលើកម្មវិធីនយោបាយជាលំដាប់ចំនួន ៤ គឺៈ (១) ថវិកាគួរឱ្យជឿជាក់ជាងមុន (២) គណនេយ្យភាពហិរញ្ញវត្ថុដែលមានប្រសិទ្ធភាព (៣) របៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលអាចអនុវត្តបានទាំងស្រុង និងមានអាទិភាព និង (៤) អ្នកគ្រប់គ្រង់របស់រាជរដ្ឋាភិបាលកម្ពុជាមានទំនួលខុសត្រូវយ៉ាងពេញលេញក្នុងការអនុវត្តកម្មវិធីនេះ។
លទ្ធផលរួបីយ៍ដែលសម្រេចបានដល់សព្វថ្ងៃ នៃកម្មវិធីនយោបាយ PFMRP ទី ១ រួមមានការលើកកម្ពស់រដ្ឋបាលពន្ធដារ ការប្រមូលចំណូល ការគ្រប់គ្រងការចំណាយ ការគ្រប់គ្រងសាច់ប្រាក់ និងការផ្តល់ថវិកា។ ក្នុងខណៈដែលការខំប្រឹងប្រែងអនុវត្តកម្មវិធីនយោបាយទី ១ កំពុងតែបន្ត រាជរដ្ឋាភិបាលកម្ពុជាក៏បានចាប់ផ្តើមចេញវិធានការកំណែទម្រង់ស្របតាមកម្មវិធីនយោបាយទី ២។

# ជំពូកទី ២៖ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជាក្នុងទស្សនៈជាសកល

## ២.១. សេចក្តីផ្តើម

ជំពូកនេះ ពន្យល់ពីការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅកម្ពុជា ក្នុងទស្សនៈទូលំទូលាយជាអន្តរជាតិ។ ជំពូកនេះ បង្ហាញថាភាពប្រឈមរបស់កម្ពុជាមិនមែនជារឿងចំឡែកទេ ហើយដំណោះស្រាយដែលមានប្រសិទ្ធភាព គឺមានស្រាប់។ ជំពូកនេះ ក៏រៀបចំបន្ថែមពីមូលដ្ឋានសម្រាប់សារថ្នាក់កណ្តាលនៅក្នុងរបាយការណ៍នេះ ដែលគោលនយោបាយមុខរបរ និងកិច្ចគាំពារសង្គម កំពុងពង្រឹងទៅវិញទៅមក និងមានប្រសិទ្ធភាពបំផុត នៅពេលដែលរួមបញ្ចូលក្នុងក្របខណ្ឌសង្គតភាពជារួម។

## ២.២. កំណើនសេដ្ឋកិច្ច និងគោលដៅសង្គម

គោលដៅអភិវឌ្ឍសហសវត្សក្នុងលក្ខខណ្ឌសកល៖ ពិភពលោកមិនដើរស្របគ្នា

គោលដៅអភិវឌ្ឍន៍សហស្សវត្សមួយ ក្នុងចំណោមគោលដៅដទៃទៀត គឺសំដៅកាត់បន្ថយអត្រាគ្រួសារក្រីក្រទូទាំងសកលលោកឱ្យបាន 50% នៅឆ្នាំ ២០១៥។ ច្រើនជាង ២ភាគ៣ នៃជីវិតមនុស្សក្នុងការសម្រេចឱ្យបានគោលដៅនេះ ស្ថិតនៅលើយើងទាំងអស់គ្នា ហើយជារួមវាហាក់ដូចជាយើងមិនអាច សម្រេចបានទេ។ ជាងនេះទៅទៀត ការអភិវឌ្ឍលើតម្លៃចំណីអាហារនាពេលថ្មីៗ និងវិបត្តិហិរញ្ញវត្ថុសកលលោកនាពេលថ្មីៗនេះ បានបណ្តាលឱ្យមានការខូចប្រយោជន៍យ៉ាងសំបើមមួយដែលប៉ះពាល់ដល់ប្រទេសក្រីក្របំផុតខ្លាំងជាងគេ។ សូម្បីតែស្ថិតិថ្មីបំផុតស្តីពីចំនួនជនក្រីក្រ ក៏ហួសសម័យក្នុងគំនិតនៃការអភិវឌ្ឍដែរ។ ឧទាហរណ៍ដូចជា នៅឆ្នាំ ២០០៧ តម្លៃស្រូវសាលីកើនឡើងដល់ 77% និងអង្ករ កើនឡើងដល់ 16%។ ពេលនោះ តម្លៃស្រូវសាលី និងអង្ករ ជាតម្លៃមួយដែលកើនឡើងខ្ពស់បំផុតក្នុងចំណោមតម្លៃចំណីអាហារទាំងអស់។ ប៉ុន្តែចាប់តាំងពីឆ្នាំ ២០០៨ ល្បឿនប្រែប្រួលនៃតម្លៃអង្ករតែមួយមុខបានកើនឡើងដល់ 141% ក្នុងអំឡុងពេល ៤ ខែដំបូងនាឆ្នាំ ២០០៨។ ការកើនឡើងតម្លៃទាំងនេះមិនសូវឆ្លើយតបទៅនឹងព្រឹត្តិការណ៍ចំបងៗប៉ុន្មានទេ ដូចជាការធ្លាក់ចុះនៃការប្រមូលផល។ តម្លៃមានការកើនឡើង ដោយសារកត្តាតម្រូវការ ដូចជាតម្រូវការខ្ពស់ពីការកើនឡើងសេដ្ឋកិច្ច -ដូចជាប្រជាជននៅប្រទេសចិន និងឥណ្ឌាក្លាយជាអ្នកមាន- និងតម្រូវការកើនឡើងនៅប្រទេសឧស្សាហកម្មក្នុងការជួយកម្មវិធីថាមពលផ្សេងទៀតរបស់ប្រទេស។

ផលប៉ះពាល់ពីតម្លៃឡើងថ្លៃទាំងនេះទៅលើជនក្រីក្រ និងជនងាយរងគ្រោះ មានទំហំធំធេង។ តាមការសង្កេត បានឱ្យដឹងថា 20% នៃការឡើងថ្លៃចំណីអាហារ នឹងធ្វើឱ្យមនុស្សប្រហែល ១០០ លាននាក់ ចំណាយតិចជាង 1 USD លើថ្លៃអាហារក្នុងមួយថ្ងៃ។ ចំនួននេះ នឹងធ្វើឱ្យភាពក្រីក្រកើនឡើងវិញនៅក្នុងប្រទេសមួយចំនួន ដែលនេះត្រូវការដំណោះស្រាយខាងរចនាសម្ព័ន្ធកាន់តែច្រើន -ដូចជាការចែកចាយសាច់ប្រាក់

មិនមែនចំណីអាហារ និងគាំទ្រគម្រោងការណ៍កិច្ចគាំពារសង្គមដែលមានស្រាប់ ឬបង្កើតគម្រោងការណ៍កិច្ចគាំពារសង្គមថ្មី។

កម្ពុជាក៏ដូចគ្នាដែរ ដែលនៅមានការណ៍ត្រូវធ្វើជាច្រើន

ប្រទេសកម្ពុជា បានប្តេជ្ញាសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ *(យុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣)* ។ កំណើនយ៉ាងលឿនរបស់ប្រទេសកម្ពុជាចាប់តាំងពីចុងទសវត្សឆ្នាំ ១៩៩០ រហូតមកដល់ឆ្នាំ ២០០៧នេះ មានទំនាក់ទំនងជាវិជ្ជមានជាមួយនឹងការកាត់បន្ថយភាពក្រីក្រ។ ចំពោះគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ផ្សេង និងសូចនាករនៃគោលដៅទាំងនោះនៃការសម្រេចបានតាមគោលដៅ យើងទទួលបាននូវលទ្ធផលក្នុងរូបភាពចម្រុះផ្សេង។

កំណើនសេដ្ឋកិច្ចត្រូវបានផ្តាច់ចេញពីគោលដៅសង្គម

អក្សរសាស្ត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ថ្មីៗមួយចំនួន ផ្តោតទៅទំនាក់ទំនងបញ្ច្រាសរវាងកំណើនសេដ្ឋកិច្ច និងលទ្ធផលសង្គមនៅក្នុងទស្សនៈជាសកល។ នៅក្នុងព័ត៌មានកាសែតស្តីពីសេដ្ឋកិច្ចជាច្រើន បាននិយាយពីការពិភាក្សាថាតើកំណើនសេដ្ឋកិច្ចនៅប្រទេសកំពុងអភិវឌ្ឍន៍ផ្តល់នូវប្រយោជន៍ដល់ជនក្រីក្រឬយ៉ាងណា។ អ្នកខ្លះបានតវ៉ាថាវាពិតជាផ្តល់នូវប្រយោជន៍ដល់ជនក្រីក្រ - ប៉ុន្តែតាមការសិក្សាចុងក្រោយបំផុតបានបង្ហាញចម្ងល់លើការ"ធ្លាក់ចុះ" នេះ។ យើងអាចនិយាយបានម្យ៉ាងទៀតថា កំណើននេះនៅតែជាចម្ងល់ ថាវាអាចផ្តល់ប្រយោជន៍ដល់ជនក្រីក្រដែរឬទេ។ ក្នុងចំណោមស្ថាប័នអន្តរជាតិទាំងអស់ ការមើលឃើញនេះបានបង្កើនទម្ងន់គួរឱ្យកត់សម្គាល់។

នេះក៏អនុវត្តផងដែរចំពោះកម្ពុជាដែលមានប្រជាជនភាគច្រើនជាជនងាយរងគ្រោះទៅនឹងវិបត្តិ

ជោគជ័យថ្មីៗរបស់ប្រទេសកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ គួរឱ្យកើតសរសើរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងគួរចងចាំថាភាពក្រីក្រនៅតែមានកម្រិតខ្ពស់ ជាពិសេសនៅតាមជនបទ នៅក្នុងតំបន់ដាច់លាក់ និងក្នុងចំណោមក្រុមប្រជាជនដាច់លាក់។ បន្ថែមពីលើនេះ ភាគរយប្រជាជនជាច្រើន មានប្រាក់ចំណូលក្នុងចន្លោះរវាងតិចជាង (1.25 USD ក្នុងមួយថ្ងៃ) និងច្រើនជាង (2 USD ក្នុងមួយថ្ងៃ) ហើយក្រុមនេះជាក្រុមជនងាយរងគ្រោះនៃវិបត្តិសេដ្ឋកិច្ច ឬផលវិបាកពីចំណូលមិនគ្រប់គ្រាន់នៅក្នុងជីវិតរបស់ពួកគាត់។ លើសពីនេះ ស្របតាមការបរិយាយខាងលើ ការកើនឡើងយ៉ាងខ្លាំងខាងវិសមភាពនៃចំណូល អាចផ្តល់ផលអាក្រក់ដល់ដំណើរការកាត់បន្ថយភាពក្រីក្រទៅមុខទៀត។

## ២.៣. ការអភិវឌ្ឍពាណិជ្ជកម្ម បច្ចេកទេស និងទីផ្សារការងារ

ពាណិជ្ជកម្មអន្តរជាតិទំនងជាប៉ះពាល់ដល់ពលករដែលគ្មានជំនាញ

ទោះបីជាមានការបើកចំហចំពោះអន្តរជាតិនីយកម្ម និងអត្រាកំណើនGDP អត្រាប្រាក់ឈ្នួលពិត និងអត្រាកំណើនមុខរបរ នៅបណ្តាប្រទេសមួយចំនួន មានការធ្លាក់ចុះជាបណ្តើរៗ។ តាមការពិត ប្រទេសមួយចំនួនបែរជាយល់ផ្ទុយទៅវិញ ថាការបើកចំហចំពោះពាណិជ្ជកម្មអន្តរជាតិទើបបណ្តាលឱ្យមានឧស្សាហកម្មទាំងមូលដួលរលំ។

ការបើកចំហរបស់បណ្តាប្រទេសទៅនឹងពាណិជ្ជ

ផលប៉ះពាល់នៃការប្រកួតប្រជែងលើមាត្រដ្ឋានជាសកល ហើយលក្ខណៈដែលប៉ះពាល់ដល់ប្រទេសកំពុងអភិវឌ្ឍ បានបង្ហាញឱ្យឃើញថាមតិយោបល់ចេញពីប្រទេស

កម្មអន្តរជាតិអាចនាំឱ្យមាន "ការឈានទៅរកភាពធ្លាក់ចុះ"

កំពុងអភិវឌ្ឍខ្លះជាការគិតខ្លីដែលថាស្តង់ដារការងារមិនអាចទទួលយកបានរហូតដល់កម្រិតខ្ពស់ជាងនៃសុខមាលភាពសេដ្ឋកិច្ចបានសម្រេចនោះ។ ប្រទេសទាំងនេះមិនចង់លះបង់អត្ថប្រយោជន៍ប្រៀបធៀបរបស់ខ្លួននោះទេ ច្រើនពេកអាចទទួលយកបាន។ ប៉ុន្តែមតិយោបល់ដូចគ្នានេះដែរ ត្រូវបានលើកឡើងនៅក្នុងប្រទេសឧស្សាហកម្ម។ ការប្រកួតប្រជែងរបស់បណ្តាប្រទេសដែលថ្លៃពលកម្មទាប មិនអនុញ្ញាតឱ្យប្រទេសទាំងនេះឈានទៅរក ឬថែរក្សាបាននូវស្តង់ដារការងារ និងសង្គមបានទេ។ ផលវិបាក គឺការអភិវឌ្ឍទាក់ទងនឹងទីផ្សារការងារទ្វេភាគ។ ការងារផ្នែកខ្ពស់ជាង បែងចែកជា ការងារដែលទទួលបានប្រាក់ឈ្នួលគ្រប់គ្រាន់ -យ៉ាងហោចណាស់មើលពីខាងក្រៅ- ដោយមានកិច្ចគាំពារសង្គមដ៏ល្អសម្រាប់យថាហេតុជាច្រើន និងកិច្ចគាំពារផ្លូវច្បាប់នៅក្នុងម៉ោងធ្វើការ និងពេលបណ្តេញចេញ។ ប៉ុន្តែមនុស្សភាគច្រើនដែលមានជំនាញតិចតួច និងមានប្រវត្តិជាជនជាតិភាគតិចផ្សេង ត្រូវបានរាប់បញ្ចូលនៅក្នុងការងារផ្នែកផ្សេងទៀត។ ការងារផ្នែកទាបជាង ទទួលបានកម្រៃតិចជាង មិនស្ថេរភាព ពេលខ្លះមានគ្រោះថ្នាក់ ដោយគ្មានកិច្ចគាំពារផ្លូវច្បាប់ចំពោះការបណ្តេញចេញ និងមិនទៀងទាត់ ហើយជារឿយៗធ្វើការច្រើនម៉ោងទៀត។

ជាមួយនឹងវិស័យមិនផ្លូវការក្នុងនាមជាផ្នែកដោយឡែក

ការបែងចែកការងារជាផ្នែកនេះ ក៏អនុវត្តផងដែរ និងត្រូវបានប្រកាសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានសេដ្ឋកិច្ចមិនរៀបរយត្រូវបានចាត់ទុកថាសមាមាត្រនឹងការងារផ្នែកទាបជាងនៅក្នុងទីផ្សារការងារទ្វេភាគនៃប្រទេសឧស្សាហកម្ម។ នៅក្នុងការងារផ្នែកមិនរៀបរយនេះ -ដែលនៅក្នុងបណ្តាប្រទេសជាច្រើន រួមបញ្ចូលនូវ50% នៃកម្លាំងពលកម្មខាងលើ - លក្ខខណ្ឌការងារទំនងជាមិនច្បាស់លាស់។ កន្លែងការងារមិនត្រូវបានកំណត់ លក្ខខណ្ឌការងារមិនអាចទុកចិត្តបាន និងមិនច្បាស់លាស់ប្រាក់ចំណូលមានកម្រិតទាប និងមិនប្រក្រតី ម៉ោងធ្វើការមានរយៈពេលយូរ និងមិនមានកិច្ចគាំពារសង្គម និងការបណ្តុះបណ្តាលសម្បទានៅឡើយ។ លើសពីនេះ សកម្មភាពមិនមិនរៀបរយ មានការរីកដាលជាជាងលុបបំបាត់ចោលនៅក្នុងទសវត្សចុងក្រោយនេះ។ ជាធម្មតា សហគ្រាសមិនស្របច្បាប់ ផ្តល់នូវផលិតផល និងសេវាកម្ម ដែលធ្វើកិច្ចសន្យាបន្តពីការរៀបចំជាមួយនឹងសហគ្រាសស្របច្បាប់ ទាំងទីផ្សារក្នុងស្រុក និងការនាំចេញទៅបរទេស។ ពលករ ត្រូវបានជួលមកធ្វើការក្រោមកិច្ចសន្យាមិនរៀបរយជាជាងធ្វើជាកម្មករធម្មតា។

កំណើនសេដ្ឋកិច្ច *នៅក្នុងបណ្តាប្រទេសនានា* ជាធម្មតាមិនមានសមតុល្យទេ៖ នៅមាន"ជនក្រីក្រដែលប្រកបការងារ"ច្រើនទៀតដែលមានជំនាញតិច

នៅក្នុងប្រទេសដែលចូលរួមក្នុងដំណើរការសកលភាវូបនីយកម្ម បានបង្កើតជាដំណាក់ដ៏លឿនមួយនៃការផ្លាស់ប្តូរសេដ្ឋកិច្ច និងសង្គមកិច្ច។ ក្នុងខណៈដែលអត្ថប្រយោជន៍សំខាន់នៃការផ្លាស់ប្តូរនេះមានទំហំធំ មិនមែនគ្រប់បុគ្គល ឬក្រុមគ្រួសារទាំងអស់ដែលទទួលបានអត្ថប្រយោជន៍នោះទេ ហើយបញ្ហានេះបានបង្កើតឱ្យមានភាពតានតឹងនៅក្នុងសង្គម។

ប្រទេសមួយចំនួនធំ - និងរួមទាំងប្រទេសកម្ពុជា - មិនមានចំណេះដឹងផ្នែកបច្ចេកវិទ្យាដើម្បីឱ្យប្រទេសទាំងនោះមានផលិតភាពខ្ពស់ក្នុងពីវិស័យកសិកម្មទេ។

និងទស្សនៈសេដ្ឋកិច្ចនៅខ្សោយ

ក្នុងជំហានបន្ទាប់នៃការអភិវឌ្ឍប្រទេស នៅពេលដែលប្រទេសទាំងនោះមានការវិវត្តខាងផ្នែកបច្ចេកវិទ្យា ពួកគេនឹងជួបនូវការធ្វើទេសន្តប្រវេសន៍របស់កម្មករជាច្រើន ទៅកាន់ទីក្រុងដែលមានប្រជាជនច្រើន ឬបរទេស ដោយទស្សនៈនៅខ្សោយក្នុងការប្រើជំនាញរបស់ពួកគេឱ្យមានប្រយោជន៍។ ប្រសិនបើអាច គួរតែជៀសវាងបញ្ហានេះ។

ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាលំដាប់ជាបញ្ហាសំខាន់នៅក្នុងន័យនេះ គិតចាប់ពីវិស័យកសិកម្ម

ក្នុងខណៈដែលកំណើនផលិតផលកសិកម្មនៅកម្ពុជា មានការកើនឡើងនាពេលថ្មីៗនេះ ផលិតភាពនៃផលិតផលកសិកម្មនៅតែមានកម្រិតទាបនៅឡើយបើប្រៀបជាមធ្យមភាពជាមួយបណ្ដាប្រទេសនៅអាស៊ាន។ ទិន្នផលដំណាំកសិកម្ម កើនឡើងជាមធ្យមប្រហែល 10.7% ក្នុងមួយឆ្នាំក្នុងតម្លៃថេរ ដែលនេះជាការគួរឱ្យកោតសរសើរ ហើយអាចពន្យល់បាន ដោយសារការបម្រុងទុកផលិតភាពនៅក្នុងវិស័យកសិកម្ម ជាពិសេសនៅក្នុងដំណាំស្រូវ ដែលផលិតភាពនេះមានការកើនឡើងយ៉ាងលើសលុបដោយមានការកើនឡើងនូវការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ គ្រឿងយន្ត និងការប្រើប្រាស់ជីកសិកម្ម។ ប៉ុន្តែផលិតភាពដំណាំស្រូវគិតជាតោន ក្នុងមួយហិចតាស្មើតែនឹងពាក់កណ្ដាល នៅក្នុងប្រទេសវៀតណាមតែប៉ុណ្ណោះ។

ជារឿយៗ ភាពគ្មានការងារមិនមែនតែជាបញ្ហាប៉ុណ្ណោះទេ ភាពខ្វះការងារក៏ជាបញ្ហាចំបងមួយដែរ

ILO បានប៉ាន់ស្មានថានៅក្នុងទសវត្សឆ្នាំ ១៩៩០ ភាពគ្មានការងារជាសកលបានកើតឡើងចាប់ពី ១០០ លាននាក់រហូតដល់ ១៨៣ លាននាក់ក្នុងឆ្នាំ ២០០៣។ ស្ទើរតែពាក់កណ្ដាលនៃចំនួននេះ ជាយុវជនដែលមានអាយុចន្លោះពី ១៥ ឆ្នាំដល់ ២៤ ឆ្នាំ។ លើសពីនេះទៀត ភាពខ្វះការងារ ជាបញ្ហាធ្ងន់ធ្ងរទូទាំងពិភពលោក។ ILO បានបង្ហាញនៅឆ្នាំ ២០០៧ ថា ប្រហែល មួយភាគបី នៃកម្លាំងការងារសកលលោក ស្ថិតក្នុងភាពខ្វះការងារ ឬភាពគ្មានការងារ។ នៅក្នុងប្រទេសដែលមានចំណូលតិច និងមធ្យម ចំនួនជនក្រីក្រដែលប្រកបការងារ (ជាជនដែលក្រីក្រតែមានការងារធ្វើ) មានភាពខុសគ្នាទៅតាមប្រទេស ប៉ុន្តែនៅមានកម្រិតខ្ពស់។ នៅប្រទេសប្រេស៊ីល ជនក្រីក្រដែលប្រកបការងារមានចំនួន 5.1% និងនៅប្រទេសចិនមានចំនួន 19.1%។ ប្រទេសឥណ្ឌាមានជនក្រីក្រដែលប្រកបការងារចំនួន 45.5% និងនៅប្រទេសក្នុងទ្វីបអាហ្វ្រិកខ្លះ - ដូចជា ប្រទេសនីហ្សេរីយ៉ា និងម៉ាលី មានជនក្រីក្រដែលប្រកបការងាររហូតទៅដល់ 75%។

ប្រទេសកម្ពុជាក៏ជួបបញ្ហាភាពគ្មានការងារ និងភាពខ្វះការងារនេះដែរ ហើយបញ្ហានេះមានពាក់ព័ន្ធនឹងការផ្ដោតទៅលើគោលនយោបាយ

ភាពគ្មានការងារ និងខ្វះការងារពាក់ព័ន្ធដល់ប្រទេសកម្ពុជា។ ដោយសារតែភាពគ្មានការងារបច្ចុប្បន្ន មានកម្រិតទាបត្រឹម 1.6% ការកាត់បន្ថយភាពគ្មានការងារមិនចាត់ថាជាអាទិភាពនៅក្នុងគោលនយោបាយទេ។ ប៉ុន្តែ ការងារភាគច្រើនដែលកើតមានក្នុងទសវត្សនេះជាការងារដែលផ្ដល់ផលប្រយោជន៍ ឬអំណោយផលយ៉ាងគ្រប់គ្រាន់។ គោលដៅនៃគោលនយោបាយដែលមានប្រយោជន៍ ត្រូវសំដៅបន្តដល់វឌ្ឍនភាពនៃសូចនាករទាំង៤ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្ស 1b - មានដូចជា គ្រោះថ្នាក់របស់ជនក្រីក្រដែលប្រកបការងារ អត្រាការងារសម្រាប់ប្រជាជន សមាមាត្រប្រជាជនងាយរងគ្រោះ និងផលិតភាពការងារ។ ការសម្របសម្រួលកំណើនការងារវិស័យរៀបរយដែលទទួលបានកំរៃ នៅក្នុងវិស័យឯកជននិងសាធារណៈ គឺជាវិធីសមស្រប

មួយ។ បច្ចុប្បន្ននេះ ទីផ្សារការងារកម្ពុជា ត្រូវបានបែងចែកជាវិស័យរៀបរយដែលមានកម្រិត ដោយមានការងារភាគច្រើនស្ថិតនៅក្នុងសេដ្ឋកិច្ចមិនរៀបរយ។ ក្រុមយុវជននៅក្នុងភាពអត់ការងារសរុប នៅមានកម្រិតខ្ពស់។ ហើយក្នុងខណៈដែលអត្រាការងារសម្រាប់ប្រជាជនជាស្ត្រីកំពុងតែកើនឡើង ភាពខុសគ្នាខាងយេនឌ័រចំបងនៅតែមានក្នុងការទទួលបានការបណ្តុះបណ្តាល និងការអប់រំ និងទទួលបានការងារដែលមានប្រាក់ឈ្នួលប្រសើរជាង។ ផ្នែកនេះពាក់ព័ន្ធនឹងកង្វះទីផ្សារការងារ។ ជាឧទាហរណ៍ដូចជាប្រទេសនេប៉ាល់ ដែលអាចទាក់ទងនឹងប្រទេសកម្ពុជា។ ការចូលរួមពីកម្លាំងពលកម្ម មានកម្រិតខ្ពស់នៅប្រទេសនេប៉ាល់។ ប៉ុន្តែប្រជាជនដែលមានការងារតិចជាង 4% កំពុងធ្វើការនៅក្នុងការងារវិស័យរៀបរយ។ ក្រៅពីអត្រាផ្លូវការទាបនៃភាពគ្មានការងារចំនួន 2.2% អត្រាចំនួន 28.5% ជាអត្រានៃភាពខ្វះការងារដោយយោងតាមស្ថិតិស្ទង់មតិពីកម្លាំងពលកម្មថ្នាក់ជាតិ។ ពលករទាំងនេះ ធ្វើការម៉ោងតិចជាងតាមការចង់បាន ហើយទទួលបានប្រាក់ឈ្នួលតិចជាងអ្វីដែលត្រូវបាន ឬធ្វើការនៅកន្លែងដែលទាបជាងជំនាញដែលពួកគេមាន។ នេះជាសូចនាករដែលទីផ្សារការងារមិនបត់បែនបានគ្រប់គ្រាន់៖ ប្រជាជនយល់ថាពួកគាត់ធ្វើការនៅកន្លែងដែលមិនប្រើប្រាស់សមត្ថភាពរបស់ខ្លួនឱ្យបានពេញលេញ។ នៅក្នុងទីផ្សារការងារដែលបត់បែនជាងនេះ ប្រជាជនទំនងជារកការងារណាដែលអាចទាមទារច្រើន និងផ្តល់ការលើកទឹកចិត្តច្រើន - ទោះបីជាត្រូវប្រើពេលយូរបន្តិចក៏ដោយ។ ភាពសំខាន់នៃការងារដែលខ្វះការប្រើប្រាស់ជំនាញខ្លះប្រហែលជាចុងបញ្ចប់ក្លាយជាគ្មានការងារ។ ប៉ុន្តែនៅពេលដែលទីផ្សារការងារមានភាពបត់បែនបានគ្រប់គ្រាន់ ភាពអត់ការងារទំនងជាស្ថិតក្នុងរយៈពេលកំណត់។

ភាពខ្វះការប្រើប្រាស់ការងារ ទំនងជាពាក់ព័ន្ធទៅនឹងភាពទូទៅនៃភាពតឹងរឹងនៃទីផ្សារការងារ

ពលករមិនមែនជាទំនិញទេ ហើយទីផ្សារការងារមិនដំណើរការដូចជាទីផ្សារផ្សេងនោះទេ។ សហគ្រាស - តែឯង- ទំនងជាណែនាំពីកម្រិតខ្ពស់នៃកិច្ចគាំពារការងារសម្រាប់កម្លាំងពលកម្មរបស់សហគ្រាសទាំងមូល ដោយផ្តល់នូវគោលដៅចំណេញក្នុងរយៈពេលខ្លី។ ការប្តូរទីតាំងសកម្មភាពសេដ្ឋកិច្ចទៅខាងត្បូងវិញហាក់ដូចជាចងសម្ព័ន្ធជាមួយលក្ខខណ្ឌការងារគ្រោះថ្នាក់ជាច្រើន។ ឧទាហរណ៍ជាក់ស្តែង ដូចជាលក្ខខណ្ឌការងារអាក្រក់សម្រាប់បុគ្គលិកនៅលើកប៉ាល់ដែលធ្វើចរាចរមានដោតទង់ជាតិប្រទេសដែលទទួលបានប្រាក់ឈ្នួលទាប ដោយគ្មានច្បាប់ការងារ ឬ គ្រោះថ្នាក់ និងការងារដោយដៃមិនមានអនាម័យនៅក្នុងឧស្សាហកម្មកប៉ាល់នៅអាស៊ីខាងត្បូង។

ក្នុងករណីនេះ រដ្ឋាភិបាលត្រូវមានតួនាទីសកម្ម ដូចជាការសម្របសម្រួលដំណើរការឱ្យបានរលូននៃទីផ្សារការងារ និងការពារការងារ

ដូចនេះ រដ្ឋាភិបាល ត្រូវផ្តល់នូវក្របខណ្ឌដែលជំរុញសហគ្រាសក្នុងការស្វែងរកការប្រកួតប្រជែងក្នុងកម្រិតផលិតកម្មខ្ពស់ជាងនេះជាជាងការងារមានតម្លៃថោក។ ការប្រកួតប្រជែងត្រូវកើតមានឡើងរវាងក្រុមហ៊ុន មិនមែនរវាងប្រទេស និងប្រទេសទេ។ ការងាររបស់ Michael Porter បានលាតត្រដាងនូវឧទាហរណ៍ជាច្រើនអំពីក្រុមហ៊ុនអន្តរជាតិដែលអនុវត្តបានល្អ ពាក់ព័ន្ធនឹងស្តង់ដារបរិស្ថាន និងសង្គមនៅក្នុងប្រទេសរបស់ពួកគេ។ ក្រុមហ៊ុនទាំងនេះ បានរៀនស្វែងរកជ្រុងដែលប្រកួតប្រជែង ដោយមិន

ផ្តោតតែលើការលើកកម្ពស់បច្ចេកវិទ្យា និងការរៀបចំ។ រដ្ឋាភិបាលមានទំនួលខុសត្រូវការពារពលកម្ម មិនមែនធ្វើទីផ្សារពលកម្មថាជាកត្តាផលិតកម្ម និងរូបីយ៍នោះទេ។

## ២.៤. ម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌគោលនយោបាយឧស្សាហកម្ម

ស្វែងរកផលប្រយោជន៍ប្រកួតប្រជែងរបស់កម្ពុជា

របាយការណ៍ប្រវត្តិរបស់ ILO (Muqtada ឆ្នាំ ២០១១) ត្រួតពិនិត្យពីភាពចំបងនៃវិស័យដែលបានជ្រើសរើស (កសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម ការសាងសង់ និងសេវាកម្ម) ពាក់ព័ន្ធនឹងការបង្កើតមុខរបរ។ ជាឧទាហរណ៍ ឧស្សាហកម្មស្បែកជើង និងសំលៀកបំពាក់ដែលពឹងផ្អែកលើពលកម្ម កើនឡើង 13.7% ក្នុងមួយឆ្នាំក្នុងចន្លោះឆ្នាំ ២០០២ - ២០០៨ លើស 10% នៃទិន្នផលសរុប វិស័យនេះជាអ្នកបែងចែកយ៉ាងសំខាន់ដល់កំណើនមុខរបរនៅក្នុងវិស័យ "រៀបរយ"។ ការសាងសង់កើនឡើង 13.1% ប្រចាំឆ្នាំ និងតាងឱ្យ 6% នៃតម្លៃបន្ថែមសរុប។ នៅក្នុងវិស័យពាណិជ្ជកម្ម និងសេវាកម្មអន្តរការីហិរញ្ញវត្ថុ ជាផ្នែកដែលកើនឡើងយ៉ាងឆាប់រហ័សបំផុត កើនឡើងដល់ 18.5% ក្នុងមួយឆ្នាំក្នុងចន្លោះឆ្នាំដដែលនោះ (២០០២-២០០៨)។ វិស័យផ្សេងក៏មានការកើនឡើងដែរ ដូចជាសណ្ឋាគារ និងភោជនីយដ្ឋាន ចំនួន 9.6% ហើយ "សេវាកម្មផ្សេង" ចំនួន 15.2% ក្នុងមួយឆ្នាំ។ យុទ្ធសាស្ត្រតាមវិស័យត្រូវការការត្រួតពិនិត្យឡើងវិញក្នុងគោលបំណងអត្ថប្រយោជន៍ប្រកួតប្រជែង ដូចជាតាមរយៈការប្រើប្រាស់សមត្ថភាព និងការបង្កើនផលិតភាព និងចំណូលនៅក្នុងការផលិតនៅក្នុងស្រុក និងការនាំចេញ។

បើកទូលាយដល់មូលដ្ឋានឧស្សាហកម្ម

ជាយូរមកហើយ ប្រទេសកម្ពុជា ក៏ដូចជាប្រទេសជិតខាងនៅអាស៊ីអាគ្នេយ៍ បានអនុវត្តតាមយុទ្ធសាស្ត្រកំណើនដែលបានពីការនាំចេញ និងពឹងផ្អែកលើពលកម្ម។ ក្នុងខណៈដែល ទាំងនេះជាជោគជ័យដោយផ្នែក ឧទាហរណ៍ដូចជានៅក្នុងកំណើនយ៉ាងលឿននៃការនាំចេញសំលៀកបំពាក់ ដែលនេះសន្មតថាជាកាលៈទេសៈចៃដន្យមួយដែលនឹងមិនទំនងជាអាចមាននិរន្តភាពនាពេលអនាគត។ ចំណុចសំខាន់បំផុតគឺភាពពឹងផ្អែកយ៉ាងខ្លាំងទៅលើការវិនិយោគបរទេសដោយផ្ទាល់ (FDI) ។ ប្រទេសក្នុងតំបន់ទាំងនោះ ដែលបានទទួលជោគជ័យកាលពីអតីតកាល បានរៀបចំមូលដ្ឋានឧស្សាហកម្មរបស់ពួកគេរួចជាស្រេច។ ការសិក្សាពី "ការភ្ជាប់ភាពមុននិងក្រោយ" និងការប្រើប្រាស់គោលនយោបាយបន្ទាប់បន្សំ ក្នុងទម្រង់លើកទឹកចិត្តការប្រើកត្តាដែលសមស្រប ការវិនិយោគក្នុងស្រុក ភាពជាសហគ្រិន និងជំនាញក្នុងការចាប់យកទីផ្សារ ជាបញ្ហាសំខាន់ដើម្បីឈានទៅរកភាពជោគជ័យ។ សេដ្ឋកិច្ចទាំងនេះបានបន្តយុទ្ធសាស្ត្រកំណើនដែលមានមូលដ្ឋានយ៉ាងទូលាយលើការបង្កើតមុខរបរ ដែលគាំទ្រដោយយុទ្ធសាស្ត្រឧស្សាហនីយកម្មពឹងផ្អែកលើការនាំចេញ។ វិស័យនាំចេញនៅកម្ពុជា ដោយមានវត្តមានការវិនិយោគក្នុងស្រុក និងពលករមានជំនាញត្រូវការការបង្ហាញនូវភាពស្វាហាប់ខាងឧស្សាហនីយកម្មនោះ។

| | |
|---|---|
| បង្កើតការភ្ជាប់ភាពមុននិងក្រោយជាមួយនឹងវិសាលភាពសម្រាប់អ្នកផ្គត់ផ្គង់ក្នុងស្រុក ផ្តោតលើថ្លៃពលកម្មទាបនោះទេ | ការអភិវឌ្ឍឧស្សាហកម្ម ត្រូវការពិពិធកម្ម ដែលជំនួសមកវិញជាការចាំបាច់សម្រាប់ផលប័ត្រនាំចេញផ្សេងគ្នា។ ការយកចិត្តទុកដាក់ចំបង ត្រូវការជាចាំបាច់ដើម្បីលើកទឹកចិត្តសហគ្រិនក្នុងស្រុក និងជាពិសេស សហគ្រាសខ្នាតតូច និងមធ្យម។ សមាមាត្រខ្ពស់នៃពលករបរទេស ដែលមានស្រាប់នៅក្នុងការងារទទួលបានកម្រៃខ្ពស់នៅក្នុងឧស្សាហកម្មនាំចេញ ត្រូវយកមកពិចារណាតាមរយៈកម្មវិធីដែលសិក្សាបានម៉ត់ចត់ ដើម្បីបង្រៀនដល់ពលករខ្មែរអំពីជំនាញចំគោលដៅ។ ភាពប្រកួតប្រជែងនៃការនាំចេញរបស់ប្រទេសកម្ពុជា មិនចាំបាច់ស្ថិតនៅលើពលកម្មមានតម្លៃថោកទេ ប៉ុន្តែស្ថិតនៅលើការពង្រឹងផលិតភាព និងការប្រកួតប្រជែងពីជំនាញ ប្រសិនបើចំគោលដៅ។ ចំពោះសហគ្រាសខ្នាតតូចបំផុត និងមិនផ្លូវការ ប្រាក់កម្ចីរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ ត្រូវជួយលើកស្ទួយសហគ្រាស ហើយតម្រូវការផ្សេងៗ (ដូចជាការដាក់វត្ថុបញ្ចាំ) ត្រូវតែលុបចោល និងការទទួលបានឥណទាន បច្ចេកវិទ្យា និងវគ្គបណ្តុះបណ្តាលត្រូវមានការសម្របសម្រួល។ គោលនយោបាយជំនាញ ត្រូវគិតគូរបន្ថែមដល់ការកាត់បន្ថយការផ្គូផ្គងមិនស៊ីសង្វាក់នៅក្នុងទីផ្សារការងារ និងគាំទ្រយុវជន និងស្ត្រីឱ្យពង្រឹងភាពមានការងាររបស់ពួកគេ នៅក្នុងការងារដែលទទួលបានប្រាក់ឈ្នួលប្រសើរ។ |
| លិខិតុបករណ៍ (សារពើភណ្ឌ) ម៉ាក្រូសេដ្ឋកិច្ចអាចអនុវត្តបានចំពោះការសម្របសម្រួលការវិនិយោគក្នុងស្រុក | របាយការណ៍ប្រវត្តិរបស់ ILO បង្ហាញថាការបង្កើតមុខរបរ និង/ឬ កិច្ចគាំពារសង្គមមិនដើរតួយ៉ាងច្បាស់នៅក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចទេ។ ការប្រើប្រាស់លិខិតុបករណ៍បុរាណត្រូវបានហាមឃាត់ ហើយធនាគារជាតិបានកម្រិតពីជម្រើសធ្វើអន្តរាគមន៍។ ជាធម្មតាគម្លាសសារពើភណ្ឌ ត្រូវបានយកមកប្រើសម្រាប់ត្រួតពិនិត្យការវិនិយោគ និងការប្រើប្រាស់ ដើម្បីធ្វើឱ្យតម្លៃមានស្ថេរភាព។ របាយការណ៍ប្រវត្តិរបស់ ILO ស្នើឱ្យមានការប្រើប្រាស់ដោយប្រុងប្រយ័ត្ននូវគោលនយោបាយសារពើភណ្ឌសម្រាប់ពង្រីកហេដ្ឋារចនាសម្ព័ន្ធសង្គមកិច្ច និងរូបវ័ន្ត និងគោលនយោបាយរូបិយវត្ថុ/ឥណទានសមស្រប សម្រាប់ជំរុញការវិនិយោគ និងការបង្កើតមុខរបរ។ |

## ២.៥. កិច្ចគាំពារសង្គម

| | |
|---|---|
| ការចូលរួមសកម្មពីសំណាក់រដ្ឋាភិបាល ចាំបាច់ត្រូវមានក្នុងការបង្កើតក្របខណ្ឌសន្តិសុខសង្គមសម្រាប់ជនណាដែលមានមូលហេតុផ្សេងៗ ដូចជាមិនអាចធ្វើការបាន | អាទិភាពមួយនៅក្នុងន័យនេះ គឺត្រូវមានក្របខណ្ឌកិច្ចគាំពារសង្គមមួយដែលផ្តល់នូវការឧបត្ថម្ភជាសាច់ប្រាក់ ឬជាសម្ភារៈ ក្នុងអំឡុងពេលដែលប្រជាជនមិនអាចធ្វើការបន្ទាប់ពីចូលនិវត្តរួច ឬនៅពេលដែលការងារមិនផ្តល់ការលើកទឹកចិត្តគ្រប់គ្រាន់សម្រាប់និរន្តភាព។<br><br>សន្តិសុខសង្គម ត្រូវបានប្រកាសថាជាសិទ្ធិមនុស្សក្នុងលិខិតុបករណ៍ចំបងស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ ប៉ុន្តែនៅដើមសតវត្សទី ២១ ការទទួលបានទម្រង់ណាមួយនៃកិច្ចគាំពារសង្គមមិនត្រូវបានបង្កើតឡើងសម្រាប់ 80% នៃប្រជាជនទូទាំងពិភពលោក។ |

សន្តិសុខសង្គមដែលបានរៀបចំគឺជាឧបករណ៍ដ៏មានប្រសិទ្ធភាព និងអំណោយផលបំផុតក្នុងការកាត់បន្ថយវិសមភាពប្រាក់ចំណូល និងប្រឆាំងនឹងភាពក្រីក្រ សន្តិសុខសង្គម ជាកត្តាជោគជ័យដ៏សំខាន់សម្រាប់សេដ្ឋកិច្ចបើកចំហ

*កម្មវិធីឧបត្ថម្ភសង្គម មានប្រសិទ្ធភាពនៅក្នុងគោលដៅចំបងៗ៖* ក្នុងការបន្ថយវិសមភាពប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រ។ នៅពេលដែលចំណាយសង្គមមានកម្រិតខ្ពស់ នោះអត្រាក្រីក្រនឹងថយចុះ។ ភស្តុតាងរឹងមាំនៃបទពិសោធន៍វិជ្ជមាន បានពីប្រទេសដូចជាប្រេស៊ីល ម៉ូរីទូស ណាមីប៊ី អាហ្វ្រិកខាងត្បូង និងហ្សំប៊ី។

ភស្តុតាងដែលសំអាងលើពិសោធន៍នាពេលថ្មីៗនេះ បង្ហាញឱ្យឃើញថាបណ្តាប្រទេសនានាអាចផ្សះផ្សាការអនុវត្តម៉ាក្រូសេដ្ឋកិច្ចល្អ ជាមួយនឹងគំរូសង្គមកិច្ចដែលមាននិរន្តភាព។ លើសពីនេះគោលនយោបាយបើកទីផ្សារ មិនអាចទទួលបានជោគជ័យទេ ប្រសិនបើគ្មានការរៀបចំសង្គមឱ្យបានត្រឹមត្រូវ ដែលអាចសម្រួលផលវិបាកខាងសង្គមនៃគោលនយោបាយទីផ្សារដូចគ្នាទាំងនេះ។ ក្នុងវិស័យ OECD សេដ្ឋកិច្ចបើកចំហ ហាក់ដូចជាមានការរៀបចំរបស់រដ្ឋលើសុខមាលភាពទូលំទូលាយជាង។

វាអាចដើរតួជាកត្តាអំណោយផលមួយ

អ្វីដែលអនុវត្តចំពោះប្រទេសមានឧស្សាហកម្ម ក៏អាចអនុវត្តបានផងដែរចំពោះប្រទេសកំពុងអភិវឌ្ឍ ទោះបីស្ថិតក្នុងមាត្រដ្ឋានផ្សេងគ្នាក៏ដោយ។ ភាពមានសក្តានុពលនេះត្រូវបានចង្អុលបង្ហាញដោយភស្តុតាងជាច្រើន។ កម្មវិធីឧបត្ថម្ភជាប្រាក់ដែលមានលក្ខខណ្ឌជាមូលដ្ឋាន Opportunidades នៅប្រទេសម៉ិកស៊ិក កាត់បន្ថយថ្ងៃឈឺរបស់មនុស្សពេញវ័យនៅត្រឹម 19% ជាការជំរុញផលិតភាពចំបង។ កម្មវិធីរកប្រាក់ដើម្បីការអប់រំ នៅប្រទេសបង់ក្លាដេស បង្កើនចំណូលក្នុងមួយជីវិតរបស់អ្នកទទួលផលប្រយោជន៍ ចំនួន25% ដែលនេះជាការចង្អុលបង្ហាញពីការកើនឡើងផលិតភាព។

ដោយឡែក នៅពេលដែលវាសម្របសម្រួលការទទួលបានឥណទានសម្រាប់ជនក្រីក្រក្នុងការវិនិយោគទ្រព្យដែលអំណោយផល

ប្រទេសកំពុងអភិវឌ្ឍភាគច្រើនទទួលរងនូវទីផ្សារមូលធនមិនគ្រប់លក្ខណៈ ដែលបង្ការមិនឱ្យជនក្រីក្រខ្ចីបាន។ ទាំងនេះមានផលប៉ះពាល់យូរអង្វែង។ ធនាគារពិភពលោកបានរៀបរាប់ឧទាហរណ៍ជាច្រើនអំពីកង្វះធនធានសម្រាប់ជនក្រីក្រក្នុងការបង្កើត "អន្ទាក់វិសមភាព" -ដែលជា ស្ថានភាពនានាដែលសេដ្ឋកិច្ច វិសមភាពនយោបាយ និងសង្គម បង្កើតខ្លួនឯងមកវិញទៅតាមពេលវេលា និងឆ្លងជំនាន់។ អវត្តមានឥណទាន ត្រូវការការប្រើប្រាស់ នូវយន្តការរលូនដែលមិនមានប្រសិទ្ធភាព និងចំណាយអស់ច្រើន និងបង្អាក់ជនក្រីក្រក្នុងការវិនិយោគលើទ្រព្យសម្បត្តិដែលអំណោយផល ដូចជាការអប់រំ និងសុខភាព។ ជាឧទាហរណ៍ កម្មវិធីឧបត្ថម្ភជាប្រាក់នៅប្រទេសអេត្យូពី បង្កើនការទទួលបានសេវាកម្មសង្គម ការផ្ទេរសាច់ប្រាក់ច្រើនជាងមុន បង្កើនការប្រកួតប្រជែង និងពាណិជ្ជកម្មក្នុងស្រុក។ នៅប្រទេសប្រេស៊ីល ការណែនាំពីគម្រោងធានារ៉ាប់រងភាពគ្មានការងារ មានផលប៉ះពាល់គួរឱ្យកត់សម្គាល់ និងសំខាន់នាពេលអន្តរកាលក្នុងការមានការងារផ្ទាល់ខ្លួន - ការឧបត្ថម្ភប្រាក់ចំណូលផ្តល់នូវមូលធនដែលត្រូវការ និងជំនួសឱ្យការដើរតួជាការមិនលើកទឹកចិត្តឱ្យធ្វើការ ហើយមូលធនត្រូវបានប្រើសម្រាប់ចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ចផ្សេងៗ។ ហើយនេះក៏ជាអ្វីដែលកើតចេញពីការត្រួតពិនិត្យលើ កម្មវិធីកិច្ចគាំពារសង្គមមួយចំនួននៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប។ ភស្តុតាងមិនបានចង្អុលបង្ហាញពីផលប៉ះពាល់ផ្សេងនៃកម្មវិធីឧបត្ថម្ភសង្គមទាំងនេះទៅលើការលើកទឹកចិត្តក្នុងការងារទេ។

ការសិក្សាផ្សេងថ្មីៗនេះដែរ គាំទ្រភស្តុតាងស្តីពីឥទ្ធិពលវិជ្ជមាននៃការឧបត្ថម្ភប្រាក់ចំណូល នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងលក្ខខណ្ឌផលិតភាព និងកំណើន។ ដោយឡែកចំពោះការចូលរៀនដែលមានការកើនឡើង និងការលើកកម្ពស់លក្ខខណ្ឌសុខភាព ក៏មានភស្តុតាងរឹងមាំអំពីផលប៉ះពាល់នៃកម្មវិធីឧបត្ថម្ភជាប្រាក់នៅក្នុងប្រទេសផ្សេងៗគ្នា។

ការសិក្សាមួយចំនួនដែលសំអាងលើពិសោធន៍ លើប្រទេសអាហ្វ្រិកខាងត្បូង ផ្តល់នូវភស្តុតាងថាការចំណាយជាជំនួយដល់សង្គម បានជំរុញការវិនិយោគ កំណើនសេដ្ឋកិច្ច និងការបង្កើតការងារ ហើយថាចំណាយទាំងនេះបានបង្កើនសមតុល្យពាណិជ្ជកម្ម។ គ្រួសារដែលមានចំណូលទាប ចំណាយជាច្រើនទៅលើទំនិញ និងសេវាកម្មក្នុងស្រុក ដូចនេះការកើនឡើងចំណូលរបស់ពួកគាត់ហាក់ដូចជាទំនោរទៅរកឧស្សាហកម្មក្នុងស្រុក។ លើសពីនេះ ក៏មានផលប៉ះពាល់លើការអប់រំ ជាពិសេសការអប់រំដល់កុមារី។ ទាំងនេះនាំឱ្យមានកម្លាំងពលកម្មច្រើនជាងមុន និងអត្រាកំណើន GDP ខ្ពស់ជាងមុន។

**ការសិក្សាពាក់ព័ន្ធដល់ការជៀសវាងនូវលក្ខណៈសេដ្ឋកិច្ចអវិជ្ជមាន និងខ្វះខ្វាយធនធានសាធារណៈ**

ជាការពិតណាស់ ការសិក្សាជាការសំខាន់។ គម្រោងពន្ធដារ និងផលប្រយោជន៍មានផលប៉ះពាល់ដល់ទម្រង់លើកទឹកចិត្តខាងសេដ្ឋកិច្ច។ ទាំងនេះសំដៅកាត់បន្ថយផលប៉ះពាល់រយៈពេលខ្លីដែលធ្វើឱ្យខូចប្រយោជន៍ ទៅលើទម្រង់លើកទឹកចិត្ត និងពង្រីកផលប៉ះពាល់ដែលមានរយៈពេលវែងក្នុងលក្ខខណ្ឌវិនិយោគក្នុងសេដ្ឋកិច្ចដែលស្ថិតស្ថេរបានយូរ និងក្នុងធនធានមនុស្ស។ នេះជាអ្វីដែលមានន័យជាមួយនឹង "ការបង្កើតវដ្តដែលប្រកបដោយគុណធម៌"។កម្មវិធីកិច្ចគាំពារសង្គម ត្រូវតែមានប្រសិទ្ធភាព ប៉ុន្តែនៅពេលដែលវាមានប្រសិទ្ធភាព វាក៏ត្រូវអាចទទួលយកបានផងដែរ។ ILO បានធ្វើការសិក្សាជាច្រើន ដែលបានបង្ហាញដោយសង្ខេបថាប្រទេសកំពុងអភិវឌ្ឍន៍អាចអនុវត្តសន្តិសុខសង្គមក្នុងកម្រិតមូលដ្ឋានមួយ។ នៅបណ្តាប្រទេសភាគច្រើន ផលប្រយោជន៍នោះមានតម្លៃពីចន្លោះ 1-2% នៃ GDP ឬ 5-10% នៃថវិកាជាតិ។ ការអនុវត្តផលប្រយោជន៍នេះ អាចជាជំហានលឿនដំបូងក្នុងការកំចាត់ភាពក្រីក្រដ៏រ៉ាំរ៉ៃនៅក្នុងប្រទេសទាំងនោះ។ ឧទាហរណ៍ដូចជា ការអនុវត្តដូចគ្នាមួយរបស់ ILO បានបង្ហាញឱ្យឃើញថា សូម្បីតែប្រាក់សោធននិវត្តន៍សកលលោកដែលសមរម្យមួយ ក៏មានតម្លៃប្រហែល 1% នៃ GDP ដែរ ដែលនេះអាចកាត់បន្ថយគម្លាតក្រីក្រនៅក្នុងប្រទេសសេណេហ្គាល និងសាធារណៈរដ្ឋតាន់ហ្សាណា ច្រើនជាង 20% ។ ដូចគ្នានេះដែរ គម្រោងឧបត្ថម្ភជាប្រាក់សង្គម នៅក្នុងសង្កាត់មួយនៃប្រទេស ហ្សំប៊ី ដែលបានចាប់ផ្តើមនៅឆ្នាំ ២០០៣ ហើយបានឆ្លុះបញ្ចាំងថាអាចទទួលយកអនុវត្តបាន។

**កសាងមូលធនសង្គមត្រូវការពេលវេលាយូរ**

ផលវិបាកនៃការមិនយកចិត្តទុកដាក់នឹងការភ្ជាប់កំណើនសេដ្ឋកិច្ច និងចំណាយទៅលើកម្មវិធីសង្គម (ដូចជាការអប់រំ និងការថែទាំសុខភាព) អាចនៅតែលាក់កំបាំងជាយូរទៀត។ ប៉ុន្តែលទ្ធផលនៃការខ្វះការវិនិយោគរយៈពេលវែង ជាលទ្ធផលរយៈពេល

វែង ហើយមិនអាចធ្វើទៅបានក្នុងរយៈពេល មួយ ឬពីរទសវត្សទេ។ វាត្រូវការច្រើនជំនាន់ក្នុងការកសាងមូលធនបញ្ញាវន្ត និងសង្គម ដែលជាតម្រូវការសម្រាប់កម្លាំងពលកម្មដែលអំណោយផល។ កុមារដែលមិនអនុញ្ញាតឱ្យចូលសាលាដោយសារតែពួកគេមានការងារធ្វើ ត្រូវការជាចាំបាច់ក្នុងការបំពេញគម្លាតក្នុងការរកប្រាក់ចំណូលដើម្បីគ្រួសារ ពួកគេក្លាយជាពលករដែលមានប្រយោជន៍នៅក្នុងភាពពេញវ័យរបស់ពួកគេ និងមិនអាចរកបានចំណូលគ្រប់គ្រាន់សម្រាប់គ្រួសារ។ ហើយកុមារដែលកើតឡើងក្នុងភាពអត់ឃ្លាន នឹងមិនអភិវឌ្ឍសមត្ថភាពបញ្ញាដែលអាចឱ្យពួកគេជួយអភិវឌ្ឍសង្គមនៅក្នុងអាយុវ័យក្មេងនោះទេ - ដូចនេះវដ្តនេះនៅតែជាបញ្ហាដដែល។

ធនាគារពិភពលោកបានដាក់ឈ្មោះឱ្យវដ្តនេះថាជា "អន្ទាក់វិសមភាព"។ វដ្តនេះសំដៅដល់វិសមភាពដែលមានរហូតពីមួយជំនាន់ទៅមួយជំនាន់។ ឧទាហរណ៍ដូចជានៅប្រទេសកំពុងអភិវឌ្ឍន៍រួមមានពិន្ទុប្រលងរបស់កុមារនៅប្រទេសអេក្វាដ័រៈ នៅអាយុ ៣ ឆ្នាំ គ្មានភាពខុសគ្នាខាងប្រព័ន្ធនៃពិន្ទុរវាងកុមារដែលមកពីគ្រួសារដែលមានប្រាក់ចំណូលទាប និងកុមារដែលមកពីគ្រួសារដែលមានប្រាក់ចំណូលខ្ពស់ទេ។ ប៉ុន្តែនៅអាយុ ៦ ឆ្នាំ ភាពខុសគ្នានៃពិន្ទុប្រលងបែរមានទំហំធំ ដែលកុមារមានប្រាក់ចំណូលទាបមិនអាចគ្រប់គ្រងក្នុងការបិទចន្លោះបានទេ នៅក្នុងមួយជីវិតរបស់ពួកគេ។

## ២.៦. កិច្ចគាំពារសង្គមមូលដ្ឋាន

កិច្ចគាំពារសង្គមមូលដ្ឋាន

នៅឆ្នាំ ២០០៤ គណៈកម្មការពិភពលោកស្តីពីទិដ្ឋភាពសង្គមនៃសកលភាវូបនីយកម្មបានសន្និដ្ឋានថា "កម្រិតអប្បបរមាជាក់លាក់មួយនៃកិច្ចគាំពារសង្គមសម្រាប់បុគ្គល និងគ្រួសារ ត្រូវការការទទួលស្គាល់ និងមិនអាចប្រកែកបានថាជាផ្នែកនៃមូលដ្ឋានសង្គម និងសេដ្ឋកិច្ចនៃសេដ្ឋកិច្ចពិភពលោក"។ គណៈកម្មការបានស្នើសុំការព្រមព្រៀងជាសកលក្នុងការដោះស្រាយនូវភាពអសុវត្ថិភាពផ្នែកសង្គម និងសេដ្ឋកិច្ច ដែលជាលក្ខខណ្ឌចាំបាច់ក្នុងការផ្តល់នូវភាពស្របច្បាប់ដល់ដំណើរការសកលភាវូបនីយកម្ម។ អនុសាសន៍នេះ សម្រាប់ការខំប្រឹងប្រែងរបស់ ILO ក្នុងការលើកកម្ពស់វិសាលភាពកិច្ចគាំពារសង្គមសម្រាប់ទាំងអស់គ្នា ដោយសារតែវាជាគោលដៅយុទ្ធសាស្រ្តមួយនៃរបៀបវារៈការងារសមរម្យ ដូចបានកំណត់នៅក្នុងសេចក្តីប្រកាសរបស់ ILO ស្តីពីយុត្តិធម៌សង្គមសម្រាប់សកលភាវូបនីយកម្មត្រឹមត្រូវ។ ដោយឡែក វាសំដៅដល់ការរៀបចំយុទ្ធនាការសកលស្តីពីសន្តិសុខសង្គម និងវិសាលភាពសម្រាប់ទាំងអស់គ្នា ដែលបានផ្សព្វផ្សាយនៅកិច្ចប្រជុំលើកទី ៩១ នៃសន្និសីទពលកម្មអន្តរជាតិនាឆ្នាំ ២០០៣ ដើម្បីលើកកម្ពស់វិសាលភាពនៃសន្តិសុខសង្គម។

ប៉ុន្មានឆ្នាំកន្លងមកនេះ វិបត្តិសេដ្ឋកិច្ចបានឆ្លុះបញ្ចាំងឱ្យឃើញពីភាពសំខាន់នៃវឌ្ឍនភាពខាងរចនាសម្ព័ន្ធពាក់ព័ន្ធនឹងការពង្រីកកិច្ចគាំពារសង្គមនៅក្នុងលក្ខខណ្ឌជាប់ទំនាក់ទំនងគ្នា ដោយអនុវត្តសំណើរបស់គណៈកម្មការពិភពលោកអំពីកិច្ចគាំពារសង្គមមូលដ្ឋាន។ ការវាស់វែងកិច្ចគាំពារសង្គម បានបម្រើជាអ្នកធ្វើឱ្យមានស្ថេរភាព

ម៉ាក្រូសេដ្ឋកិច្ច ដើម្បីសម្រាលផលប៉ះពាល់នៃវិបត្តិដល់ប្រជាជនទន្ទឹមនឹងការថែរក្សានូវតម្រូវការសរុប និងធ្វើឱ្យប្រជាជនឆ្លងផុតពីភាពក្រីក្រ និងការបដិសេធចេញពីសង្គម ក៏ដូចជាការស្វែងរកការងារសមរម្យ។

ដោយមានការទទួលស្គាល់ពីភាពសំខាន់នៃការធានាកិច្ចគាំពារសង្គមសម្រាប់ទាំងអស់គ្នា ប្រព័ន្ធប្រធានក្រុមប្រឹក្សាប្រតិបត្តិសម្រាប់ការសម្របសម្រួលរបស់អង្គការសហប្រជាជាតិ (CEB) បានអនុម័តកាលពីខែ មេសា ឆ្នាំ ២០០៩ នូវគំនិតផ្តួចផ្តើមកិច្ចគាំពារសង្គមមូលដ្ឋាន ដែលជាគំនិតផ្តួចផ្តើមមួយក្នុងចំណោមគំនិតផ្តួចផ្តើមរួមទាំង ៩ របស់អង្គការសហប្រជាជាតិ ក្នុងការដោះស្រាយនូវឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ច។

Global Jobs Pact អនុម័តដោយសន្និសិទពលកម្មអន្តរជាតិនៅក្នុងកិច្ចប្រជុំលើកទី ៩៨ កាលពីឆ្នាំ ២០០៩ និងធ្វើតាមសំណើឡើងវិញក្នុងការកសាងកិច្ចគាំពារសង្គមឱ្យបានគ្រប់គ្រាន់សម្រាប់ទាំងអស់គ្នា ដោយផ្តោតលើកិច្ចគាំពារសង្គមមូលដ្ឋានដើម្បី "អនុវត្តប្រព័ន្ធកិច្ចគាំពារសង្គមដែលមាននិរន្តរភាពក្នុងការជួយដល់ជនងាយរងគ្រោះ (និង) បង្ការការកើនឡើងនូវភាពក្រីក្រ ដោះស្រាយភាពលំបាកនៅក្នុងសង្គម ក្នុងខណៈដែលជួយធ្វើឱ្យមានស្ថេរភាពដល់សេដ្ឋកិច្ច និងរក្សា និងលើកកម្ពស់ភាពមានការងារធ្វើ"។ សេចក្តីសម្រេច និងសេចក្តីសន្និដ្ឋានស្តីពីកិច្ចគាំពារសង្គម (សុវត្ថិភាពសង្គម) អនុម័តដោយប្រតិភូត្រីភាគីតំណាងនៅសន្និសិទពលកម្មអន្តរជាតិឆ្នាំ ២០១១ ព្រមព្រៀងលើយុទ្ធសាស្ត្រទិស២ ដើម្បីពង្រីកវិសាលភាពសុវត្ថិភាពសង្គម និងយល់ព្រមលើតម្រូវការក្នុងការពិភាក្សាពីអនុសាសន៍ស្តីពីកិច្ចគាំពារសង្គមមូលដ្ឋាននៅក្នុងសន្និសិទពលកម្មអន្តរជាតិឆ្នាំ ២០១២។

ក្នុងអំឡុងឆ្នាំចុងក្រោយនេះ អភិក្រមកិច្ចគាំពារសង្គមមូលដ្ឋានទទួលបានការទទួលស្គាល់យ៉ាងទូលំទូលាយ រួមទាំងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDG) និងកិច្ចប្រជុំកំពូល G20។ កិច្ចគាំពារសង្គមមូលដ្ឋានត្រូវបានទទួលស្គាល់ជាឧបករណ៍គោលនយោបាយសង្គមស្នូលក្នុងការឆ្លើយតបទៅនឹងវិបត្តិសេដ្ឋកិច្ច និងបង្កើនល្បឿនការទទួលបានមកវិញ និងក៏ជាផ្នែកនៃយុទ្ធសាស្ត្រដែលផ្តោតលើមនុស្ស និងការអភិវឌ្ឍរួមបញ្ចូល។ ដូចដែលបានកំណត់ដោយ លោក Juan Somavia នាយកចាត់ការទូទៅនៃអង្គការ ILO ក្នុងឱកាសថ្ងៃយុត្តិធម៌សង្គមពិភពលោក ឆ្នាំ ២០១១ (ថ្ងៃទី ១៧ ខែមករា) វិសាលភាពនៃ "កិច្ចគាំពារសង្គមដែលមាននិរន្តរភាពជាប្រចាំឆ្នាំ ដល់ប្រជាជនចំនួន ៨ នាក់ក្នុងចំណោម ១០នាក់ ដែលខ្វះការទទួលបានទម្រង់ណាមួយនៃសន្តិសុខសង្គមនៅក្នុងពិភពលោកនាថ្ងៃនេះ រាប់ចាប់ពីថ្នាក់មូលដ្ឋាននៃកិច្ចគាំពារសង្គមជាសកល" ជាជំហានចាំបាច់ក្នុងការ "បន្តយុគសម័យថ្មីនៃយុត្តិធម៌សង្គម"។

សញ្ញាណនៃកិច្ចគាំពារសង្គមមូលដ្ឋាន ត្រូវបានកំណត់នៅក្នុងគោលការណ៍បែងចែកនៃយុត្តិធម៌សង្គម និងនៅក្នុងសេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្សដើម្បីស្វែងរកស្តង់ដារជីវិតត្រឹមត្រូវ ការទទួលបានការថែរក្សាសុខភាព ការអប់រំ ចំណីអាហារ ការមានផ្ទះ និងសុវត្ថិភាពសង្គម។ គំនិតស្នូល គឺគ្មាននរណាម្នាក់ត្រូវរស់នៅទាបជាង

កម្រិតប្រាក់ចំណូលជាកលាក់ណាមួយទេ ហើយមនុស្សគ្រប់រូបត្រូវអាចទទួលបាន យ៉ាងហោចណាស់នូវសេវាកម្មសង្គមមូលដ្ឋាន ក្នុងការពង្រឹងនូវឱកាសការងារសមរម្យ។

កិច្ចគាំពារសង្គមមូលដ្ឋាន ដូចបានកំណត់ដោយអង្គការសហប្រជាជាតិ ជាគោលនយោបាយសង្គមដែលរួមបញ្ចូលគ្នាមួយ រៀបចំឡើងដើម្បីធានាសុវត្ថិភាពប្រាក់ចំណូល និងទទួលបានសេវាកម្មសង្គមសម្រាប់អ្នកទាំងអស់គ្នា ដោយផ្តោតការយកចិត្តទុកដាក់ទៅលើក្រុមជនងាយរងគ្រោះ។ កិច្ចគាំពារសង្គមមូលដ្ឋានរួមមានការធានានូវ៖
(ក) សុវត្ថិភាពប្រាក់ចំណូលមូលដ្ឋាន ក្នុងទម្រង់ជាការឧបត្ថម្ភសង្គមជាច្រើន (ជាប្រាក់ ឬជាសម្ភារ:) ដូចជាប្រាក់សោធននិវត្តន៍សម្រាប់ចាស់ជរា និងជនពិការ ផលប្រយោជន៍កុមារ ផលប្រយោជន៍គាំទ្រប្រាក់ចំណូល និង/ឬ ការធានាការមានការងារ និងសេវាកម្មសម្រាប់ភាពគ្មានការងារ និងខ្វះការងារ និង
(ខ) ការដែលអាចរកបាន និងការទទួលបានសេវាកម្មសង្គមសំខាន់ៗ នៅក្នុងវិស័យសុខាភិបាល ទឹក និងអនាម័យ ការអប់រំ សុវត្ថិភាពចំណីអាហារ ទីលំនៅ និងផ្សេងទៀតដែលបានកំណត់ដោយអនុលោមតាមអាទិភាពថ្នាក់ជាតិ។

កិច្ចគាំពារសង្គមមូលដ្ឋាន ទាមទារនូវការភ្ជាប់ទំនាក់ទំនងគោលនយោបាយ និងការសម្របសម្រួលនៅក្នុងគោលនយោបាយសង្គមផ្សេងៗ ដើម្បីបង្ការបុគ្គល និងគ្រួសារគេពីការធ្លាក់ក្នុងភាពក្រីក្រ និងភាពខ្វះខាត។ វាក៏សំដៅការពារអ្នកទាំងនោះដែលមិនអាចរកចំណូលសមរម្យតាមរយៈការធ្វើការងារ និងផ្តល់អំណាចដល់ពលករក្នុងការចាប់យកឱកាសសេដ្ឋកិច្ច និងរកផ្លូវចេញពីភាពក្រីក្រ។

នេះជាអភិក្រមវដ្តជីវិតរួមមានការអភិវឌ្ឍធនធានមនុស្សដែលរួមបញ្ចូលក្នុងកម្មវិធីសម្រាប់កុមារងាយរងគ្រោះ និងគ្រួសាររបស់ពួកគេ ជនក្រីក្រខ្វះការងារធ្វើ និងជនក្រីក្រដែលប្រកបការងារ ចាស់ជរា និងជនពិការ។ នេះជាក្របខណ្ឌសម្រាប់ការធ្វើអន្តរាគមន៍សាធារណៈដែលសម្របសម្រួលនៅក្នុងកម្រិតគ្រួសារ សំដៅដល់មូលហេតុក្រីក្រគ្រប់ជ្រុង និងការមិនបញ្ចូលក្នុងសង្គម និងសំដៅដោះស្រាយសមត្ថភាពអំណោយផល។ ការយកចិត្តទុកដាក់ដោយឡែក ផ្តោតទៅលើការផ្តល់អំណាចដល់យេនឌ័រ ដោយសារតែស្ត្រីត្រូវបានផ្តល់ការទុកចិត្តលើតួនាទីធំដុំនៅក្នុងគ្រួសារ ថាជាផ្នែកមួយនៃគម្រោងការណ៍ឧបត្ថម្ភប្រាក់ចំណូល និងសេវាកម្មសង្គម។

នៅពេលដែលអនុម័តជាគោលគំនិតសកល កិច្ចគាំពារសង្គមមូលដ្ឋានត្រូវបានកំណត់ជាថ្នាក់ជាតិនៅក្នុងក្របខណ្ឌរចនាសម្ព័ន្ធស្ថាប័នថ្នាក់ជាតិ ឧបសគ្គសេដ្ឋកិច្ច ភាពស្វាហាប់ខាងនយោបាយ និងសេចក្តីប៉ងប្រាថ្នាខាងសង្គម។ ដំណើរការអនុវត្តទាំងនេះ ជាធម្មតានឹងវិវត្តឡើង និងជាបណ្តើរៗ ដោយអនុលោមតាមអាទិភាព និងសមត្ថភាពថ្នាក់ជាតិ ដោយកសាងទៅគម្រោងការណ៍កិច្ចគាំពារសង្គមដែលមានស្រាប់ និងផ្អែកទៅលើប្រភពផ្តល់មូលនិធិដែលមាននិរន្តភាព។

កិច្ចគាំពារសង្គមមូលដ្ឋាន ត្រូវបានគេស្គាល់ថាជាជំហានដំបូងនៃកម្រិតកិច្ចគាំពារខ្ពស់ជាង។ ដោយសារតែសេដ្ឋកិច្ចកើនឡើង និងចន្លោះហិរញ្ញវត្ថុ និងសារពើភណ្ឌរីកធំឡើង ការពង្រីកបន្ថែមនៅក្នុងកម្រិតកិច្ចគាំពារ ត្រូវយកមកពិចារណា។ ក្នុងបណ្ដាប្រទេសដែលមានការយល់ដឹងរួចហើយ ប៉ុន្តែខណ្ឌជាផ្នែកនូវប្រព័ន្ធកិច្ចគាំពារសង្គមអភិក្រមកិច្ចគាំពារសង្គមមូលដ្ឋាន មិនត្រូវបានមើលឃើញថាជាវិធីមួយធ្វើឱ្យកម្រិតគាំពារចុះអន់ខ្សោយ ប៉ុន្តែដោយសារជាផ្នែកនៃដំណើរការបំពេញនូវគម្លាតវិសាលភាពចុងក្រោយ និងជំរុញការទំនាក់ទំនងគោលនយោបាយ ក្នុងចំណោមគោលនយោបាយសង្គមដទៃទៀត។

ប្រទេសដែលមានប្រាក់ចំណូលមធ្យម និងទាបច្រើនជាង ៣០ ប្រទេស បានអនុវត្តវិធានការនានាបានយ៉ាងជោគជ័យ ក្នុងការណែនាំពីធាតុផ្សំនៃកិច្ចគាំពារសង្គមមូលដ្ឋានថ្នាក់ជាតិ។ បទពិសោធន៍របស់ប្រទេសទាំងនោះ បានបង្ហាញឱ្យឃើញថាគម្រោងការណ៍សុវត្ថិភាពសង្គមជាឧបករណ៍គោលនយោបាយចាំបាច់ និងបត់បែនក្នុងការទប់ស្កាត់ និងបន្ធូរផលវិបាកសង្គម និងសេដ្ឋកិច្ចបណ្ដាលមកពីវិបត្តិហិរញ្ញវត្ថុ។ បទពិសោធន៍ទាំងនេះក៏បានចង្អុលបង្ហាញពីភាពអាចធ្វើទៅបាននៃការកសាងកិច្ចគាំពារសង្គមមូលដ្ឋាន ដោយបង្ហាញថាជាមួយនឹងឆន្ទៈនយោបាយចាំបាច់ ធនធានគ្រប់គ្រាន់សម្រាប់កសាងសមត្ថភាព និងដំណើរការអនុវត្តល្អមួយ ការព្រមព្រៀងខ្លាំងក្លាថ្នាក់ជាតិទំនោរទៅលើគោលនយោបាយកិច្ចគាំពារសង្គមមូលដ្ឋានអាចត្រូវបានបង្កើតឡើង និងអភិវឌ្ឍ។

### ២.៧. មាតិកាអំពីយុទ្ធសាស្ត្ររួមបញ្ចូលមុខរបរ និងកិច្ចគាំពារសង្គម

នាំមកនូវធាតុផ្សំទាំងអស់ចូលគ្នា

នៅចុងបញ្ចប់នៃជំពូកនេះ មានការណែនាំពីសេចក្ដីសង្ខេបដែលបានរៀបរាប់កន្លងមក។ ស្តង់ដារការងារខ្ពស់ និងការអភិវឌ្ឍសេដ្ឋកិច្ចល្អ ជាការបំពេញបន្ថែម មិនមែនជាអ្វីផ្សេងនោះទេ។ បន្ថែមពីលើនេះ ការឧបត្ថម្ភសង្គមមានប្រសិទ្ធភាពជាដំបូងដោយសំដៅ៖ កាត់បន្ថយចំនួនប្រជាជនក្រីក្រ។ ទន្ទឹមនឹងនោះ គ្មានការផ្លាស់ប្តូរដោយស្វ័យប្រវត្តិណារវាងសមភាព និងប្រសិទ្ធភាព នៅពេលដែលនិយាយពីកិច្ចគាំពារសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចទេ។ កិច្ចគាំពារសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចអាចត្រូវបានផ្សះផ្សា ហើយកម្មវិធីគាំពារសង្គម អាចអនុវត្តទៅបានប្រសិនបើសិក្សា និងគ្រប់គ្រងបានល្អ។ ផលប្រយោជន៍សុវត្ថិភាពសង្គមសកម្ម ដែលជៀសវាងឥទ្ធិពលលើកទឹកចិត្តអវិជ្ជមាននៃសុវត្ថិភាពសង្គម "សកម្ម ឡើងវិញ" អាចជំរុញកំណើនសេដ្ឋកិច្ចរយៈពេលវែង ដោយការវិនិយោគសមត្ថភាពធនធានមនុស្សដែលអំណោយផល និងសម្របសម្រួលការកែតម្រូវទីផ្សារចាំបាច់។ ជាលទ្ធផល អក្សរសិល្ប៍ថ្មីៗចង្អុលបង្ហាញពីផលប៉ះពាល់សេដ្ឋកិច្ចជាវិជ្ជមាននៃកិច្ចគាំពារសង្គម។

| | |
|---|---|
| ធាតុផ្សំដែលអាចត្រូវរាប់បញ្ចូលក្នុងគំរូសង្គមណាមួយ | សូម្បីតែគំរូសង្គមមួយក៏គ្មានដែរ។ បណ្ដាប្រទេសនានាមានសេរីភាពក្នុងការជ្រើសរើសផ្លូវដើរដោយខ្លួនឯង។ ប៉ុន្តែធាតុផ្សំខ្លះហាក់ដូចជាសំខាន់ និងជាសកលគ្រប់គ្រាន់សម្រាប់រៀបរាប់ដូចខាងក្រោមៈ |

- ការវិនិយោគលើធនធានមនុស្ស
  - ចាប់ផ្ដើមពីការឱ្យកុមារចូលសាលារៀន ដោយច្បាស់ថាលោកគ្រូ/អ្នកគ្រូមានវត្តមាន និងមានសមត្ថភាព។ នេះក៏រួមបញ្ចូលនូវការធានាថាសមភាពយេនឌ័រក្នុងការអប់រំត្រូវមានភាពស្មើគ្នា។ ហើយក៏រួមបញ្ចូលនូវសម្បទាសម្រាប់ការធ្វើការដែលអាចឱ្យប្រជាជនរក្សាបាន និងបង្កើនជំនាញរបស់ពួកគេ។
- ណែនាំពីការរៀបចំស្ថាប័នស្ដីពីទីផ្សារការងារ ដែលកាត់បន្ថយភាពគ្មានប្រសិទ្ធភាព និងការខ្វះការប្រើប្រាស់ធនធានអំណោយផល
  - នេះអាចរួមបញ្ចូលការរកឃើញជម្រើសផ្សេងសម្រាប់ច្បាប់ការពារដ៏តឹងតែង ដែលអាចពិបាកក្នុងការបណ្ដេញពីការងារ និង - ជាផលវិបាកដែលមិនបានគ្រោងទុក- រារាំងមិនឱ្យក្រុមហ៊ុនរើសបុគ្គលិក
- ធានាអន្តរកាលទីផ្សារការងារ
  - ឧទាហរណ៍ តាមរយៈគោលនយោបាយទីផ្សារការងារសកម្ម និងគម្រោងការណ៍កិច្ចគាំពារសង្គមដែលអនុញ្ញាតឱ្យមានការស្វែងរកការងារក្នុងរយៈពេលកំណត់មួយ
- បង្កើតឱ្យមានក្រុមដែលមិនចូលរួម
  - ជាទូទៅនៅក្នុងការងារដែលមានប្រាក់ឈ្នួល។ ទាំងនេះនាំឱ្យមានការរួមបញ្ចូលនៅក្នុងសង្គម និងផ្ដល់នូវឱកាសសម្រាប់ទទួលបានជំនាញ និងការឈានមុខផ្នែកសេដ្ឋកិច្ច
- ផ្ដល់នូវការឧបត្ថម្ភប្រាក់ចំណូលសម្រាប់អ្នកដែលមិនអាចចូលរួមក្នុងមូលដ្ឋានអចិន្ត្រៃយ៍
  - ដំបូងបំផុតជាអាជ្ញាបញ្ញាប្រកបដោយគុណធម៌ ដោយសារតែវាប្រឆាំងនឹងការមិនរួមបញ្ចូលក្នុងសង្គម។ វាក៏អាចជៀសវាងនូវឥទ្ធិពលឃាំងទុកនៃសេដ្ឋកិច្ចដែលរារាំងការអនុវត្តដោយរលូននៃទីផ្សារការងារ
- ភ្ជាប់គោលដៅសង្គមទៅក្នុងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចទូលំទូលាយ
  - រួមបញ្ចូលការប្រើប្រាស់ឧបករណ៍សារពើពន្ធ ដូចជាការបន្ធូរបន្ថយពន្ធ ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចដូចជាកសិកម្ម និងវិស័យឧស្សាហកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលបានគិតគូរបានល្អ
- បង្កើតក្របខណ្ឌសម្រាប់អភិបាលកិច្ចល្អដោយត្រួតពិនិត្យ និងថ្លឹងថ្លែងត្រឹមត្រូវ និងវេទិកាសម្រាប់កិច្ចពិភាក្សាសង្គម

- ធានាថាផលប្រយោជន៍នៃក្រុមកំពូលៗត្រូវបានត្រួតពិនិត្យ ហើយក្រុមផ្សេងទៀតត្រូវបានឱ្យបញ្ចេញមតិ។

ដើម្បីអនុវត្តទៅវិញទៅមក ធាតុផ្សំនៃការងារសមរម្យ និងយុទ្ធសាស្ត្រគាំពារសង្គម ដែលមានលំនឹង សំដៅដល់កំណើនសេដ្ឋកិច្ច ភាពមានការពេញលេញ និងអំណោយផល និងកិច្ចគាំពារសង្គមជាសកល។ យុទ្ធសាស្ត្រនេះពាក់ព័ន្ធ និងមានសុពលភាពសម្រាប់ប្រទេសឧស្សាហកម្ម ក៏ដូចជាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ។ វាអាចត្រូវបានកំណត់សម្រាប់ស្ថានភាព និងតម្រូវការជាក់លាក់នៃប្រទេសទាំងនោះ។ របាយការណ៍នេះនឹងប្រើក្របខណ្ឌនេះសម្រាប់វាយតម្លៃពីអ្វីដែលជំហានបន្ទាប់អាចមានក្នុងករណីដូចជាប្រទេសកម្ពុជា។

ជំពូកបន្ទាប់នឹងបង្ហាញពីយុទ្ធសាស្ត្រជាតិគាំពារសង្គម ដែលបានបង្កើតឡើង និងវាយតម្លៃពីវិសាលភាពដែលយុទ្ធសាស្ត្រជាតិស្តីពីមុខរបរអាចបំពេញ និងពង្រឹងបន្ថែមលើដំណើរការដែលរាជរដ្ឋាភិបាលបានផ្តោតទៅលើ។

## ជំពូកទី ៣៖ គំនិតផ្តួចផ្តើមកំពុងបន្តរបស់រាជរដ្ឋាភិបាលកម្ពុជា

### ៣.១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ និងយុទ្ធសាស្ត្រចតុកោណ

យុទ្ធសាស្ត្រចតុកោណ

យុទ្ធសាស្ត្រចតុកោណសម្រាប់កំណើន ភាពមានការងារ សមភាព និងដំណាក់ កាលមានប្រសិទ្ធភាពលើកទី ២ រួមមាន "របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច" នៃ "វេទិកានយោបាយ" របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី ៤ (២០០៨-២០១៣)។ រូបភាពទី ៣.១. បង្ហាញពីកំណែសាមញ្ញនៃយុទ្ធសាស្ត្រចតុកោណ។

**រូបភាពទី ៣.១. យុទ្ធសាស្ត្រចតុកោណ**




ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ជាឧបករណ៍អនុវត្តឬផែនទីគោចរសម្រាប់អនុវត្តអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី ៤ ដូចបានបង្ហាញនៅក្នុងយុទ្ធសាស្ត្រចតុកោណ។ យុទ្ធសាស្ត្រនេះបង្ហាញពីតួអង្គ (នរណាដែលទទួលខុសត្រូវ) សកម្មភាព (អ្វីដែលត្រូវធ្វើ) និងការចំណាយ (តើគោលដៅទាំងអស់នឹងត្រូវសម្រេចបានយ៉ាងដូចម្តេច) ហើយសំដៅធានាថាសកម្មភាពរាប់ពីខាងក្រោមឡើងទៅលើដែលបានពីក្រសួង និងដៃគូផ្សេងៗគ្នា មានសង្គតភាពជាមួយនឹងអាទិភាពរាប់ពីខាងលើមកក្រោម និងក្របខណ្ឌហិរញ្ញវត្ថុ។ ស្របតាម "ក្របខណ្ឌចតុកោណ" ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ រៀបរាប់ដោយប្រព័ន្ធពីជោគជ័យរបស់រាជរដ្ឋាភិបាលក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ និងគោលដៅសម្រាប់អាណត្តិបច្ចុប្បន្ន។ ចំណុចសំខាន់នៃយុទ្ធសាស្ត្រចតុកោណ រួមមានវិធានការក្នុងការលើកកម្ពស់ (i) របបអភិបាលកិច្ច និង(ii) ការឆ្លើយតបទៅនឹងហិរញ្ញ

វត្ថុសាធារណៈ ចំពោះបរិយាកាស ម៉ាក្រូសេដ្ឋកិច្ច។ បន្ទាប់មកទៀត ជ្រុងទាំង ៤ នៃយុទ្ធសាស្ត្រចតុកោណ ជាអាទិភាព អភិវឌ្ឍន៍សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ដោយកំណត់នូវៈ វិស័យកសិកម្ម ហេដ្ឋា រចនាសម្ព័ន្ធ វិស័យឯកជន និងការអភិវឌ្ឍធនធានមនុស្ស។ ដោយគ្មានមហិច្ឆតាហាត់ នឿយក្នុងការរៀបរាប់ពីវិធានការទាំងអស់ ធាតុផ្សំមួយចំនួនដែលពាក់ព័ន្ធនឹង ឯកសារនេះ (ដោយសារតែមានការតភ្ជាប់នូវភាពមានការងារ និង/ឬកិច្ចគាំពារសង្គម ច្បាស់ៗ) នឹងមានបង្ហាញនៅខាងក្រោមនេះ។

ម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌហិរញ្ញវត្ថុរដ្ឋាភិបាល

ម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌហិរញ្ញវត្ថុរដ្ឋាភិបាល

- បង្កើតគោលនយោបាយទាមទារ
- បង្កើតជំហរសារពើភណ្ឌ "ប្រុងប្រយ័ត្ន" - សម្របសម្រួលទៅតាមតម្រូវការសេដ្ឋកិច្ច ដោយគិតលើភាពមានហិរញ្ញវត្ថុ
- ពង្រឹងមូលដ្ឋានគិតពន្ធ ពង្រឹងការអនុវត្ត និងស្វែងរកប្រភពធនធានផ្សេង
- ធ្វើសនិទានកម្មចំណាយរបស់រដ្ឋ ដើម្បីធ្វើឱ្យប្រសើរដល់ធនធានដែលមានសម្រាប់អាទិភាពដែលមានកំណត់នៅក្នុងរបៀបវារៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ពង្រីកសម្បទាផ្តល់មីក្រូហិរញ្ញប្បទាន ជាពិសេសនៅតំបន់ជនបទ

អភិបាលកិច្ចល្អ

របបអភិបាលកិច្ច

- ពង្រឹងសមត្ថភាពផ្តល់ថវិកានៅរដ្ឋបាលថ្នាក់ទាប
- កំណែទម្រង់ PFM (កម្មវិធីទី ២)
- បង្កើតភ្នាក់ងារទទួលខុសត្រូវការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ (តំបន់សេដ្ឋកិច្ចពិសេស)
- ពាក់ព័ន្ធនឹងចំណុចខាងលើ៖ ដោយឡែកសម្របសម្រួលការជំរុញ SME ឱ្យទៅជាវិស័យរៀបរយ
- បង្កើតសេវាកម្មច្រកចេញចូលតែមួយ នៅគ្រប់កម្រិត
- ជាទូទៅ៖ គ្រប់វិធានការទាំងអស់ ក្នុងជំពូកនេះ សំដៅ "ប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់នូវសេវាកម្មសាធារណៈប្រកបដោយប្រសិទ្ធភាពមួយ"

ការបង្កើនកសិកម្ម

កសិកម្ម - លើកកម្ពស់ផលិតភាព និងពិពិធកម្ម

- ការធ្វើស្រែចំការប្រពលវប្បកម្មកាន់តែច្រើននៅលើដីដែលមានស្រាប់
- ណែនាំពីបច្ចេកទេសដាំដំណាំជាច្រើន
- បង្កើតកសិ-ឧស្សាហកម្ម ដូចជាដំណាំកៅស៊ូ
- ជំរុញ/បង្កើតបរិយាកាសអំណោយផលដល់វិនិយោគិន
- ប្រែក្លាយចំណឹងដឹង និងលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ (មើលផ្នែកបន្ទាប់)

ហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ
- លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន
- ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត (បណ្ដាញធារាសាស្ត្រ)
- បង្កើត/លើកកម្ពស់បណ្ដាញបច្ចេកទេសព័ត៌មានវិទ្យា

វិស័យឯកជន

ការអភិវឌ្ឍវិស័យឯកជន
- លើកកម្ពស់បរិយាកាសវិនិយោគទុន
- សម្របសម្រួលការបង្កើត SME នៅក្នុងវិស័យរៀបរយ
- បង្កើតការងារ និងលើកកម្ពស់លក្ខខណ្ឌការងារ
- បង្កើតសំណាញ់សុវត្ថិភាពសង្គម

ទាំងនេះជា "ជ្រុង" ទាំង ៤ នៃរបៀបវារៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ដោយផ្ដោតលើការអភិវឌ្ឍវិស័យឯកជន។ វិធានការដែលមានរៀបរាប់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម រួមមាន "ការធ្វើសកម្មភាពសមស្រប ដើម្បីលើកកម្ពស់វិធានការសារពើពន្ធ និងមិនមែនសារពើពន្ធ សម្រាប់គាំទ្រឧស្សាហកម្មជាអាទិភាព និងការបង្កើតមូលនិធិជាតិសន្តិសុខសង្គមទូលំទូលាយមួយ។ ការផ្ដោតបន្ថែមទៅលើរបៀបវារៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម គឺការសិក្សាកម្មវិធី ដែលសង្កត់លើការកសាងមូលធនមនុស្ស និងសំដៅលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ (ដូចជា ចំណីអាហារសម្រាប់កម្មវិធីការងារដូចដែលបានរៀបរាប់)។

មូលធនមនុស្ស

ការកសាងមូលធនមនុស្ស
- បង្កើនលទ្ធផលនៃប្រព័ន្ធអប់រំ
- ពង្រឹងការចូលរួមក្នុងកម្មវិធីបច្ចេកទេស និងវិស្វកម្ម នៅក្នុងការអប់រំជាន់ខ្ពស់តាមរយៈកម្មវិធី TVET
- បង្កើនបទបញ្ញត្តិសេវាកម្មសុខភាព

ប្រាកដណាស់ កម្មវិធីផ្សេងៗនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩ - ២០១៣ ដែលមាននៅក្នុងការរៀបរាប់មានកម្រិតខាងលើនេះ ពិតជាមានអន្តរទំនាក់ទំនងគ្នាយ៉ាងខ្លាំងមិនខាន។ ជោគជ័យនៅក្នុងវិស័យណាក៏ដោយ គឺពឹងផ្អែកលើវឌ្ឍនភាពនៅក្នុងវិស័យផ្សេងទៀតទាំងអស់។

### ៣.២. យុទ្ធសាស្ត្រជាតិកិច្ចគាំពារសង្គម

យោងទៅតាមដំណើរការពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយនឹងដៃគូពាក់ព័ន្ធថ្នាក់ជាតិ នៅខែ មេសាឆ្នាំ ២០១១ រាជរដ្ឋាភិបាលកម្ពុជាបានបោះពុម្ពផ្សាយនូវយុទ្ធសាស្ត្រ

ជាតិគាំពារសង្គម (NSPS)។ NSPS នេះមានគោលបំណងបំពេញបន្ថែម និងសហការជាមួយផែនការ និងយុទ្ធសាស្ត្ររបស់ក្រសួងខ្សែបណ្តោយ និងភាគីពាក់ព័ន្ធដទៃទៀតនៅក្នុងវិស័យកិច្ចគាំពារសង្គម។ លើសពីនេះទៀត NSPS បានបញ្ជាក់ពិស្តារនូវអាទិភាពដែលបានកំណត់នៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ឆ្នាំ ២០០៩-២០១៣ និងយុទ្ធសាស្ត្រចតុកោណសំរាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព ជំហានទី ២។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) មានទំនួលខុសត្រូវសំរាប់ការសម្របសម្រួលបង្កើត NSPS។

**វិសាលភាព NSDP**

NSPS សំរាប់រយៈពេលខ្លី និងមធ្យមផ្តោតសំខាន់លើការបង្កើត និងពង្រីកកិច្ចគាំពារសង្គមសំរាប់ជនក្រីក្រ និងជនងាយរងគ្រោះ។ NSPS ដាក់អាទិភាពចំពោះការបង្កើតសំណាញ់សុវត្ថិភាពសង្គមដែលមានចីរភាព និងប្រសិទ្ធិភាពដែលមានជនក្រីក្រ និងងាយរងគ្រោះជាទិសដៅពិសេស។ កម្មវិធីភាគច្រើនក្រោម NSPS គឺទទួលថវិកាពីប្រាក់ចំណូលទូទៅ។ ទោះបីជាយ៉ាងណាក៏ដោយ NSPS រួមមានការបង្កើតនូវគម្រោងធានារ៉ាប់រងសុខភាពសហគមន៍ដែលមានមូលធិនិបដិភាគ។

សំរាប់រយៈពេលវែង NSPS មានទសន្សៈវិស័យក្នុងការពង្រីកបន្ថែមឆ្ពោះទៅកាន់ក្របខណ្ឌកិច្ចគាំពារសង្គមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយមួយ រួមមានការបង្កើត និងការទទួលបាននូវគម្រោងធានារ៉ាប់រងសង្គមដែលមានស្រាប់ និងថ្មី។ ជំហានបន្ទាប់គឺជាការបញ្ជាក់ និងអនុវត្តបន្ថែមនូវផែនការសកម្មភាពជាមួយនឹងអាទិភាពនៅក្នុងអំឡុងឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៥។ សំរាប់ឆ្នាំ ២០១៣ នឹងមានការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ ហើយនៅក្នុងឆ្នាំ ២០១៥ ការអនុវត្ត NSPS នឹងត្រូវបានវាយតម្លៃ។

**NSDP ត្រូវបានបញ្ចូលនៅក្នុងក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិទូលំទូលាយជាង**

NSPS ត្រូវបានបញ្ចូលទៅក្នុងក្របខណ្ឌនៃរដ្ឋធម្មនុញ្ញ និងនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាឯកសារគោលនយោបាយរបស់រដ្ឋាភិបាលដូចជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និង NSDP និងសេចក្តីថ្លែងការណ៍ថ្មីៗរបស់នាយកមន្ត្រី គឺសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។ កម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិសំខាន់ជាច្រើនក្នុងគោលបំណងស្វែងយល់ពីសិទ្ធិក្នុងការទទួលបានកិច្ចគាំពារសង្គម ហើយរដ្ឋាភិបាលបានអនុម័ត NSPS និងសកម្មភាពដែលចេញពីយុទ្ធសាស្ត្រនេះស្របតាមការប្តេជ្ញាចិត្តអន្តរជាតិទាំងនេះ។

**ហានិភ័យ និងភាពងាយរងគ្រោះ**

ឯកសារ NSPS ពិពណ៌នានូវហានិភ័យមួយចំនួន និង ភាពងាយរងគ្រោះដែលបុគ្គល និងគ្រួសារអាចជួបប្រទះ។ ដែលទាំងនេះរួមមានការសង្គ្រោះបន្ទាន់ និងវិបត្តិ -ជាឧទាហរណ៍ដោយសារកើនឡើងនូវតម្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ និងគ្រោះធម្មជាតិ-ដូចជាទឹកជំនន់ និងគ្រោះរាំងស្ងួត និងឧបសគ្គក្នុងការអភិវឌ្ឍន៍មនុស្សជាតិ-ដូចជាអនក្ខរកម្ម កត្តាតាមរដូវកាលដែលធ្វើឱ្យមានអសន្តិសុខស្បៀង និងមហន្តរាយសុខភាពដែលមានផលប៉ះពាល់ទៅលើបុគ្គលនិងគ្រួសារទាំងលើផ្នែកចំណាយ និងផ្នែកចំណូល។

**ក្រុមទទួលរងការប៉ះពាល់ និងយុទ្ធសាស្ត្រដោះស្រាយអវិជ្ជមាន**

ឯកសារនេះនឹងវាយនាម ក្រុមមួយចំនួនដែលជាពិសេសស្ថិតក្នុងស្ថានភាពងាយរងគ្រោះ។ ក្រុមទាំងនោះរួមបញ្ចូល កុមារ កុមារី និងស្ត្រីដែលគ្រប់អាយុ ពលរដ្ឋដែលមានជំនាញទាប អ្នកដែលមានសុខភាពមិនមាំមួន ពលរដ្ឋចាស់ជរា និងជនជាតិភាគតិច។

ស្ថានភាពនេះកាន់តែធ្ងន់ធ្ងរជាងនេះទៅទៀតពេលដែលគ្រួសារប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយដែលមានវិនាស ពេលដែលពួកគេស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ឬប្រឈមមុខនឹងមហន្តរាយ។ ឧទាហរណ៍ ដូចជាការចុះហត្ថលេខាទទួលប្រាក់កម្ចីដែលមានការប្រាក់ខ្ពស់ ឬក៏យកកូនរបស់ខ្លួនចេញពីសាលាដើម្បីជួយរកប្រាក់ចំណូលចិញ្ចឹមជីវិតតាមបែបយថាកម្ម។

**ក្របខណ្ឌបច្ចុប្បន្ន**

ឯកសារ NSPS បានធ្វើការគិតគូរពិចារណា និងវាយតម្លៃទៅលើកម្មវិធីកិច្ចគាំពារសង្គមដែលមានស្រាប់ពេលបច្ចុប្បន្ន។

តារាងទី ៣ នៅក្នុង NSPS មានសារពើព័ន្ធនូវការរៀបចំពេលបច្ចុប្បន្ន និងក្រសួងដែលទទួលខុសត្រូវក្នុងការរៀបចំទាំងអស់នេះ។ ដើម្បីងាយស្រួល តារាងទី ៣ នៅក្នុងឯកសារ NSPS មិនបានដាក់បង្ហាញនៅទីនេះទេ។

**គម្លាត និងភាពប្រឈមនៅក្នុងក្របខណ្ឌបច្ចុប្បន្ន**

ជាបន្តគម្លាត និងភាពប្រឈមត្រូវបានបញ្ជាក់។ ជាថ្មីម្តងទៀតដើម្បីងាយស្រួលអ្នកអានអាចយោងទៅតារាងទី ៤ នៃឯកសារNSPS។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់អត្តសញ្ញាណឧបសគ្គក្នុងការអនុវត្ត និងឧបសគ្គស្ថាប័នមួយចំនួនទាក់ទងទៅនឹងការផ្តល់កិច្ចគាំពារសង្គមដ៏មានប្រសិទ្ធិភាព និងគ្រប់ជ្រុងជ្រោយ។

- ការអភិវឌ្ឍន៍ទន់ខ្សោយនៅកម្រិតរដ្ឋបាលមូលដ្ឋានក្នុងការអនុវត្តវិធាន
- ការសហការមានកម្រិត នាំឱ្យមានគម្លាត/ភាពជាន់គ្នាក្នុងការគ្រប់ដណ្តប់
- មិនមែនជាទស្សនៈរយៈពេលវែង ប៉ុន្តែជានិន្នាការអាទិភាពភ្លាមៗដើម្បីកំណត់របៀបវារៈ

- កង្វះនូវការគ្របដណ្តប់តាមភូមិសាស្រ្តជាសកល និងមានភាពទន់ខ្សោយក្នុងការកំណត់អាទិភាពតំបន់
- កម្មវិធីមានរយៈពេលខ្លី មានភាពខ្វះចន្លោះក្នុងការតាមដានផលប៉ះពាល់
- អវត្តមាននូវយន្តការផ្តល់មតិយោបល់ អភិបាលកិច្ចមិនមានតម្លាភាព
- មានការសហការទន់ខ្សោយក្នុងការផ្តល់មូលនិធិ

NSDP ៖ ទស្សនៈវិស័យ

ទស្សនៈវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលសំរាប់កិច្ចគាំពារសង្គម គឺធានានូវការធានាជាមូលដ្ឋាននូវកិច្ចគាំពារសង្គមសំរាប់ពលរដ្ឋទាំងមូល។ វារួមបញ្ចូលទាំងសេវាផ្តល់មូលនិធិប្រាក់ចំណូលទៅដល់ជនក្រីក្រ និងគម្រោងធានារ៉ាប់រង។

NSDP ៖ គោលដៅ

គោលដៅយុទ្ធសាស្រ្តរបស់ NSPS រួមមាន៖

- ការពារអ្នកក្រីក្របំផុត និងអ្នកដែលមិនបានទទួលផលប្រយោជន៍
- បង្ការផលប៉ះពាល់នៃហានិភ័យដែលឈានទៅដល់ឥរិយាបថដោះស្រាយអវិជ្ជមាន និងធ្វើឱ្យកាន់តែក្រីក្របន្ថែមទៀត
- ជួយកសាងធនធានមនុស្ស និងពង្រីកឱកាសសំរាប់ជនក្រីក្រដើម្បីឱ្យពួកគេធ្វើការដោយខ្លួនឯង

ជំហានយុទ្ធសាស្រ្ត

គោលបំណងទាំងនេះគួរតែអាចសម្រេចបានតាមរយៈជំហានដូចខាងក្រោម៖ បញ្ចប់គម្លាតដែលមាន ពង្រីកនិងធ្វើឱ្យមានសុខដុមនីយកម្មនូវកម្មវិធីដែលមានស្រាប់ និងសម្របសម្រួលការប្រឹងប្រែងរបស់ភ្នាក់ងារដែលពាក់ព័ន្ធ ធានានូវហិរញ្ញប្បទានទៀងទាត់ និងពង្រឹងរដ្ឋបាល និងការអនុវត្តការវាយតម្លៃ។

គោលដៅ

យោងទៅតាមការរៀបរាប់ពីហានិភ័យ ក្រុមអ្នកដែលមិនបានទទួលផលប្រយោជន៍ ភាពងាយរងគ្រោះ និងគម្លាត NSPS កំណត់គោលបំណងទាំងប្រាំ និងបញ្ជាក់ពីឧបករណ៍ក្នុងការសម្រេចបានគោលបំណងទាំងនេះ។

១. លទ្ធភាពក្នុងការទទួលបានសេវាជាមូលដ្ឋាន

២. សំណាញ់សន្តិសុខសង្គមដែលបានកំណត់ទិសដៅចំពោះកុមារ និងស្ត្រី

៣. គោលនយោបាយទីផ្សារការងារសកម្មក្នុងការភ្ជាប់ពលរដ្ឋគ្រប់អាយុដែលមិនសកម្មទៅនឹងទីផ្សារការងារ

៤. លទ្ធភាពក្នុងការទទួលបានសេវាថែទាំសុខភាព និងការការពារហិរញ្ញវត្ថុសំរាប់ជនក្រីក្រ និងអ្នកងាយរងគ្រោះ

៥. ការផ្តល់ជូនជាពិសេសសំរាប់ក្រុមដែលមិនបានទទួលផលប្រយោជន៍

យើងខ្ញុំនឹងរៀបរាប់ពីគោលបំណង និងឧបករណ៍ទាំងនេះពេលក្រោយក្នុងរបាយការណ៍នេះ។

| | |
|---|---|
| បញ្ហានៃការសម្របសម្រួល និងការអនុវត្ត | CARD មានអាណត្តិក្នុងការសម្របសម្រួល NSPS ជាមួយនឹងទស្សនៈក្នុងការធានាប្រសិទ្ធិភាព និងភាពគ្រប់ជ្រុងជ្រោយនៃវិធានដែលមាននៅក្នុង NSPS។ ការអនុវត្តជាក់ស្តែងនៃវិធានផ្សេងៗនឹងស្ថិតក្រោមទំនួលខុសត្រូវរបស់ក្រសួងខ្សែបណ្តោយ។ NSPS នឹងផ្តល់ក្របខណ្ឌជាទូទៅមួយដើម្បីជាមាគ៌ានៃសកម្មភាពទាំងនេះ ច្បាស់ជាងនេះទៀត៖ ដើម្បីជៀសវាងការជាន់គ្នា ឬគម្លាត ធ្វើឱ្យមានសុខដុមនីយកម្មនូវនីតិវិធី សម្រេចបាននូវសមត្ថភាពនៅក្នុងក្រសួង រដ្ឋបាលមូលដ្ឋាន និងភ្នាក់ងារពាក់ព័ន្ធដទៃទៀត ពង្រឹងយន្តការតាមដាន និងអនុលោម និងសម្របសម្រួលការប្រើប្រាស់មូលនិធិដែលមាន។ ឯកសារ NSPS កំណត់សកម្មភាពមួយចំនួនដែលបញ្ជាក់បន្ថែមនៅក្នុងរបាយការណ៍នេះ។ |

## ជំពូកទី៤ ទំនាក់ទំនងដែលមិនមានការផ្សារភ្ជាប់៖ យុទ្ធសាស្ត្រជាតិមុខរបរ និងការងារ

### ៤.១. សេចក្តីផ្តើម

ទសវត្សចុងក្រោយនៃកំណើនសេដ្ឋកិច្ចខ្ពស់មិនបានលុបបំបាត់នូវវិបត្តិភាពខ្វះការងារយ៉ាងសំបើមនោះទេ

យើងអាចរំលឹកពីជំពូកមុនថាយើងបានសំរេចការងារជាមូលដ្ឋាន នៅកម្រិតយុទ្ធសាស្ត្រ ហើយធាតុផ្សំជាមូលដ្ឋានក៏មានរួចជាស្រេចដែរ ដែលយើងអាចកំណត់បាន។ លើសពីនេះទៀត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ និង NSPS មានប្រសិទ្ធភាពក្នុងការបង្កើតដំណើរការក្នុងការស្វែងរកនូវរបៀបវារៈឆ្ពោះទៅកាន់ការរួមបញ្ចូលសេដ្ឋកិច្ចនិងសង្គម នៃប្រជាពលរដ្ឋកម្ពុជាទាំងអស់។ ដូចនេះ យើងអាចមានចម្ងល់ថា៖ តើកម្ពុជានៅតែត្រូវការ យុទ្ធសាស្ត្រជាតិមុខរបរ និងការងារដែរឬទេ? ជំពូកនេះនឹងបង្ហាញថាយើងពិតជាត្រូវការ។ ជាដំបូង យើងនឹងវាយតម្លៃ ស្ថានភាពដែលកើតមាន ៖ ស្ថានភាពទីផ្សារការងារពេលបច្ចុប្បន្ន។ ទសវត្សកន្លងទៅនេះ កំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លា មិនបានផ្តល់ការងារដែលទទួលបានប្រាក់កម្រៃ ជាមួយនឹងលក្ខខណ្ឌការងារសមរម្យទៅដល់ប្រជាពលរដ្ឋកម្ពុជាដែលគ្រប់អាយុបំរើការងារហើយមានបំណងចង់បំរើការងារ បានគ្រប់គ្រាន់នោះទេ។ ដូចនេះ ជាការពិតជាក់ស្តែងដែលថាកំណើនសេដ្ឋកិច្ច មិនមានប្រសិទ្ធិភាពក្នុងការជៀសឱ្យផុតពីភាពខ្វះការងារ នោះទេ។ កំណើនសេដ្ឋកិច្ចបានផ្តល់ឱកាសដល់បុគ្គលមួយចំនួន ប៉ុន្តែមិនបានអើពើចំពោះបុគ្គលមួយចំនួន និងជាច្រើនទៀត ហើយនេះរួមបញ្ចូលចំនួនដ៏ច្រើននៃអ្នកក្រីក្រប្រកបការងារ។

NES ៖ ទស្សនៈវិស័យ និងក្របខណ្ឌស៊ីសង្វាក់គ្នា

តើយុទ្ធសាស្ត្រជាតិមុខរបរ និងការងារជាអ្វី? វាគឺជាទស្សនៈវិស័យ និងក្របខណ្ឌស៊ីសង្វាក់គ្នាមួយដែលភ្ជាប់គោលនយោបាយក្នុងរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដែលរួមចំនែកក្នុងវិស័យការងារ។ វាទាមទារឱ្យមានការប្រមើមើលរយៈពេលវែងឆ្ងាយមួយ៖ តើកម្ពុជាយល់ឃើញថាខ្លួននឹងស្ថិតនៅស្ថានភាពបែបណាក្នុងរយៈពេល ៥ ទៅ ១០ ឆ្នាំទៀត? ហើយវាពឹងផ្អែកទៅលើកិច្ចសន្ទនាសង្គមដើម្បីបង្កើតផែនការរួមមួយជាមួយនឹងការបែងចែកការផ្តោតយកចិត្តទុកដាក់។

ដើម្បីសម្រេចបាន វាត្រូវការអភិក្រមយុទ្ធសាស្ត្របន្ថែម

យុទ្ធសាស្ត្រជាតិមុខរបរ នឹងបំពេញបន្ថែមនូវឯកសារយុទ្ធសាស្ត្ររាជរដ្ឋាភិបាលដែលមានស្រាប់ ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ និង NSPS។ ក្នុងការបង្កើត និងការបរិយាយពី យុទ្ធសាស្ត្រជាតិមុខរបរ និងការងារ គឺទាមទារឱ្យមានការពិចារណាយ៉ាងម៉ត់ចត់ទៅលើ ឯកសារប្រវត្តិសាស្ត្រទាំងនេះ ក្នុងគោលបំណងធានាថា ការផ្តួចផ្តើមនៅក្រោម យុទ្ធសាស្ត្រជាតិមុខរបរ និងការងារ

នឹងមានលទ្ធផលជាផ្លែផ្កា។ ជំពូកនេះនឹងបង្ហាញនូវគ្រោងនៃយុទ្ធសាស្ត្រជាតិមុខរបរ និងការងារ។

### ៤.២. ស្ថានភាពទីផ្សារការងារពេលបច្ចុប្បន្ន

**ការចូលរួមក្នុងកម្លាំងពលកម្មមានកម្រិតខ្ពស់នៅប្រទេសកម្ពុជា**

អត្រាចូលរួមក្នុងកំលាំងពលកម្មក្នុងប្រទេសកម្ពុជាមានកម្រិតខ្ពស់ពាក់ព័ន្ធទៅនឹងស្តង់ដារអន្តរជាតិ។ អត្រាចូលរួមក្នុងទីផ្សារការងារសរុបសំរាប់ពលរដ្ឋដែលមានអាយុ ១៥ ឆ្នាំ ឬច្រើនជាង ១៥ ឆ្នាំបានកើនឡើងពី 77% ដល់ 78% ក្នុងអំឡុងឆ្នាំ ១៩៩៨ ២០០៨។ ជាង 25% នៃកំលាំងការងារសរុបគឺស្ថិតក្នុងក្រុមអាយុពី ១៥ ដល់ ២៤ ឆ្នាំ។ កំលាំងការងារសរុបកើនឡើងប្រហែលជា 3.3% ក្នុងមួយឆ្នាំជាមធ្យមក្នុងអំឡុងទសវត្សចុងក្រោយនេះ។

**អត្រាភាពមានការងារក៏មានកម្រិតខ្ពស់ដែរ ជនជាតិភាគច្រើនលើសលុបនៅតែធ្វើការនៅក្នុងវិស័យដំបូង ប៉ុន្តែចំណែកនៃវិស័យដទៃទៀតក៏កំពុងរីកចំរើនដែរ**

ការងារប្រៀបធៀបទៅនឹងអត្រាប្រជាជននៅក្នុងប្រទេសកម្ពុជាគឺប្រហែលជា 77% ដែលជាតួលេខមួយដ៏ខ្ពស់ប្រៀបធៀបទៅនឹងស្តង់ដារអន្តរជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ យើងគួរតែចងចាំថាការងារសរុបរួមបញ្ចូលចំណែកដ៏ធំនៃអ្នកជួយគ្រួសារដែលមិនបានទទួលប្រាក់កម្រៃ ដែលភាគច្រើនជាស្ត្រី។ ភាគច្រើន (71%) នៃអ្នកបំរើការងារធ្វើការក្នុងវិស័យដើម រួមមានវិស័យកសិកម្ម ទោះបីជាយ៉ាងណាក៏ដោយចំណែកនៃវិស័យដើម គឺកំពុងតែធ្លាក់ចុះ។ ចំណែកនៃវិស័យបន្ទាប់ (ឧស្សាហកម្ម) បានកើនឡើងដល់ 8.6% នៃការងារសរុប ជាពិសេសដោយការ កើនឡើងនៃឧស្សាហកម្មកាត់ដេរ និងស្បែកជើង។ ការងារក្នុងវិស័យទី៣ (ពាណិជ្ជកម្ម និងសេវាកម្ម) មានការកើនឡើងដល់ 19.3% នៅចុងទសវត្សចុងក្រោយនេះ។

**ការបំរើការងារច្រើនបំផុតនៅក្នុងវិស័យមិនរៀបរយ**

ភាគច្រើនលើសលប់នៃអ្នកបំរើការងារ (83%) ត្រូវបានចាត់ចូលក្នុងសេដ្ឋកិច្ចមិនរៀបរយ ពួកគេតែងតែមិនមានសុវត្ថិភាពប្រាក់ចំណូល និងជាទូទៅមិនមានសិទ្ធិទទួលបានផលប្រយោជន៍កិច្ចគាំពារសង្គមតាមរយៈនិយោជក ឬមុខរបររបស់ខ្លួនប្រសិនពួកគេជាអ្នកមានមុខរបរផ្ទាល់ខ្លួន។

**ពលករជាច្រើនជាពលករទេសន្តប្រវេសន៍ក្នុងស្រុក**

ទេសន្តប្រវេសន៍កំលាំងពលកម្មក្នុងស្រុកមានកំរិតខ្ពស់នៅក្នុងប្រទេសកម្ពុជា ហើយប្រហែលជា ១/៣ នៃកំលាំងពលកម្មជាពលករចំណាកស្រុក។ ការចល័តកំលាំងពលកម្មក្នុងស្រុកគឺពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងវិស័យដើម ជាពិសេសវិស័យកសិកម្ម។

**ហើយភាពគ្មានការងារមិនច្រើនទេប៉ុន្តែភាពខ្វះការងារទើបជាបញ្ហាពិតប្រាកដ**

អត្រាអត់ការងារធ្វើជាផ្លូវការគឺមានកំរិតទាបត្រឹមតែ 1.6% តែប៉ុណ្ណោះនៃកំលាំងពលកម្ម (ឆ្នាំ ២០០៨)។ ទោះជាយ៉ាងនេះក៏ដោយ ភាពខ្វះការងារធ្វើ និង ភាពអត់ការងារធ្វើតាមរដូវគឺមានកំរិតខ្ពស់ជាពិសេសក្នុងសេដ្ឋកិច្ចមិនរៀបរយ។

វិបត្តិហិរញ្ញវត្ថុបានបង្ហាញពីភាពគ្មានលំនឹងនៃស្ថាប័ន ឧទាហរណ៍ដូចជាក្នុងការបង្កើតឱកាសសម្រាប់ការចូលការងារថ្មីនិងពលករដែលមានការងារឱ្យអំណោយផលទាប

វិបត្តិសេដ្ឋកិច្ចពិភពលោកបានបង្ហាញពីអតុល្យភាពរចនាសម្ព័ន្ធនៅក្នុងប្រទេសកម្ពុជា និងបានបង្ហាញពីការប្រឈមទីផ្សារការងារ។

ការប្រឈមមួយក្នុងចំណោមការប្រឈមសង្គម និងសេដ្ឋកិច្ចចំបងរបស់កម្ពុជា គឺការបង្កើតឱកាសការងារសំរាប់អ្នកដែលចូលក្នុងកំលាំងការងារថ្មី ខណៈពេលជាមួយគ្នានេះផងដែរគឺការបង្កើនការរកប្រាក់ចំណូល និងលើកកម្ពស់ផលិតភាពសំរាប់ពលករភាគច្រើនដែលបំរើការងារតំបន់ជនបទ និងសេដ្ឋកិច្ចមិនរៀបរយ។ ប្រជាជនក្នុងអាយុសកម្ម (២៥ ដល់ ៥៤) នឹងកើនឡើងដោយអត្រាមធ្យមប្រចាំឆ្នាំចំនួន 3.4%។ អត្រាកំណើនដ៏ខ្ពស់ នៃប្រជាជនដែលមានអាយុអាចបំរើការងារនេះ នឹងធ្វើឱ្យមានការកើនឡើងកំលាំងពលកម្មយ៉ាងច្រើននៅក្នុងទសវត្សបន្ទាប់។

ដើម្បីពង្រឹងផលិតភាព និងបកស្រាយវាទៅជាលក្ខខណ្ឌការងារដែលប្រសើរជាងមុន និងមានប្រាក់ឈ្នួលខ្ពស់ជាងមុន... ជាពិសេសសម្រាប់ក្រុមជនងាយរងគ្រោះ

ការប្រឈមដ៏ចំបងដទៃទៀតចំពោះកម្ពុជាគឺការទាមទារឱ្យមានការបង្កើនផលិតភាព និងធានាថាការទទួលបានផលិតភាព នឹងត្រូវបានបង្វែរទៅជាលក្ខខណ្ឌការងារប្រសើរជាង និងប្រាក់ឈ្នួលខ្ពស់ជាងនេះ។ ប្រទេសកម្ពុជាជាប្រទេសមួយដែលមានកំរិតផលិតភាពទាបបំផុតបើប្រៀបធៀបទៅនឹងប្រទេសដទៃទៀតនៅក្នុងតំបន់អាស៊ាន។

ក្រុមបុគ្គលមួយចំនួននៅក្នុងសង្គមជាចាំបាច់ត្រូវការនូវជំនួយពេលដែលគិតគូរពីបញ្ហាផលិតភាពពីព្រោះពួកគេមានជំនាញទាប និងឱកាសការងារមានកម្រិត។ នេះរួមបញ្ចូលអ្នកដែលរស់នៅក្រោមឬជិតបន្ទាត់ក្រីក្រ ប្រជាជនវ័យក្មេង (ដែលមានចំនួនភាគរយយ៉ាងខ្ពស់ក្នុងចំណោមអ្នកដែលគ្មានការងារធ្វើ) ស្ត្រី (ដែលនៅតែប្រឈមមុខនឹងឧបសគ្គទាក់ទងទៅនឹងប្រពៃណី និងទទួលបានការអប់រំទាប) និងអ្នកដែលរស់នៅដាច់ដោយឡែកនៅតំបន់ជនបទក្រីក្រ។

និងសម្រាប់កសាងធនធានមនុស្សដែលត្រូវការសម្រាប់ទាក់ទាញការវិនិយោគ និងជំរុញកំណើនសេដ្ឋកិច្ច

ទោះបីជាមានការឈានឡើងគួរឱ្យកត់សម្គាល់ក្នុងឆ្នាំកន្លងទៅនេះ កម្ពុជាជួបបញ្ហាប្រឈមជាចំបងក្នុងការកសាងមូលដ្ឋានធនធានមនុស្សដ៏ខ្លាំងក្លាមួយ និងកសាងកំលាំងពលកម្មដែលមានជំនាញដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងាររបស់ខ្លួន ដែលមានការកើនឡើងនូវការផ្គូរផ្គងមិនស៊ីសង្វាក់គ្នារវាងជំនាញរបស់ កំលាំងពលកម្ម និងជំនាញដែលនិយោជកត្រូវការ ដែលជាស្ថានភាពមួយកើតឡើង ដោយសារការកើនឡើងដ៏ឆាប់រហ័សនៃកំលាំងពលកម្ម និងការវិវត្តន៍យឺតនៃពិពិធកម្មសេដ្ឋកិច្ច។ កម្ពុជា នៅក្នុងកម្រិតបច្ចុប្បន្ននៃការអភិវឌ្ឍន៍ ទាមទារនូវជំនាញការងារក្នុងអាជីពដូចជា វិស្វករមេកានិច និងវិស្វករភ្លើងព្រោះថាវាជាការងារដែលត្រូវបានបង្កើតក្នុងវិស័យឧស្សាហកម្ម។ មានការផ្គូផ្គងមិនស៊ីសង្វាក់គ្នាដ៏ធំមួយរវាងតម្រូវ

ការទីផ្សារការងារ ជារួមគឺវិញ្ញាបនប័ត្រវគ្គបណ្តុះបណ្តាល និងធនធានបច្ចុប្បន្នដែលចេញពីមហាវិទ្យាល័យ (វិទ្យាសាស្ត្រសង្គម និងការសិក្សារទាក់ទងទៅនឹងធុរកិច្ច)។

ចំណុចនេះសំដៅលើតម្រូវការសម្រាប់ NES – "គោលការណ៍ណែនាំ" ខ្លះសម្រាប់ NES

កំណើនសេដ្ឋកិច្ចខ្ពស់មិនអាចដោះស្រាយបញ្ហានេះបានជោគជ័យនោះទេ។ ដូចនេះទាមទារឱ្យមានយុទ្ធសាស្ត្រជាតិមុខរបរ និងការងារ ដើម្បីបំពេញបន្ថែមឱ្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ និង NSPS ។ យុទ្ធសាស្ត្រជាតិមុខរបរ និងការងារនឹងផ្តោតសំខាន់លើការបង្កើតបរិមាណការងារដែលមានគុណភាពឱ្យបានគ្រប់គ្រាន់ ដែលជាការងារមានផលិតភាព និងឱកាសការងារដែលទទួលបានប្រាក់ឈ្នួលខ្ពស់សំរាប់អ្នកដែលក្នុងពេលបច្ចុប្បន្នកំពុងស្វែងរកការងារ និងអ្នកដែលនឹងចូលរួមក្នុងទីផ្សារការងារក្នុងពេលឆាប់ៗនេះ។ យុទ្ធសាស្ត្រជាតិមុខរបរ និងការងារនៅក្នុងបរិបទនេះអាចជាទំនាក់ទំនងមិនផ្សារភ្ជាប់មួយក្នុងក្របខណ្ឌអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ហើយវាអាចបង្កើតអាទិភាពចំបងមួយរបស់រាជរដ្ឋាភិបាលៈ ការកាត់បន្ថយភាពចំនួន គ្រួសារក្រីក្រ និងងាយរងគ្រោះ។

## ៤.៣. បញ្ចូលយុទ្ធសាស្ត្រជាតិមុខរបរ និងការងារទៅក្នុងក្របខណ្ឌអភិវឌ្ឍន៍ទូលំទូលាយ

បញ្ចូល NES ទៅក្នុងរបៀបវារៈ NSDP

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦ - ២០១០ បានចាត់បញ្ចូលការកាត់បន្ថយភាពក្រីក្រក្នុងចំណោមអាទិភាពខ្ពស់បំផុតរបស់ប្រទេសជាតិ។ រដ្ឋាភិបាលបង្ហាញនូវតម្រូវការចំពោះ ការផ្តោតការយកចិត្តទុកដាក់ និងសកម្មភាពដែលកំណត់ទិសដៅដើម្បីសម្រេចបាន គោលដៅអភិវឌ្ឍន៍សហសវត្សសំរាប់ប្រទេសកម្ពុជា (CMDGs) ក្នុងការកាត់បន្ថយភាពក្រីក្រ (NSDP ២០០៦-២០១០)។ NSDP បច្ចុប្បន្នកម្ម ២០០៩-២០១៣ កំណត់ថា ការបង្កើតការងារ និងធានាលើកកម្ពស់លក្ខខណ្ឌការងារ គឺជាគោលដៅរយៈពេលវែងរបស់រដ្ឋាភិបាល ដើម្បីឱ្យប្រជាជនមានជីវភាពសមរម្យ និងកាត់បន្ថយភាពក្រីក្រ និងជម្រុញឱ្យមានកំណើនសេដ្ឋកិច្ច។ នេះផ្តល់បរិបទ និងមូលដ្ឋានក្នុងការបង្កើត គោលនយោបាយ/យុទ្ធសាស្ត្រជាតិមុខរបរ (ដែលជាគោលនយោបាយមួយផ្តោតសំខាន់លើការលើកកម្ពស់មុខរបរ ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ និងគ្មានការរើសអើង ) ហើយសំរាប់ការបញ្ចូលយុទ្ធសាស្ត្រ និងគោលនយោបាយនោះទៅក្នុងក្របខណ្ឌអភិវឌ្ឍន៍ជាតិ។

ក៏ដូចជាកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ

ការបង្កើនឱកាសការងារមានផលិតភាព និងភាពមានការងារធ្វើរបស់ប្រជាជនកម្ពុជាគ្រប់រូបគឺជាតម្រូវការដ៏ចាំបាច់មួយ ជាពិសេសនៅតំបន់ជនបទដែលមានការរីករាលដាលនូវភាពក្រីក្រ (និងមានភាពធ្ងន់ធ្ងរ) និងពិពិធកម្មសកម្មភាពសេដ្ឋកិច្ចនូវមាន

កម្រិត។ នេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិរបស់ប្រទេស ដែលបញ្ជាក់ពីសារៈសំខាន់នៃការបង្កើតមុខរបររយៈពេលវែងដែលមានភាពស្ថិតស្ថេរ ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេស។ និន្នាការសេដ្ឋកិច្ច និងប្រជាសាស្ត្រធ្វើឱ្យការប្រឈមនេះកើតមានឡើងនៅក្នុងបរិបទកម្ពុជា។ ជាមួយនឹងភាពពិតជាក់ស្តែងថាមានការកើនឡើនូវការផ្គូរផ្គងមិនស៊ីសង្វាក់គ្នារវាងជំនាញដែលផ្តល់ជូនដល់កំលាំងពលកម្ម និងជំនាញដែលជាតម្រូវការទីផ្សារ ច្បាស់លាស់ណាស់គឺថាការប្រឈមមុខរបរនៅក្នុងប្រទេសកម្ពុជាកាន់កើនឡើងនៅក្នុងបន្ទាប់។

និងជាពិសេស នៅក្នុងក្របខណ្ឌ NSPS

ខណៈពេលដែល NSPS ត្រូវបានបង្កើតឡើង (សូមពិនិត្យមើលជំពូកមុន) ការបង្កើតយុទ្ធសាស្ត្រជាតិមុខរបរ និងការងារគឺនៅតែជាជំហានបន្ទាប់ ដែលនេះមិនមែនជាពិតនៅឡើយទេ។ ជំពូកទី ២ បានបង្ហាញថាកម្ពុជាត្រូវការផ្តោតសំខាន់លើការបន្តនូវ*ដំណើរការ* ក្នុង*សូចនាករទាំងបួនរបស់ ទិសដៅMDG ១B* ៖ ស្ថានភាពនៃអ្នកក្រីក្របំរើការងារ សមាមាត្រការងារទៅនឹងប្រជាជន សមាមាត្រនៃជនងាយរងគ្រោះ និងការសម្រេចបាននូវផលិតភាពការងារ។ ជំពូកទី ២ នឹងបង្ហាញថាការសម្របសម្រួលនូវ*កំណើននៃការងារវិស័យរៀបរយដែលទទួលបានប្រាក់កម្រៃ*នៅក្នុងវិស័យសាធារណៈ និងឯកជនគឺមានសារៈសំខាន់ណាស់នៅក្នុងបរិបទនេះ។ ទីផ្សារការងារក្នុងប្រទេសកម្ពុជាត្រូវបានកត់សម្គាល់ដោយវិស័យរៀបរយមានកម្រិត និងគម្លាតធំក្នុងការទទួលបានលទ្ធភាពក្នុងការស្វែងរកការងារដែលមានប្រាក់ឈ្នួលខ្ពស់ និងការទទួលបានការអប់រំរវាងបុរស និងស្ត្រី ក្រុមអាយុផ្សេងៗគ្នា និងកម្រិតជំនាញ។ ការដោះស្រាយបញ្ហានេះនឹងជួយឱ្យមានដំណើរការចំពោះគោលដៅដែលបាន កំណត់នៅក្នុងឯកសារ NSPS។ ការមិនដោះស្រាយនូវជ្រុងទាំងសងខាងនៃបញ្ហាក្នុងពេលតែមួយ ហើយក្នុងឥរិយាបថស៊ីសង្វាក់គ្នាទេនោះអាចឈានដល់ការប្រើប្រាស់ធនធានសារធារណៈដោយមិនមានប្រសិទ្ធិភាព និងដោយមិនអស់លទ្ធភាព។

បញ្ហាមួយចំនួនដែលគួរតែជាផ្នែកមួយនៃយុទ្ធសាស្ត្រជាតិមុខរបរ និងការងារ ត្រូវបានដោះស្រាយនៅក្នុង NSPS។ នេះសំដៅលើវិធានការដែលបានកំណត់ក្នុងគោលដៅទី ៣ នៃ NSPS ដែលនេះសាកសមនឹងទទួលបានការអនុញ្ញាត។ ទោះបីជាយ៉ាងណាក៏ដោយវាគឺជាឱកាសខកខានមួយក្នុងការមិនបញ្ចូលឧបករណ៍ គោលនយោបាយទីផ្សារការងារសកម្មនេះ (សំណង់សាធារណៈ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ) ក្នុងក្របខណ្ឌទូលំទូលាយនៃយុទ្ធសាស្ត្រមុខរបរ។

ប្រអប់៖ "គ្រាប់ពេជ្យនៃកំណើន"

ធាតុមួយនៃយុទ្ធសាស្ត្រជាតិមុខរបរ និងការងារអាចជាការកំណត់នូវ "គ្រាប់ពេជ្យនៃកំណើន" ។ ទាំងនេះជាវិស័យសេដ្ឋកិច្ចដែលប្រទេសកម្ពុជាអាចសម្រេចបាននូវផលប្រយោជន៍ប្រកួតប្រជែងក្នុងពេលឆាប់ៗនេះ និងពេលអនាគតវែងឆ្ងាយ។ ការសម្រេចបាននូវជ្រុងនៃការប្រកួតប្រជែងនេះ គឺទាមទារឱ្យមានការសហការដ៏ប្រុងប្រយ័ត្នមួយនៃគោលនយោបាយដែលកំណត់ទិសដៅក្នុងវិស័យទាំងនេះ។ ជាដំបូងគួរតែមានសេចក្តីបញ្ជាក់ពីអត្ថន័យនៃ ផលប្រយោជន៍ប្រកួតប្រជែងជាមុនសិន។ វាមានទស្សនៈទូលំទូលាយជាងផលប្រយោជន៍ប្រៀបធៀប។ ផលប្រយោជន៍ប្រៀបធៀបជាទូទៅសំដៅលើកត្តាអំណោយផលថេរមួយដែលធ្វើឱ្យប្រទេសធ្វើការផលិតដោយប្រើប្រាស់ចំណាយតិចជាងប្រទេសដទៃ។ ជាឧទាហរណ៍នៃផលប្រយោជន៍ប្រៀបធៀបទាំងនេះមានដូចជាកត្តាអំណោយផលធម្មជាតិ (ប្រេងឥន្ធនៈ ដីមានជីជាតិ) ឬកត្តាចំណាយទាប(ប្រាក់ឈ្នួលទាប)។ ផលប្រយោជន៍ប្រៀបធៀបទាំងនេះ ទោះបីជាយ៉ាងណាក៏ដោយ នឹងបាត់បង់ទៅតាមពេលវេលា។ ធនធានធម្មជាតិនឹងបាត់បង់នៅចំនុចណាមួយ ហើយប្រាក់ឈ្នួលទាបនឹងលែងមានតទៅទៀតពេលដែលសេដ្ឋកិច្ចមានការរីកចំរើន។ ផលប្រយោជន៍ប្រៀបធៀបដែលមិនអាចកើតមានសារជាថ្មី នឹងបាត់បង់ក្នុងរយៈពេលវែងមួយ។ ជាឧទាហរណ៍គឺតម្លៃពលកម្មថោកក្នុងវិស័យឧស្សាហកម្ម នៅក្នុងប្រទេសកូរ៉េខាងត្បូង តៃវ៉ាន់ និងហុងកុងក្នុងទសវត្ស ១៩៧០ និង ១៩៨០ ឬប្រទេសចិនក្នុងទសវត្ស ១៩៩០។ បន្តិចម្តងៗ ផលប្រយោជន៍នៃប្រាក់ឈ្នួលទាប គឺរំកិលទៅប្រទេសដទៃទៀតក្នុងតំបន់ ឬក៏ទៅតំបន់ឆ្ងាយពីឆ្នេរដូចជាករណីក្នុងប្រទេសចិន។ ការប្រឈមសំរាប់ឧស្សាហកម្មទាំងនេះ និងសំរាប់ប្រទេសទាំងនេះ គឺមិនមែនទៅលើការរក្សាតម្លៃពលកម្មថោកនោះទេ ប៉ុន្តែលើថាតើត្រូវធ្វើដូចម្តេចទើបមានផលិតភាពជាងនេះ។

ផលប្រយោជន៍ប្រកួតប្រជែងគឺត្រូវបានបង្កើត និងទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្តបន្ទាប់ ដូចនេះវាជាទស្សនៈខ្លាំងក្លាមួយ។ ឧទាហរណ៍ល្បីល្បាញ ទាក់ទងបញ្ហានេះគឺប្រទេសមានផលប្រយោជន៍ប្រកួតប្រជែងមួយចំនួនដូចជាប្រទេសកូរ៉េខាងត្បូង សិង្ហបូរី និងតៃវ៉ាន់ដែលសម្រេចបានដោយសារវិស័យឧស្សាហកម្មដែលពឹងផ្អែកលើជំនាញ។ មិនមានវត្តមានការងារជំនាញនោះទេនៅពេលដែលប្រទេសទាំងនេះស្ថិតក្នុងដំណាក់កាលចាប់ផ្តើមសេដ្ឋកិច្ចរបស់ខ្លួន។ វាទាមទារឱ្យមានការប្រឹងប្រែងខ្លាំងក្លានិងរួមមួយក្នុងការធ្វើផែនការ និងការប្រើប្រាស់ធនធានដើម្បីកសាងធនធានមនុស្សដែលជាតម្រូវការ ហើយតួនាទីរបស់រដ្ឋាភិបាលក្នុងប្រទេសទាំងនេះក្នុងការសម្របសម្រួលបញ្ហានេះ គឺមានសារៈសំខាន់ណាស់ក្នុងការទទួលបានភាពជោគជ័យរបស់ពួកគេ។

ទស្សនៈនៃ គ្រាប់ពេជ្យនៃកំណើន គឺពឹងផ្អែកលើការងាររបស់ Michael Porter។ Porter បរិយាយពីវិធីដែលការប្រមូលផ្តុំនៃសកម្មភាពសេដ្ឋកិច្ចអាចត្រូវបានអនុវត្ត និងអាចជម្រុញការអនុវត្តក្នុងកម្រិតប្រកួតប្រជែងជាអន្តរជាតិ។ នៅក្នុងការងាររបស់Porter វត្តមាននៃទីផ្សារក្នុងស្រុកក៏ជាកត្តាជម្រុញមួយផងដែរ ប៉ុន្តែការបង្កើតនូវឧស្សាហកម្មដែលមានការប្រកួតប្រជែងមិនមែនជាការដាក់លក្ខខណ្ឌនោះទេ យោងទៅតាមជ័យជំនះរបស់ប្រទេសសឹង្ហបូរី និងហុងកុង។ ឧស្សាហកម្មរបស់ពួកគេត្រូវបានបង្កើតឡើងដើម្បីផ្គត់ផ្គង់សំរាប់ទីផ្សារអន្តរជាតិ (គួរឱ្យកត់សម្គាល់គឺសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប) និងការបង្កើតនូវទីផ្សារអ្នកប្រើប្រាស់ក្នុងស្រុកកើតឡើងក្រោយតែប៉ុណ្ណោះ។

នៅក្នុងឧទាហរណ៍ដែលបានបញ្ជាក់ខាងលើ វាជាការច្របាច់បញ្ចូលនៃគោលនយោបាយរដ្ឋាភិបាលឆ្ពោះទៅកាន់ការសម្រេចបាននូវជំនាញ (ការកសាងផែ ឧបករណ៍ដឹងជញ្ជូន) និងគោលនយោបាយសង្គមផ្សេងៗគ្នាដែលជាកត្តាជម្រុញនៃកំណើនផលិតភាពក្នុងវិស័យទាំងនេះ។

ធាតុសំខាន់នៃ "ទស្សនៈគ្រាប់ពេជ្យនៃកំណើន" គឺថាវាជួយក្នុងការផ្តោតសំខាន់ និងសហការគោលនយោបាយជាមួយក្រសួងផ្សេងៗ និងក្នុងវិស័យផ្សេងៗគ្នា។ វាផ្តល់នូវការយកចិត្តទុកដាក់ ទិសដៅអាចត្រូវបានបង្កើត និងភាពជោគជ័យជាប្រវត្តិសាស្រ្តត្រូវបានកំណត់។ រូបភាព ទី ៤.១ ផ្តល់ជាឧទាហរណ៍មួយ។

**រូបភាពទី ៤.១. គ្រាប់ពេជ្រនៃកំណើន និងវិសាលភាពរបស់វា**




នៅលើជ្រុងទាំងប្រាំនៃគ្រាប់ពេជ្យវិស័យគោលនយោបាយសំខាន់ៗត្រូវបានបង្ហាញ។ ក្នុងក្របខណ្ឌយុទ្ធសាស្រ្តរួមបញ្ចូលកិច្ចគាំពារសង្គម និងមុខរបរវិសាលភាពទាំងប្រាំត្រូវបានកំណត់៖ (១) របបវិនិយោគ (២) ការរីកចំរើនហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា (៣) កម្មវិធី និងគម្រោងកិច្ចគាំពារសង្គម ជាសកលនិងបង្កើតឡើងសំរាប់វិស័យជាក់លាក់ (ជាឧទាហរណ៍ គម្រោងធានារ៉ាប់រងសង្គម) (៤) កម្មវិធីទទួលបានជំនាញ (ជាឧទាហរណ៍ កម្មវិធី TVET) និង (៥) របបទំនាក់ទំនងឧស្សាហកម្ម។ ជាមួយគ្នានេះ វិសាលភាពទាំងប្រាំត្រូវបានចាត់ទុកថាជារបៀបវារៈយុទ្ធសាស្រ្តសំរាប់វិស័យជាក់លាក់មួយ។

នៅក្នុងវិសាលភាពនីមួយៗនៃទិសដៅវិសាលភាពទាំងប្រាំ អាចត្រូវបានបង្កើត និងធ្វើការវាស់វែងដំណើរការ។ នេះអាចមើលឃើញក្នុងរូបភាពដែលចំនុចផ្សេងគ្នានៅលើជ្រុងអាចជាព្រឹត្តការណ៍ជាប្រវត្តិសាស្រ្ត ជាឧទាហរណ៍ត្រូវបានបញ្ចូលក្នុងផែនទីបង្ហាញផ្លូវ។ បន្តិចម្តងៗ ពេលដែលព្រឹត្តការណ៍ជាប្រវត្តិសាស្រ្តទាំងនេះបានសម្រេច គ្រាប់ពេជ្រនៃកំណើនកាន់តែរីកធំឡើង។

## ៤.៤. ការបង្កើតយុទ្ធសាស្ត្រជាតិមុខរបរ និងការងារ

ការបង្កើតយុទ្ធសាស្ត្រជាតិមុខរបរ និងការងារអាចអនុវត្តតាមនីតិវិធីវដ្តគោល នយោបាយដូចដែលបានបញ្ជាក់ក្នុងរូបភាព ៤.២ ខាងក្រោម។

**រូបភាពទី ៤. ២. វដ្តគោលនយោបាយមុខរបរ**




ជំហានទីមួយក្នុងការបង្កើត NES

ជំហានមួយក្នុងចំណោមជំហានដំបូងក្នុងការបង្កើតយុទ្ធសាស្ត្រជាតិមុខរបរ និងការងារគឺជាការកំណត់នូវ៖

- វិស័យសេដ្ឋកិច្ចដែលអាចត្រូវបានអភិវឌ្ឍន៍ក្នុង គ្រាប់ពេជ្យនៃកំណើន។ នេះទាមទារឱ្យមានការសំរេចចិត្តលើកម្រិតផែនការថ្នាក់ជាតិ (MOP/MEF/SNEC) ហើយគួរតែផ្សារភ្ជាប់ជាមួយនិងរបៀបវារៈផែនការបញ្ច្រាបះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ និងរចនាសម្ព័ន្ធសម្របសម្រួលដែលបានបង្កើតក្រោម ក្របខណ្ឌ នោះ
- ទាមទារនូវការវាយតម្លៃចំពោះវិស័យទាំងនេះ ដែលនេះជាធាតុផ្សំបន្ទាប់។ ធាតុផ្សំនៅក្នុងវាយតម្លៃតម្រូវការនេះនឹងត្រូវបានបញ្ជាក់ខាងក្រោម
- តួអង្គពាក់ព័ន្ធ ដែលនេះជាធាតុផ្សំទី ៣ ដ៏សំខាន់មួយដែលរួមមានក្រសួងខ្សែបណ្ដោយ ក្រុមប្រឹក្សាសម្របសម្រួល (ជាឧទាហរណ៍ CARD សំរាប់វិស័យកសិកម្ម) ដៃគូសង្គម និងប្រហែលជាអង្គការដទៃទៀត។
- សូចនាករដែលអាចប្រើប្រាស់ដើម្បីតាមដានដំណើរការ និងលទ្ធផល

ការវាយតម្លៃតម្រូវការរួមបញ្ចូល៖

- លក្ខខណ្ឌបច្ចេកវិទ្យាដែលអំណោយផលៈ តើអ្វីជាកង្វះហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យាពេលបច្ចុប្បន្ននៅក្នុងវិស័យ? តើមានការទាមទារអ្វីខ្លះដើម្បីភ្ជាប់គម្លាតទាំងនេះ និងជម្រុញឱ្យវិស័យទទួលបាននូវសក្តានុពលរបស់ខ្លួន?
- លក្ខខណ្ឌសេដ្ឋកិច្ចដែលអំណោយផលៈ តើអ្វីជាបរិយាកាសវិនិយោគពេលបច្ចុប្បន្ន តើមានវិធានការលើកទឹកចិត្ត និងសន្តិសុខអ្វីដើម្បីទាក់ទាញអ្នកវិនិយោគទុនក្នុងស្រុក និងបរទេសនៅក្នុងវិស័យ? តើមានការលើកទឹកចិត្តសហគ្រិនយ៉ាងដូចម្តេច? តើមានវិធានការអ្វីដើម្បីដោះស្រាយឧបសគ្គឥណទាន?
- ឧបសគ្គច្បាប់ និងស្ថាប័នៈ តើអ្វីជាឧបសគ្គពាក់ព័ន្ធនឹងនីតិបញ្ញត្តិ និងអង្គការស្ថាប័នដែលរាំងស្ទះដល់ការប្រើប្រាស់នូវធនធានដែលត្រូវការ?
- តម្រូវការសង្គមៈ តើអ្វីជាភាពងាយរងគ្រោះក្នុងវិស័យជាក់លាក់នេះ? តើអ្វីជាលក្ខខណ្ឌការងារគ្រោះថ្នាក់? តើមានវិធានការអ្វីដើម្បីបង្កើតស្តង់ដារការងារសមរម្យក្នុងវិស័យនេះ?
- តម្រូវការធនធានមនុស្សៈ តើអ្វីជាជំនាញដែលត្រូវការ និងតើអ្វីជាគម្លាតនៅក្នុងបញ្ហានេះ?

| | |
|---|---|
| ជាបន្ទាប់ ផែនទីគោចរពិស្តារនឹងត្រូវពង្រាងឡើង | អនុវត្តតាមការកំណត់នៃតម្រូវការនេះ នឹងមានការពង្រាងនូវផែនទីបង្ហាញផ្លូវមួយដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ ហើយផែនទីនេះអាចត្រូវបានពិភាក្សាជាមួយភាគីពាក់ព័ន្ធ និងបញ្ចូលក្នុងផែនការប្រតិបត្តិជាមួយនឹងសកម្មភាពសំរាប់តួអង្គផ្សេងៗ។<br><br>វាជាដំបូន្មានក្នុងការបង្កើតគណៈកម្មាធិការជាក់លាក់សំរាប់វិស័យ ឬ ផែនការ ដែលរួមមានការចូលរួមពីអ្នកតំណាងមកពីក្រសួងខ្សែបណ្តោយ និងដៃគូសង្គមដើម្បីអនុវត្ត/សម្របសម្រួល ការវាយតម្លៃតម្រូវការនេះ។ |
| និងកម្មវិធីនយោបាយដ៏មានប្រសិទ្ធភាពសម្រាប់បង្កើតកិច្ចសន្ទនាសង្គម | វាមានសារៈសំខាន់ណាស់ក្នុងការមានផែនការដ៏មានប្រសិទ្ធិភាពមួយសំរាប់កិច្ចសន្ទនាសង្គម។ អ្នកតំណាងដែលចូលរួមក្នុងផែនការត្រូវមានអាណត្តិច្បាស់លាស់។ ដែលនេះតម្រូវឱ្យមានប្រព័ន្ធនៃស្ថាប័នតំណាងផ្សេងៗ។ កម្រិតសមរម្យនៃស្ថាប័នគឺគួរតែកម្រិតវិស័យ។ |
| ធាតុផ្សំនៃ NES | យុទ្ធសាស្ត្រជាតិមុខរបរ និងការងារ ដែលជាវិធីសាស្ត្រស៊ីសង្វាក់ឆ្ពោះទៅកាន់គោលដៅនៃការសម្រេចបាននូវការងារពេញលេញ និងមានផលិតភាព នឹងគ្របដណ្តប់លើវិស័យខាងក្រោមៈ<br><br>- បទប្បញ្ញត្តិគាំពារមុខរបរ និងការងារ (EPL) |

- ទំនាក់ទំនងឧស្សាហកម្ម
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ (TVET)
- គោលនយោបាយទីផ្សារការងារសកម្ម
- វិធានការបន្ធូរបន្ថយពន្ធ
- ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា
- វិធានការម៉ាក្រូសេដ្ឋកិច្ច

យុទ្ធសាស្ត្រជាតិមុខរបរ និងការងារមិនមែនជាអ្នកនាំមុខក្នុងការបង្កើតនូវគោលនយោបាយនៅក្នុងវិស័យទាំងអស់នេះទេ។ ជាពិសេសនៅក្នុងវិស័យបីចុងក្រោយៈ ការបន្ធូរបន្ថយពន្ធ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា វិធានការម៉ាក្រូសេដ្ឋកិច្ច យុទ្ធសាស្ត្រជាតិមុខរបរ និងការងារគ្រាន់តែទាមទារក្នុងការធានាថាវាស្របទៅនឹងការអភិវឌ្ឍន៍ដែលត្រូវបានផ្តួចផ្តើមនៅក្នុងវិស័យផ្សេង។
ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ ផ្តល់នូវក្របខណ្ឌផែនការជារួម។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងវិស័យដទៃ (EPL ទំនាក់ទំនងឧស្សាហកម្ម កម្មវិធីការបណ្តុះបណ្តាលវិជ្ជាជីវៈ ALMPs) យុទ្ធសាស្ត្រជាតិមុខរបរគឺឈានមុខក្នុងការបង្កើតផែនការ។

**សូចនាករសម្រាប់ការតាមដាន**

សំរាប់វិស័យនីមួយៗនៃវិស័យទាំងនេះនៃយុទ្ធសាស្ត្រជាតិមុខរបរ និងការងារ ទាមទារឱ្យមានការកំណត់សូចនាករ ។ សូចនាករទាំងនេះត្រូវតែ SMART ( ច្បាស់លាស់ អាចវាស់វែងបាន អាចទទួលបាន ពាក់ព័ន្ធ និងទាន់ពេលវេលា)។

បញ្ហាសំខាន់នៃទស្សនៈរបស់យុទ្ធសាស្ត្រជាតិមុខរបរ និងការងារ នឹង(យ៉ាងហោចណាស់ ) ត្រូវអនុវត្តតាមកម្រងសូចនាករដូចខាងក្រោម៖

- ចំណែកនៅក្នុងប្រជាជនដែលមានអាយុបំរើការងារហើយអសកម្មផ្នែកសេដ្ឋកិច្ច
- ចំណែកក្នុងកំលាំងពលកម្មដែលចុះបញ្ជីជាអ្នកដែលគ្មានការងារធ្វើ
- ចំណែកនៃការងារវិស័យមិនរៀបរយក្នុងការងារសរុប
- ចំណែកក្នុងកំលាំងពលកម្មដែលដែលចុះបញ្ជីថា(ប្រហែលជាមិនផ្លូវការ)ជាអ្នកខ្វះការងារធ្វើ
- ចំនួននៃជនក្រីក្រប្រកបការងារ
- តុល្យភាពយេនឌ័រក្នុងវិស័យរៀបរយ (ក្នុងកម្រិតប្រាក់ចំណូល និងលក្ខខណ្ឌការងារ)

- វិធានការមួយចំនួននៃការប្រាក់ចំណូលជាក់ស្តែង ជាឧទាហរណ៍ភាពខុសគ្នានៃ ចំនួនប្រាក់ចំណូលមុខពេលកាត់ពន្ធ
- វិធានការមួយចំនួននៃផលិតភាព ឬក៏កំណើនផលិតភាព (ជាមួយនឹងការញែកឱ្យដាច់តាមវិស័យ)
- ចំនួនកុមារ(អាយុក្រោម ១៥ឆ្នាំ) ដែលកំពុងបំរើការងារ
- សមាមាត្រចុះឈ្មោះចូលរៀននៅកម្រិតអប់រំផ្សេងៗ
- ចំនួនប្រជាជនដែលមានជំនាញបណ្តុះបណ្តាល
- ចំនួននៃ (ក្នុងស្រុកនិងអន្តរជាតិ) ពលករទេសន្តប្រវេសន៍
- ចំនួននៃជម្លោះឧស្សាហកម្ម(ជាមួយការញែកឱ្យដាច់តាមវិស័យ)
- ចំនួននៃពលករដែលនៅក្រោមកិច្ចសន្យាការងាររួម

The ភាគបែងទូទៅ ក្រោមសូចនាករទាំងនេះ គឺថាសូចានាករៀបរាប់អំពី បរិមាណ និង/ឬ គុណភាពការងារ។ ដូចនេះ ទាំងនេះជា សូចនាករអនុវត្តគន្លឹះ សំរាប់យុទ្ធសាស្ត្រជាតិមុខរបរ និងការងារ។ម្យ៉ាងទៀត ជាមួយនឹងសូចនាករទាំង ១៥ នេះ (ឧទាហរណ៍សូចនាករទាំងនេះត្រូវបានបញ្ចូលវិធានការ SMART) ជោគជ័យនៃយុទ្ធសាស្ត្រជាតិមុខរបរ និងការងារអាចត្រូវបានតាមដាន។ ជំពូកទី ៧ នឹងបរិយាយសូចនាករទាំងនេះបន្ថែមទៀត។

## ជំពូកទី ៥ កម្មវិធីទម្រង់កិច្ចគាំពារសង្គម ALMPs និងការធានារ៉ាប់រងសង្គម

### ៥.១. សេចក្តីផ្តើម

កំណែទម្រង់អ័ក្សដេក និងឈរ

សិទ្ធិក្នុងការទទួលបានសន្តិសុខសង្គមត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ សន្តិសុខសង្គមត្រូវបានចាត់ទុកថាជាគ្រឹះសំរាប់កសាងសង្គមមួយដែល មានជម្លោះតិចតួច មានភាពស៊ីសង្វាក់គ្នា និងរួមបញ្ចូលមួយ។ រាជរដ្ឋាភិបាល និងដៃគូសង្គមក្នុងប្រទេសកម្ពុជាបានទទួលស្គាល់នូវតម្រូវការកំណែទម្រង់សន្តិសុខសង្គមដែលនឹងបំពេញតម្រូវការសេដ្ឋកិច្ច និងសង្គម ដោយប្រើប្រាស់មូលដ្ឋានធនធានដែលមាន។

ការពង្រីកសន្តិសុខសង្គមទៅដល់ពលករក្នុងវិស័យមិនរៀបរយ និងក្រុមគ្រួសាររបស់ពួកគេត្រូវបានចាត់ថាជាការសំខាន់ក្នុងបរិបទនេះ។ នេះអាចត្រូវបានចាត់ទុកថាជាវិសាលភាពអ័ក្សដេកក្នុងវិធីសាស្ត្រវិសាលភាពដើម្បីពង្រីកការវិសាលភាពសន្តិសុខសង្គមនៅក្នុងប្រទេសកម្ពុជា។ វិសាលភាពអ័ក្សដេកនេះទទួលយកគំនិតនៃ ទម្រង់កិច្ចគាំពារសង្គម ដែលរួមមាននូវចង្កោមនៃគម្រោងកិច្ចគាំពារសង្គមដែលផ្តល់ (i) លទ្ធភាពជាសកលក្នុងការទទួលបានផលប្រយោជន៍ថែទាំសុខភាពជាមូលដ្ឋាន/ជាចំបង (ii) ផលប្រយោជន៍កុមារ/ស្ត្រី ដែលមានគោលបំណងក្នុងការសម្របសម្រួលលទ្ធភាពក្នុងការទទួលបានជីវជាតិ ការអប់រំ និងការថែទាំ (iii) ការគាំទ្រប្រាក់ចំណូលដែលបានកំណត់សំរាប់អ្នកក្រីក្រដែលមិនបំរើការងារក្នុងក្រុមអាយុសកម្ម និង(iv)ការរៀបចំមួយចំនួនដែលផ្តល់ផលប្រយោជន៍សោធននិវត្តដល់ចាស់ជរា និងជនពិការ។

ជាការពិត ការរៀបចំកិច្ចគាំពារសង្គមមួយចំនួនគឺមានរួចជាស្រេចក្នុងប្រទេសកម្ពុជាពេលបច្ចុប្បន្ននេះ។ ការប្រឈមក្នុងវិធីសាស្ត្រអ័ក្សដេកគឺជាការបញ្ចូលកម្មវិធីបច្ចុប្បន្នទៅក្នុងក្របខណ្ឌដែលមានភាពស៊ីសង្វាក់មួយ និងក្នុងការតាមដាន និងដោះស្រាយជាមួយកញ្ចប់ទាំងនោះ (ក្រុមជនជាតិ តំបន់ សង្គម) ដែលមិនមានការគ្រប់ដណ្តប់ដោយកម្មវិធីដែលមានស្រាប់ណាមួយ។ ភាគច្រើននៃអ្វីដែល NSPS បានបរិយាយក្នុងជំពូកទី ៥ របស់ឯកសារនេះទាក់ទងនឹងគោលដៅ និងឧបករណ៍រយៈពេលមធ្យម និងក្នុងជំពូកទី៦ ទាក់ទងនឹងការអនុវត្ត និងតាមដានការខិតខំប្រឹងប្រែងបង្ហាញពីវិធីសាស្ត្រអ័ក្សដេក។

រូបភាពទី៥ ភាពជាន់គ្នារវាង NSPS និង NES




ALMPs ៖ ការភ្ជាប់រវាង NSPS និង NES

គោលដៅទី ៥នៅក្នុង NSPS ៖ "ផ្តល់ឱកាសការងារដល់អ្នកក្រីក្រដែលមានអាយុបំរើការងារ និងជនងាយរងគ្រោះ" មិនបានបញ្ជាក់នៅក្នុង ទស្សនៈ SPF ទេ។ ជាការពិត វានៅក្នុងតារាងនៃវិធានការ ALMP ជាឧទាហរណ៍៖ កម្មវិធីសំណង់សាធារណៈ និង កម្មវិធី TVET ដែល NSPS ផ្សារភ្ជាប់ (ជាន់គ្នា)ជាមួយនឹង NES (សូមមើលរូប ៥ ១ ខាងលើ)។

ការធានារ៉ាប់រងសង្គម - វិសាលភាពអ័ក្សឈរ

វិសាលភាពទី ២ គឺជាការពង្រីកអ័ក្សឈរនៃវិសាលភាពការធានារ៉ាប់រងសង្គម។ ការពង្រីកអ័ក្សឈរនេះត្រូវបញ្ជាក់ក្នុង NSPS ជាគោលដៅរយៈពេលវែង។ អនុសញ្ញា ILO លេខ១០២ (C១០២) ផ្តល់នូវមាគ៌ាក្នុងបរិបទនេះ។ មកដល់ពេលបច្ចុប្បន្ន មាន

គម្រោងកិច្ចគាំពារសង្គមមួយចំនួនក្រោម NSSF និង NSSFC ហើយមានផែនការសំរាប់ការពង្រីកបន្ថែមក្នុងអនាគតមធ្យម។

## ៥.២.វិសាលភាពអ័ក្សដេកៈ ទម្រង់កិច្ចគាំពារសង្គម

កំណែទម្រង់អ័ក្សដេក

ដំណើរការកំនែទម្រង់ជាមួយនឹង "វិសាលភាពអ័ក្សដេក" នឹងរួមបញ្ចូលការច្របាច់បញ្ចូលនូវ "ចង្កោមតូចៗ និងជាមូលដ្ឋាននៃការធានាកិច្ចគាំពារសង្គម" សមស្រប និងអាចធ្វើទៅរួចក្នុងលក្ខខណ្ឌថ្នាក់ជាតិដែលបានផ្តល់។ ត្រូវបានចាត់ទុកថាជា "ទម្រង់កិច្ចគាំពារសង្គម" ដែលនេះរួមបញ្ចូលនៃកញ្ចប់អប្បបរមាមួយនៃសិទ្ធិ ការផ្ទេរប្រាក់ និងសេវាកម្ម ដែលត្រូវបានធានាដោយរដ្ឋ។ កញ្ចប់នៃផលប្រយោជន៍នេះនៃផលប្រយោជន៍នេះគួរតែត្រូវបានផ្តល់ជូនដល់អ្នកទទួលផលប្រយោជណ៍ជាចំបងដោយមិនខ្វល់ពីឋានៈ ជនជាតិ ឬក៏ស្ថានភាពសង្គមសេដ្ឋកិច្ច ឬក៏ទីតាំងភូមិសាស្ត្ររបស់ពួកគេនោះទេ។ វាគួរតែត្រូវបានផ្តល់លទ្ធភាពដល់ប្រជាជនក្នុងវិស័យមិនរៀបរយ និងអ្នកដែលមិនត្រូវបានគ្របដណ្តប់ប្រព័ន្ធដែលមានស្រាប់។ ដូចនេះទម្រង់រួមមានការអន្តរាគមន៍សំខាន់ៗមួយចំនួនដែលគួរតែជាសកលក្នុងការគ្របដណ្តប់ និងជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលតែមួយគត់ក្នុងការផ្តល់ហិរញ្ញប្បទានចំពោះកញ្ចប់នេះ។ NSPS បានកំណត់គោលដៅចំនួន ៥ ក្នុងការកំណត់ទម្រង់កិច្ចគាំពារសង្គមសំរាប់ប្រទេស។ ការអន្តរាគមន៍នេះមិនមែនថ្មីទាំងស្រុងនោះទេ។ អ្វីដែលជាសំណើគឺថាជាការច្របាច់បញ្ចូល និងការពង្រីកនៅក្នុងការគ្របដណ្តប់របស់កម្មវិធីដែលមានស្រាប់។ កញ្ចប់នេះរួមមានៈ

- ជំនួយសង្គមទៅដល់ជនចាស់ជរា ស្ត្រីមេម៉ាយ ជនពិការ និងក្រុមជនជាតិភាគតិច
- ជំនួយកិច្ចគាំពារកុមារជាសកល
- ទទួលបានការអប់រំដោយមិនចាំបាច់បង់ថ្លៃរហូតដល់ថ្នាក់ទី ១២ នៅក្នុងសាលា (រដ្ឋាភិបាល)សហគមន៍
- សេវាថែទាំសុខភាពមូលដ្ឋានដោយមិនចាំបាច់បង់ថ្លៃសេវា និង
- គម្រោងធានាការងារ

ទម្រង់ដែលបានស្នើនេះមិនត្រឹមតែស្របគ្នាជាមួយទម្រង់កិច្ចគាំពារសង្គមដូចដែលបានលើកកម្ពស់ដោយ ILO និងស្ថាប័ន UN ដទៃទៀត និងដូចដែលបានបញ្ជាក់នៅក្នុងផ្នែក ២.៦ ខាងលើនោះទេ ប៉ុន្តែថែមទាំងសមស្របនៅក្នុងបរិបទប្រទេសកម្ពុជា។ ប្រសិនជាបន្តដោយឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្ត កញ្ចប់នេះអាចនាំមកនូវភាព

ខុសប្លែកមួយក្នុងការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះក្នុងប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ភាគច្រើនគឺពឹងផ្អែកទៅលើទំហំនៃផលប្រយោជន៍ និង គុណភាពនៃសេវាកម្មដែលអាចទទួលបានដោយទម្រង់កិច្ចគាំពារសង្គម។ វានៅតែ មានការទាមទារឱ្យមានការធ្វើកិច្ចការជាច្រើនទៀតក្នុងវិស័យនេះ។ រូបភាពទី ៤.៣. បង្ហាញពីស្ថានភាពពេលដែលទម្រង់កិច្ចគាំពារសង្គមសំរាប់ប្រទេស កម្ពុជាត្រូវបានបង្កើត។

**៥.៣. កម្មវិធីសំណាញ់សន្តិសុខសង្គមសំរាប់ជនក្រីក្រ និងជនងាយរងគ្រោះ**

កម្មវិធីប្រភេទទាំង ៥

នៅក្នុង NSPS ក្រោមគោលដៅទី២ និងទី ៥ បានកំណត់ប្រភេទទាំងប្រាំនៃកម្មវិធី៖

- កម្មវិធីផ្តល់ស្បៀងអាហារដែលបានកំណត់ទិសដៅ
- សេវាសុខភាព (ជាចំបងការត្រួតពិនិត្យសុខភាព និងការព្យាបាលតិចតួច)
- ការផ្តល់ការអប់រំ (លិខិតបញ្ជាក់មិនចាំបាច់បង់ថ្លៃ និងអាហាររូបករណ៍)
- កម្មវិធីផ្តល់ជាសាច់ប្រាក់សង្គម
- បញ្ជូនបន្ត ក្នុងករណីនៃភាពងាយរងគ្រោះជាន់គ្នា

រដ្ឋបាលមូលដ្ឋាននៅក្រោមក្របខណ្ឌជាតិ

កម្មវិធីទាំងនេះទាមទារគួរតែត្រូវបានផ្តល់ជូនដល់បុគ្គល និងគ្រួសារក្រីក្រ និងងាយ រងគ្រោះ ដែលនេះជាសំណើដែលស្ថាប័នពិតប្រាកដនឹងអនុវត្តការងារនេះក្នុងកម្រិត មូលដ្ឋាន (សហគមន៍)។ ទោះបីជាយ៉ាងណាក៏ដោយ ជាដំបូងគួរតែមាននូវក្របខណ្ឌ គោលនយោបាយជាតិមួយដើម្បីធានាភាពស៊ីសង្វាក់គ្នា និងការផ្តល់ជូនដោយសម ធម៌ទូទាំងប្រទេស។ ជំពូកទី ៦ នឹងបង្ហាញពីបញ្ហានេះ។

ការសិក្សាកម្មវិធី

ចំនុចនៃការបង្កើតកម្មវិធីអាចជាចំនុចខាងក្រោម៖

- គម្រោងជំនួយសង្គមតាមលំដាប់ថ្នាក់មួយ ជាមួយនឹងផលប្រយោជន៍ច្រើន ជាងពេល ដែលមានកុមារ និងកាន់តែច្រើនថែមទៀតពេលដែលកុមារទាំង នេះកំពុងសិក្សាក្នុងសាលាឬមហាវិទ្យាល័យ
- ជំនួយសង្គមនឹងត្រូវបានផ្តល់ទៅតាមមូលដ្ឋានបុគ្គល (ទៅដល់សមាជិក ពេញវ័យនៃក្រុមគ្រួសារ) ដើម្បីធានាថាសាច់ប្រាក់មិនត្រូវទទួលបានទាំង ស្រុងដោយមេគ្រួសារដែលជាបុរស។
- ផ្នែកនៃជំនួយសង្គមត្រូវបានផ្តល់ជូនជារបស់ (ជាឧទាហរណ៍ លិខិតបញ្ជាក់ មិនចាំបាច់បង់ថ្លៃ)ដើម្បីធានាថាវាត្រូវបានចំណាយសំរាប់គោលបំណងត្រឹម ត្រូវ (ចំណីអាហារ សុខភាព ការអប់រំ)
- សោធននិវត្តសង្គម (ដែលជា៖ មិនមានលក្ខខណ្ឌចំពោះការងារដែលមាន) សំរាប់ក្រុមចាត់តាំង (ចាស់ជរា និងជនពិការ)

- ការបង្កើតនូវការគ្រប់គ្រងករណីបុគ្គល (ប្រហែលជាក្នុងការសាកល្បងចំនួនបីបួនដងជាមុនសិន) ដើម្បីដោះស្រាយបញ្ហា វិសាលភាពចំរុះ (ការជាន់គ្នានៃភាពងាយរងគ្រោះ) និង បញ្ជូនបន្ត រវាងសេវាកម្មផ្សេងគ្នា

## ៥.៤. ALMPs និងការបណ្តុះបណ្តាលវិជ្ជាជីវៈ

កម្មវិធីប្រភេទទាំង ២

នៅក្នុង NSPS ក្រោមគោលដៅទី ៣ បានកំណត់ប្រភេទកម្មវិធីចំនួនពីរៈ

- សំណង់សាធារណៈ (PWPs)
- ការបណ្តុះបណ្តាល និងការអប់រំវិជ្ជាជីវៈដែលបានកំណត់ទិសដៅ (TVET)

TVET ៖ ការរៀបចំ និងកម្មវិធីបច្ចុប្បន្ន

គោលដៅនៃ TVET គឺការកាត់បន្ថយភាពក្រីក្រតាមរយៈការផ្តល់ការបណ្តុះបណ្តាលជំនាញ និងលើកកម្ពស់ផលិតភាព។ ក្រសួងការងារ បានចាត់តាំងអគ្គនាយកដើម្បីទទួលខុសត្រូវចំពោះការធ្វើផែនការកម្មវិធី និងគ្រប់គ្រង TVET ហើយមានការសហការ និងរចនាសម្ព័ន្ធធានាគុណភាពជាមួយនឹងការដឹកនាំដោយក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល និង DGTVET និងភ្នាក់ងារជាតិមុខរបរ និងការងារជាស្ថាប័នធ្វើផែនការ និងប្រតិបត្តិ។ មាននូវគោលបំណងសំខាន់ចំនួន ២៖ (១) ផ្តល់ជំនាញជាមូលដ្ឋានសំរាប់អ្នកក្រីក្រជនបទ និង(២) ផ្តល់ជំនាញកម្រិតខ្ពស់ឆ្លើយតបនឹងតម្រូវការ សំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្ម។

ភាពប្រឈមទាំង ៧ នៃ TVET

កម្មវិធីរួមមានទាំងវគ្គបណ្តុះបណ្តាលផ្លូវការដែលមានជាវិញ្ញាបនប័ត្រ ឬសញ្ញាប័ត្រ និងវគ្គបណ្តុះបណ្តាលមិនផ្លូវការមួយចំនួន។ ការប្រឈមដំបូងរបស់TVET គឺតើថាវាមានភាពទាក់ទាញយ៉ាងណាចំពោះសិស្សនិស្សិតថាជាជំហានឈានឡើងក្នុងការទទួលបានការបានប្រាក់ចំនូល និងផលិតភាពខ្ពស់។ ជាក់ច្បាស់ណាស់នេះជាបញ្ហាមួយក្នុងពេលបច្ចុប្បន្ន។ តម្លៃនៃសញ្ញាបត្រ ឬវិញ្ញាបនបត្ររបស់ TVET មិនត្រូវបានចាត់ទុកថាមានតម្លៃស្មើទៅនឹងសញ្ញាបត្រសិក្សានោះទេពីទស្សនៈរបស់និស្សិត ខណៈពេលដែលទស្សនៈពីឧស្សាហកម្មគឺថា TVET មានតម្លៃខ្ពស់ នេះដោយសារ TVET មិនមែនជាជំនាញវិស្វកម្ម បច្ចេកទេស និងការបណ្តុះបណ្តាលដែលបង្រៀនដោយមហាវិទ្យាល័យ។ ទីពីរ ការប្រឈមគឺការបង្កើតផ្លូវផ្គងប្រសើរឡើងរវាងជំនាញដែលផ្គត់ផ្គង់ និងជំនាញដែលត្រូវការ។ របាយការណ៍របស់ធនាគារពិភពលោកពេលថ្មីៗនេះក្នុងការផ្តល់ជំនាញ ចង្អុលបង្ហាញថាមានការផ្គូរផ្គងមិនស៊ីសង្វាក់គ្នាជាចំបងនៅក្នុងវិស័យនេះ។ ការប្រឈមទី ៣ គឺនៅក្នុងកម្មវិធីដែលបង្រៀនជំនាញសហគ្រិនដែលមានសារៈសំខាន់ក្នុងការចាប់ផ្តើម SMEs ដែលនេះជាអាទិភាពមួយក្នុងចំណោមអាទិភាពរបស់ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-

២០១៣។ ការប្រឈមទី ៤ គឺការបង្កើតលទ្ធភាពទូលំទូលាយក្នុងការទទួលបានវគ្គបណ្តុះបណ្តាលនៅគ្រប់កម្រិតថ្នាក់ជាតិ ដែលនេះអាចធ្វើទៅបានតាមរយៈការពង្រីកកម្មវិធីដែលមានស្រាប់ (បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលបន្ថែមទៀតនៅថ្នាក់ខេត្ត) ឬក៏តាមរយៈការបង្កើតកម្មវិធី និងសម្ភារៈសិក្សាពីចំងាយ។ ទី ៥ ការប្រឈមអាចជាការផ្តល់ជូនអ្នកដែលបោះបង់ការសិក្សានូវជំនាញបណ្តុះបណ្តាលជាមូលដ្ឋាន ដើម្បីឱ្យពួកគេអាចកក់កន្លែងមួយនៅក្នុងទីផ្សារការងារ។ ទី ៦ ទាមទារឱ្យមានការកម្មវិធីសិក្សាអស់មួយជីវិត។ ជាចុងក្រោយការប្រឈមគឺថាការបង្កើត កម្មវិធី TVET ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ឧស្សាហកម្មជាអាទិភាព (គ្រាប់ពេជ្យនៃកំណើនដែលបានបញ្ជាក់ក្នុងជំពូកទី ៨)។

ភារកិច្ចសម្រាប់ NEA

ការបង្កើតភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) កាលពីពេលថ្មីៗនេះ គឺមានតួនាទីប្រតិបត្តិយ៉ាងចំបងមួយ។ NEA ទទួលខុសត្រូវក្នុងការផ្គូរផ្គងការផ្គត់ផ្គង់និងតម្រូវការដែលនេះរួមបញ្ចូលៈ ការកំណត់គំរោងហេដ្ឋារចនាសម្ព័ន្ធ ក្នុងការសហការជាមួយក្រសួងទទួលបន្ទុក និងសមត្ថកិច្ចថ្នាក់តំបន់ឬមូលដ្ឋាន បន្ថែមជាមួយការកំណត់អត្តសញ្ញាណបុគ្គលដែលមានគុណវឌ្ឍិសំរាបចុះឈ្មោះក្នុង PWP ក្នុងការសហការជាមួយភ្នាក់ងារផលប្រយោជន៍ (ជាឧទាហរណ៍រដ្ឋបាលមូលដ្ឋាន) កំណត់តម្រូវការជំនាញតាមវិស័យក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគតក្នុងការសហការជាមួយសហជីព និងសមាគមនិយោជក ថែមទាំងកំណត់អត្តសញ្ញាណស្ថាប័នអប់រំដែលអាចផ្តល់កម្មវិធីលើកម្ពស់ជំនាញដែលជាទិសដៅ។

បច្ចេកវិទ្យាព័ត៌មានសម្រាប់តាមដានដំណើរ

NEA គួរតែមានប្រព័ន្ធ IT មួយសំរាប់តាមដានដំណើររបស់អតិថិជននីមួយៗ និងបង្កើតព័ត៌មានគ្រប់គ្រង (លើការចំណាយ ការងារដែលបានសម្រេច និងលទ្ធផល) ក្នុងកម្រិតប្រមូលផ្តុំមួយ។

ចុះកិច្ចសន្យាបន្តជាជម្រើសមួយ

ជម្រើសមួយក្នុងការស្វែងរកអាចជាការចុះកិច្ចសន្យាបន្តនៃកម្មវិធីទៅឱ្យស្ថាប័នដែលមិនស្វែងរកចំនេញ ឬក៏អាចទៅឱ្យអ្នកផ្តល់សេវាមានលក្ខណៈពាណិជ្ជកម្ម។ NEA បន្ទាប់មកដើរតួជាអន្តរការីនៃសេវាកម្ម និងនៅតែទទួលខុសត្រូវចំពោះការសហការ និងគុណភាពសេវាកម្ម។ ប្រទេសអូស្ត្រាលី សហរដ្ឋអាមេរិក និងប្រទេសមួយចំនួនទៀតនៅក្នុងសហគមន៍អឺរ៉ុបមានបទពិសោធន៍ជាមួយនឹងគំរូសេវាកម្មនេះ។ ហេតុផលសំរាប់ប្រទេសកម្ពុជាគឺថាវាប្រើប្រាស់ពេលវេលាតិចតួចក្នុងការចុះកិច្ចសន្យាជំនាញដែលត្រូវការ ជាជាងការអភិវឌ្ឍន៍ជំនាញទាំងនេះ។ បើសិនជាមានការសម្រេចចិត្តក្នុងការទទួលយកវិធីសាស្ត្រនេះ វានឹងទាមទារឱ្យមានការកសាងសមត្ថ

ភាពជាក់លាក់ចំពោះ NEA អំពីជំនាញអន្តរការី (ការសសេរលិខិតអញ្ជើញ សំណើកិច្ចសន្យា និងការគ្រប់គ្រងកិច្ចសន្យា ។ល។)។

ការសិក្សាកម្មវិធី

ខាងក្រោមអាចជាចំនុចនៃការបង្កើតកម្មវិធី ALMP៖

- ជំនួយសង្គមសំរាប់អាយុដែលបំរើការងារត្រូវតែភ្ជាប់ជាមួយលក្ខខណ្ឌ បុគ្គលត្រូវទទួលការអប់រំ ទទួលខុសត្រូវក្នុងការចិញ្ចឹមកូនតូចៗ មានការបញ្ជាក់អះអាងពីពេទ្យថាអសមត្ថភាពការងារ ឬបើមិនដូចនេះទេអាចចូលរួមសំណង់ការងារសាធារណៈក្នុងគោលបំណងមានសិទ្ធិក្នុងការទទួលបានផលប្រយោជន៍ជំនួយសង្គម។
- កិច្ចសន្យារដ្ឋាភិបាលជាមួយក្រុមហ៊ុនសាងសង់ អ្នកផ្តល់សេវាសាធារណៈនឹងមានកំណត់នូវ ខស្តង់ដារដែលអនុញ្ញាតឱ្យមានវគ្គហ្វឹកហ្វឺន និងឱកាសការងារសំរាប់ជំនាញទាប ចំពោះអ្នកទទួលជំនួយសង្គម។
- ការបង្កើតមូលនិធិបំរុងសំរាប់ TVET ជាមួយការផ្តល់សិទ្ធិទៅដល់អ្នកផ្តល់សេវាកម្មការងារ ភ្នាក់ងារផលប្រយោជន៍ និងនិយោជក។
- នឹងមានការបែងចែកអាហារូបករណ៍សំរាប់ការអប់រំជាន់ខ្ពស់៖ សម្រាប់ការសិក្សាយុទ្ធសាស្ត្រ (ជាឧទាហរណ៍ ការសិក្សាពីវិស័យកសិកម្ម និងវិស្វកម្ម) អាហារូបករណ៍នឹងធូរលុងជាងការសិក្សាមានលក្ខណៈយុទ្ធសាស្ត្រតិចតួច។

### ៥.៥. សុខភាពសង្គម

អភិក្រមទាំង ៤

នៅក្នុង NSPS ក្រោមគោលដៅទី ៤ បានកំណត់វិធីសាស្ត្រចំនួន ៤ ដូចខាងក្រោម៖

- ការមិនយកថ្លៃពីអ្នកប្រើប្រាស់
- HEFs
- CBHI
- គម្រោងធានារ៉ាប់រងសុខភាពក្រោម NSSI និង NSSI-C

ជាពិសេស HEFs ត្រូវបានអនុវត្តនាពេលបច្ចុប្បន្ន

សំរាប់ខណៈពេលនេះកម្មវិធីទាំងអស់នេះនឹងមិនមានការកែប្រែបន្ថែមនោះទេពីព្រោះថាការអនុវត្តកំពុងមានដំណើរការល្អ ជាពិសេស HEFs។

### ៥.៦. ការពង្រីកបន្ថែមទៀតឆ្ពោះទៅកាន់គម្រោងកិច្ចគាំពារសង្គម

ច្បាប់ការងារ

ច្បាប់ការងារ (ឆ្នាំ ១៩៩៨) ផ្តល់នូវក្របខណ្ឌគតិយុទ្ធសំរាប់ការពារពលករ និងនិយោជិត។ ច្បាប់អនុវត្តចំពោះនិយោជិតដែលទទួលបានប្រាក់ឈ្នួលទាំងអស់ក្នុងវិស័យឯកជន ដោយមានការលើកលែងចំពោះមន្ត្រីរាជការ កងទ័ពនិងទាហានសមាជិកនីតិបញ្ញត្តិ និងពលករក្នុងស្រុក។

| | |
|---|---|
| ច្បាប់សន្តិសុខសង្គម | ច្បាប់លើគម្រោងការណ៍សន្តិសុខសង្គមសំរាប់បុគ្គលដែលបានកំណត់ដោយច្បាប់ការងារ ត្រូវបានអនុម័តក្នុងឆ្នាំ ២០០២ និងកំណត់អំពីការបង្កើតគម្រោងសន្តិសុខសង្គមសំរាប់និយោជិតវិស័យឯកជន។ ផលប្រយោជន៍ដែលត្រូវផ្តល់ក្រោមគម្រោងរួមមានសោធននិវត្ត ផលប្រយោជន៍គ្រោះថ្នាក់ការងារ និងផលប្រយោជន៍ដទៃទៀតដែលពាក់ព័ន្ធ។ បន្ថែមពីលើនេះទៀតមានបទប្បញ្ញត្តិដោយឡែកដែលពាក់ព័ន្ធជាមួយផលប្រយោជន៍សន្តិសុខសង្គមសំរាប់ក្រុមជាក់លាក់៖ មន្ត្រីរាជការ ទាហាន និងនគរបាល និងអតីតយុទ្ធជន។ |
| ប.ស.ស | របបបេឡាជាតិសន្តិសុខសង្គមគ្របដណ្តប់ទៅលើគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ (មានការផ្តល់ជូនចំពោះសេវាថែទាំសុខភាព ចំណាយបុណ្យសព និងសោធននិវត្តន៍រស់រានមានជីវិត)។ រហូតដល់ពេលបច្ចុប្បន្ន មូលនិធិនេះគ្របដណ្តប់ចំពោះពលករក្នុងសហគ្រាសដែលមាននិយោជិតចំនួន ឬច្រើនជាង ៨ នាក់។ ការពង្រីកការគ្របដណ្តប់ដល់ពលករក្នុងសហគ្រាសតូចជាងនេះត្រូវបានពិចារណាក្នុងពេលអនាគត។ NSSF បានគ្របដណ្តប់ពលករចំនួន ៩៨០ ពាន់នាក់ ដែល ៨០ភាគរយនៃពលករទាំងនេះធ្វើការក្នុងវិស័យកាត់ដេរ។ ការពង្រីកបន្ថែមក្នុងក្របខណ្ឌ NSSF ដែលបានគ្រោងក្នុងពេលឆាប់ៗនេះគឺការធានារ៉ាប់រងសុខភាពសង្គម (រួមមានផលប្រយោជន៍ពេលមានជំងឺ និងមាតុភាព) ឆ្ពោះទៅកាន់ចុងឆ្នាំ ២០១២ និងសោធននិវត្តក្នុងឆ្នាំ ២០១៥។ នៅតែទាមទារឱ្យមាននូវការកំណត់លក្ខខណ្ឌ យន្តការរួមចំណែក និងសិទ្ធិក្នុងការទទួលបានផលប្រយោជន៍សំរាប់គម្រោងទាំងនេះ។ |
| ប.ស.ស សំរាប់មន្ត្រីរាជការស៊ីវិល | របបបេឡាជាតិសន្តិសុខសង្គមសំរាប់មន្ត្រីរាជការស៊ីវិល ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៨។ ក្របខណ្ឌគតិយុត្តិគឺច្បាប់ស្តីពីស្ថានភាពគតិយុត្តិរបស់មន្ត្រីរាជការស៊ីវិល (ឆ្នាំ ១៩៩៤) និងបទប្បញ្ញត្តិដទៃមួយចំនួនទៀត ( SPER រៀបរាប់ពិស្តារពីបញ្ហានេះ)។ មន្ត្រីរាជការចំនួន ១៧៥ ពាន់នាក់ត្រូវបានគ្រប់ដណ្តប់បូករួមជាមួយក្រុមគ្រួសាររបស់ពួកគាត់ ដែលជាសរុបគឺមានចំនួន ៦៧៥ ពាន់នាក់។ យថាហេតុដែលត្រូវបានគ្របដណ្តប់ពេលបច្ចុប្បន្នរួមមាន៖ ជំងឺ ផលប្រយោជន៍គ្រោះថ្នាក់ការងារ ផលប្រយោជន៍សំរាកមាតុភាព ផលប្រយោជន៍ចូលនិវត្ត ផលប្រយោជន៍ទុព្វលភាព និងផលប្រយោជន៍ពេលស្លាប់។ មានផែនការពង្រីកយថាហេតុដែលត្រូវគ្របដណ្តប់ក្នុងការធានារ៉ាប់រងសង្គម។ រហូតដល់ពេលបច្ចុប្បន្ននេះ ផលប្រយោជន៍ទាំងនេះត្រូវបានផ្តល់ហិរញ្ញប្បទានដោយប្រាក់ចំណូលរបស់រដ្ឋាភិបាល។ ផែនការគឺថាចង់ប្រែក្លាយប្រព័ន្ធនេះទៅជាប្រព័ន្ធដែលមានការរួមចំណែកមួយ ប៉ុន្តែផែនការនេះមិនទាន់បានអនុវត្តនៅឡើយទេ។ |

| | |
|---|---|
| NVF | គម្រោងការណ៍ធានារ៉ាប់រងសង្គមទី ៣ ដែលមានរួចជាស្រេចគឺបេឡាជាតិសំរាប់អតីតយុទ្ធជន ដែលនេះទើបតែបង្កើតថ្មីៗក្នុងឆ្នាំ ២០១០។ NFV គ្របដណ្តប់យថាហេតុដូចគ្នាទៅនឹងគម្រោង NSSF-C ទោះបីជាមានការផ្តល់ជូនបន្ថែមមួយចំនួនក៏ដោយ ហើយទាក់ទងជាមួយការផ្តល់មូលនិធិ គឺដូចទៅនឹង NSSF-Cដែរ។ |
| របៀបវារៈសម្រាប់អនាគតឆាប់ៗ | ការសន្និដ្ឋានគឺថាមានកិច្ចការជាច្រើនទៀតដើម្បីបំពេញក្នុងការពង្រីកគម្រោងធានារ៉ាប់រងសង្គម ដែលនេះរួមបញ្ចូល (i) ចំនួននៃពលករដែលត្រូវបានគ្របដណ្តប់ដោយគម្រោងដែលមានស្រាប់ (ii) ប្រភេទយថាហេតុដែលបានគ្របដណ្តប់ និង(iii) លក្ខខណ្ឌជាក់លាក់ (សិទ្ធិទទួល កម្រិតការរួមចំនែក និងផលប្រយោជន៍ និងពេលវេលា)។ មិនត្រឹមតែទៅលើការបង្កើតគម្រោងប៉ុណ្ណោះទេ ប៉ុន្តែទៅលើការកិច្ចការរដ្ឋបាលផងដែរ គឺត្រូវធ្វើកិច្ចការជាច្រើន។ ជំពូកទី៦ និងពិភាក្សាពីបញ្ហាទាំងនេះ។ |

## ជំពូកទី៦ ក្របខណ្ឌមុខរបរ និងអភិបាលកិច្ចកិច្ចគាំពារសង្គម

### ៦.១. សេចក្តីផ្តើម

ជាដំបូងជំពូកនេះនឹងពិភាក្សា នៅកម្រិតថ្នាក់ក្រសួង និងនីតិប្រតិបត្តិ អំពីរចនាសម្ព័ន្ធអភិបាលកិច្ចដែលពាក់ព័ន្ធសំរាប់យុទ្ធសាស្រ្តជាតិមុខរបរ និងការងារ/កិច្ចគាំពារសង្គម (NE/SPS)។ បន្ទាប់មកជំពូកនេះនឹងពិភាក្សាពីបញ្ហាក្នុងការផ្តល់សេវា។

### ៦.២. សហប្រតិបត្តិការនៅកម្រិតក្រសួង

រចនាសម្ព័ន្ធសម្រប សម្រួល ត្រូវការការកែ សម្រួល

CARD មានអាណត្តិក្នុងការសម្របសម្រួលការអនុវត្ត NSPS ។ ក្រសួងខ្សែបណ្តោយមួយចំនួនមានទំនួលខុសត្រូវក្នុងការគ្រប់គ្រងកម្មវិធីកិច្ចគាំពារសង្គមផ្សេងៗគ្នា។ MOLVT ទទួលខុសត្រូវចំពោះការធានារ៉ាប់រងសង្គមក្រោមច្បាប់ការងារ និងចំពោះ NEA ។ នៅក្នុងវិស័យនៃកម្មវិធីវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ មានការបង្កើតរចនាសម្ព័ន្ធសម្របសម្រួលដោយឡែកមួយក្រោម ក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល (NTB) ។ ពេលដែលក្របខណ្ឌយុទ្ធសាស្រ្តត្រូវបានពង្រីកដើម្បីរួមបញ្ចូល យុទ្ធសាស្រ្តជាតិមុខរបរ និងការងារ គឺទាមទារឱ្យមានការកែប្រែរចនាសម្ព័ន្ធសម្របសម្រួលនេះ។

SNEC/CARD/MOP/ NTB/ NCDD អាចជាកម្មវិធីនយោបាយសមស្រប សម្រាប់សម្របសម្រួល ក្របខណ្ឌរួមបញ្ចូល ដោយចងភ្ជាប់ទៅនឹង របៀបវារៈ NSDP

ជាការសមហេតុផលមួយដែលថាការសម្របសម្រួលនៃការរួមបញ្ចូលយុទ្ធសាស្រ្តជាតិមុខរបរ និងការងារ/កិច្ចគាំពារសង្គម ដែលមានផ្សាភ្ជាប់ជាមួយរបៀបវារៈ NSDP នឹងស្ថិតក្រោមក្រុមការងារមួយ ដែលក្រៅពី CARD គឺមានអ្នកតំណាងមកពីឧត្តមក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច (SNEC) ក្រសួងផែនការ (MOP) NTP និងក្រុមប្រឹក្សាជាតិដើម្បី NCDD ។ នេះអាចធានាថារាល់ទំនាក់ទំនងទាំងអស់ជាមួយកម្មវិធីដែលពាក់ព័ន្ធពីទស្សនៈវិស័យនៃ យុទ្ធសាស្រ្តជាតិមុខរបរ និងការងារ/កិច្ចគាំពារសង្គម អាចសម្រេចបាននៅផែនការកម្រិតខ្ពស់នេះ។

### ៦.៣. ការបង្កើតស្ថាប័នសន្តិសុខសង្គម (SSO)

ការបង្កើត "ឆ័ត្រ SSO"

ជាការសមហេតុផលមួយក្នុងការបង្កើតស្ថាប័នរួមមួយសំរាប់គ្រប់គ្រង បញ្ញត្តិ និងត្រួតពិនិត្យរដ្ឋបាលនៃសន្តិសុខសង្គម។ ស្ថាប័ននេះនឹងមានឈ្មោះថា៖ ស្ថាប័នសន្តិសុខសង្គម (SSO) ។ ជាការពិតណាស់ដែលទើបតែមានការបង្កើតថ្មីៗនូវរចនាសម្ព័ន្ធអភិបាលកិច្ចក្នុង NSSF NSSF-C និងNVF ។ មូលនិធិទាំងបីនេះមានក្រុមប្រឹក្សាភិបាលមកពីក្រសួងផ្សេងៗ និងក្នុងករណី NSSF មានអ្នកតំណាងមកពីសហជីព និងសមាគមនិយោជក។ ការបង្កើតស្ថាប័នរួមថ្មីមួយមិនស្ថិតក្នុងអាទិភាពភ្លាមៗនោះទេ ទោះបីជាយ៉ាងណាក៏ដោយមានហេតុផលសមរម្យមួយក្នុងការដោះស្រាយបញ្ហានេះ

ភ្លាមៗ។ SSP អាចជាស្ថាប័នប្រតិបត្តិនៃផែនការសម្របសម្រួលនយោបាយដែលបានស្នើរនៅក្នុងផ្នែកមុន។ ស្ថាប័ននេះមិនត្រឹមតែត្រួតពិនិត្យមូលនិធិធានារ៉ាប់រងទាំងបីនេះទេ ប៉ុន្តែជាប្រតិបត្តិការនៃការិយាល័យច្រកចេញចូលតែមួយផងដែរពេលដែលស្ថាប័ននេះទទួលខុសត្រូវក្នុងការផ្តល់កម្មវិធីកិច្ចគាំពារសង្គមយ៉ាងទូលំទូលាយ និង ALMPs (ផ្នែកទី ៦ ៤)។ សំរាប់គោលបំណងនេះ វាទាមទារឱ្យមានការផ្លាស់ប្តូរព័ត៌មានយ៉ាងជិតស្និតជាមួយ NEA ។ យើងអាចនិយាយបានម្យ៉ាងទៀតថា ការបង្កើត SSO ដ៏ជំនាញមួយមានសារៈសំខាន់ណាស់ក្នុងការបង្កើតរចនាសម្ព័ន្ធអនុវត្តដែលក្នុងនេះភ្នាក់ងារទាំងអស់នឹងធ្វើការសហការគ្នាទៅវិញទៅមក។

ខាងក្រោមជាតារាងនៃបញ្ហាដែលនឹងទាមទារឱ្យមានការដោះស្រាយនៅក្នុងដំណើរការនេះ។ បញ្ហាទាំងនេះទាញចេញពីការអនុវត្តល្អប្រសើរអន្តរជាតិ។

SSO ជាអង្គការស្វ័យត

បញ្ហាទីមួយក្នុងការដោះស្រាយក្រោមប្រធានបទនេះ គឺធ្វើឱ្យ SSO ទៅជាស្ថាប័នឯករាជ្យមួយ។ នេះជាការសំខាន់ដែលទាមទារឱ្យ SSO មិនពាក់ព័ន្ធនឹង ល្បែងនយោបាយ។ ការអនុវត្តទូទៅជាអន្តរជាតិ គឺជាវត្តមាននៃស្ថាប័នប្រតិបត្តិឯករាជ្យមួយសំរាប់គ្រប់គ្រងបេឡាសន្តិសុខសង្គម (ក្នុងករណីប្រទេសកម្ពុជាទាំងនេះរួមមានៈ NSSF NSSF-C និង NVF )។ ស្ថាប័នប្រតិបត្តិទាំងនេះនឹងចរចារថវិការប្រចាំឆ្នាំរបស់ខ្លួនជាមួយក្រសួងទទួលបន្ទុកចំពោះមូលនិធិទាំងនេះ។ រដ្ឋមន្ត្រីអាចកំណត់គោលការណ៍ណែនាំ និងគោលនយោបាយទូលំទូលាយជាងនេះ។ កិច្ចការរបស់ SSO គឺត្រូវរៀបចំគោលការណ៍ណែនាំទាំងនេះ។ ការអនុវត្តនៃគោលការណ៍ណែនាំជាមួយនឹងក្របខណ្ឌ និងថវិកាដែលបានកំណត់ នឹងជាទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលនៃរដ្ឋបាលមូលនិធិទាំងបី។ រូបភាពទី ៧.១. បង្ហាញពីគ្រោងនៃក្របខណ្ឌអភិបាលកិច្ច។

រូបភាពទី ៧.១.៖ ស្ថានភាពស្ថាប័ននៃ SSO (ស៊ុមអភិបាលកិច្ច)




**ជំហានបន្ទាប់អាចជាក្រុមប្រឹក្សាឯករាជ្យនៃនាយកគ្រប់គ្រងសម្រាប់មូលនិធិ SI**

ជាជំហានបន្ទាប់ក្នុងការមានក្រុមប្រឹក្សាភិបាលជំនាញដែលឯករាជ្យមួយសំរាប់មូលនិធិធានារ៉ាប់រងសង្គមទាំងបី។ បន្ថែមលើក្រុមប្រឹក្សាភិបាលនេះ អាចមាននូវក្រុមប្រឹក្សាត្រួតពិនិត្យដែលមានការចូលរួមពីក្រសួងពាក់ព័ន្ធ (ដោយមានតួនាទីក្នុងនាមជានិយោជកតែប៉ុណ្ណោះ) និងដៃគូសង្គម។ នេះអាចធានាថា នាយកប្រតិបត្តិដែលទទួលខុសត្រូវសំរាប់ប្រតិបត្តិការប្រចាំថ្ងៃនឹងត្រូវបានណែនាំតម្រង់ទិស និងធ្វើការផ្លាស់ប្តូរព័ត៌មានជាមួយស្ថាប័នគ្រប់គ្រងដោយមិនប៉ះពាល់ជាមួយទំនួលខុសត្រូវប្រតិបត្តិរបស់ខ្លួន។ គួរតែមានការកំណត់ដែនកំណត់ច្បាស់លាស់នៃទំនួលខុសត្រូវ និងកម្រិតដែលនាយកប្រតិបត្តិនឹងទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាត្រួតពិនិត្យ។ ជារឿងសមហេតុផលមួយដែលថា នាយកប្រតិបត្តិនឹងត្រូវការសេចក្តីអនុញ្ញាតពីក្រុមប្រឹក្សាត្រួតពិនិត្យជាមុនសិនសំរាប់សេចក្តីព្រាងថវិកា មុខពេលដែលខ្លួនធ្វើការចរចាបញ្ហានេះជាមួយរដ្ឋមន្ត្រី។

**ផ្តល់អំណាចដល់ SSO ស្របតាមតួនាទីសម្របសម្រួលរបស់អង្គការនេះ**

ចំនុចសំខាន់មួយទៀតដែលយើងត្រូវពិភាក្សានៅទីនេះគឺអាណត្តិរបស់ SSO ចំពោះក្រសួងដែលពេលបច្ចុប្បន្ននេះកំពុងទទួលខុសត្រូវចំពោះកម្មវិធីកិច្ចគាំពារសង្គមមួយចំនួនធំ។ កំណែទម្រង់អ័ក្សដេកទាមទារការសហការ យ៉ាងខ្លាំងពី SSO ហើយនេះអាចប៉ះទង្គិចជាមួយទស្សនៈនៃទំនួលខុសត្រូវក្នុងចំណោមក្រសួងទាំងនេះ។ ការពង្រីកអ័ក្សឈរនៃគម្រោងធានារ៉ាប់រងសង្គមដែលមានស្រាប់ក៏ទាមទារការសហការ ហើយនៅទីនេះ SSO និងមូលនិធិទាំងបីនឹងប្រឈមមុខភាពតានតឹងស្រដៀងគ្នា។

ចំពោះ SSO ក្នុងការអនុវត្តតួនាទីសម្របសម្រួលរបស់ខ្លួនអោយមានប្រសិទ្ធិភាព វាទាមទារអោយមានការគាំទ្រពីផែនការសហការនយោបាយ (SNEC/CARD/MOP/NTB/NCDD)។

ភារកិច្ចរបស់ SSO

SSO នឹងទទួលខុសត្រូវចំពោះកិច្ចការមួយចំនួន។ នេះមិនមែនមានន័យថា SSO ត្រូវបំពេញកិច្ចការទាំងអស់ដោយខ្លួនឯងនោះទេ ដោយកិច្ចការមួយចំនួនអាចត្រូវបានចាត់តាំងទៅអោយភ្នាក់ងារដទៃ ដែលនេះគួរតែមានការបែងចែកអោយដាច់រវាងកិច្ចការយុទ្ធសាស្ត្រ និងការងារប្រតិបត្តិការ។

ភារកិច្ចយុទ្ធសាស្ត្រ

កិច្ចការយុទ្ធសាស្ត្ររួមមាន៖

- ការបង្កើតមាគ៌ាគោលនយោបាយដោយមានការពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយរដ្ឋាភិបាល និងដៃគូសង្គម
- ការសម្របសម្រួលកម្មវិធី និងគម្រោងផ្សេងគ្នាដើម្បីធានាភាពស៊ីសង្វាក់គ្នា
- ការសម្របសម្រួលប្រព័ន្ធសេវាច្រកចេញចូលតែមួយ
- ការគ្រប់គ្រងនូវមូលនិធិទាំងបី និងការគ្រប់គ្រងគម្រោងធានារ៉ាប់រងសង្គម

ទាមទារអោយមានការប្រែសម្រួលពីកម្រិតយុទ្ធសាស្ត្រ ទៅជាកម្រិតប្រតិបត្តិការ ដែលនេះរួមមាន៖

- ការបង្កើតគំរូរបាយការណ៍គ្រប់គ្រងដូចគ្នាមួយសំរាប់មូលនិធិ និងការិយាល័យច្រកចេញចូលតែមួយ
- កំណត់ទិសដៅសំរាប់ការអនុវត្តមូលនិធិ និងគម្រោងផ្សេងៗ
- កំណត់ឧបករណ៍តាមដាននិងវាយតម្លៃ
- បង្កើត និងរក្សាទិន្នន័យកណ្តាល និងបញ្ចូលទិន្នន័យទៅក្នុងរបាយការណ៍តាមពេលវេលា
- ការបង្កើតគោលការណ៍ណែនាំវិនិយោគសំរាប់មូលនិធិ
- ការបង្កើតវិធីសាស្ត្រធ្វើសេចក្តីរាយការណ៍
- ស្រាវជ្រាវ និងអភិវឌ្ឍន៍យុទ្ធសាស្ត្រ

ភារកិច្ចប្រតិបត្តិ

កិច្ចការប្រតិបត្តិការ ដែលជាការគ្រប់គ្រងមូលនិធិ និងគម្រោង រួមមាន៖

- ការបង្កើត និងគ្រប់គ្រងគម្រោង
- ប្រមូលបដិភាគ
- តាមដានការអនុលោម

- វាយតម្លៃករណី
- ចាត់ចែងផ្តល់ផលប្រយោជន៍
- ធ្វើគម្រោងថវិកា(ជាឧទាហរណ៍ ទាក់ទងនឹងការចំណាយប្រតិបត្តិការ)
- គ្រប់គ្រងបណ្តឹង

ដើម្បីអនុវត្ត កិច្ចការប្រតិបត្តិការទាំងនេះទាមទារអោយមានការកំណត់ទិសដៅ និងទាមទារអោយមានការកំណត់និងតាមដានសូចនាករ។ ឧទាហរណ៍នៃសូចនាករអាចជា៖ ពេលវេលាដំណើរការវាយតម្លៃបណ្តឹងទាមទារផលប្រយោជន៍ ចំនួនបដិភាគដែលទាន់បង់ ចំនួនបណ្តឹងទាមទារដែលបានទទួល ។ល។ វាជាកិច្ចការរបស់អ្នកគ្រប់គ្រងមូលនិធិក្នុងការបង្កើតកម្រងសូចនាករដ៏មានប្រសិទ្ធិភាពមួយ និងក្នុងការតាមដានការអនុវត្ត។ វាជាកិច្ចការរបស់ស្ថាប័ន ឬផ្នែកត្រួតពិនិត្យក្នុងការធានាថាការងារនេះត្រូវបានបំពេញយោងទៅតាមស្តង់ដារដែលបានព្រមព្រៀង។

ច្បាប់ SSO

កិច្ចការ និងទំនួលខុសត្រូវរបស់ SSO និងស្ថាប័នដទៃទៀតក្នុងវិស័យកិច្ចគាំពារសង្គម រួមមានសេវាកម្មច្រកចេញចូលតែមួយ អាចត្រូវបានបញ្ចូលជាផ្លូវការក្នុង ច្បាប់ស្ថាប័នកិច្ចគាំពារសង្គម។

### ៦.៤. ការផ្តល់សេវា

មួយក្នុងចំណោមបញ្ហាប្រឈមពិបាកបំផុតក្នុងការបង្កើតកម្មវិធីកិច្ចគាំពារសង្គម គឺថាតើត្រូវផ្តល់ផលប្រយោជន៍ និងសេវាសង្គមយ៉ាងដូចម្តេចទៅដល់ប្រជាជនដែលត្រូវការផលប្រយោជន៍ និងសេវាសង្គមទាំងនោះ។ កម្ពុជាបានចាប់ផ្តើមនូវគម្រោងចំនួនពីរដែលមានភាពស្ថិតស្ថេរក្នុងបរិបទនេះ។ ជាដំបូងគឺគម្រោងអត្តសញ្ញាណជនក្រីក្រ (ID Poor) និងទីពីរគឺសេវាប្រជាជន (PEOPLE Service)។

អត្តសញ្ញាណជនក្រីក្រ

ID Poor បានបង្កើតឡើងក្នុងឆ្នាំ ២០០៥ ហើយគោលបំណងរបស់វារួមមានការកំណត់អត្តសញ្ញាណជនក្រីក្រនៅក្នុងប្រទេសកម្ពុជា និងកំណត់ពីតម្រូវការរបស់ពួកគេ។ រហូតមកដល់ពេលបច្ចុប្បន្នគ្រួសារកម្ពុជាចំនួនជាង 50% ត្រូវបានសម្ភាសន៍។ សង្ឃឹមថាទិន្នន័យ ID-Poor នឹងរួមបញ្ចូលជនក្រីក្រកម្ពុជាទាំងអស់ ត្រឹមចុងឆ្នាំ ២០១២។ កម្មវិធីមានគម្រោងធ្វើការវាយតម្លៃឡើងវិញពេញលេញមួយចំពោះ គ្រួសារទាំងអស់រៀងរាល់ពីរឆ្នាំដើម្បីធានាកម្រងទិន្នន័យបច្ចុប្បន្នភាពមួយលើស្ថានភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចរបស់អ្នកក្រីក្រ។ ID-Poor ជាយន្តការមានសារៈសំខាន់មួយសំរាប់តាមដានគ្រួសារក្រីក្រ។ កង្វះនូវយន្តការសមរម្យក្នុងការដោះស្រាយភាពក្រីក្រ ជារឿយៗជាឧបសគ្គមួយដ៏ចំបងក្នុងការបង្កើតនូវផលប្រយោជន៍ដែលកំណត់ទិសដៅចំពោះជនក្រីក្រ។

**វិមជ្ឈការ និងវិសហមជ្ឈការ ពាក់ព័ន្ធនឹងសេវាកម្មសង្គម**

ទាក់ទងជាមួយនឹងកំណែទម្រង់ D&D ដែលកំពុងស្ថិតក្នុងដំណើរការ វិមជ្ឈការដែលបានគ្រោងទុកនៃការផ្តល់សេវាសាធារណៈ អាចបង្កប់ន័យនូវការផ្តល់ផលប្រយោជន៍កិច្ចគាំពារសង្គម និងសេវាការងារនាពេលអនាគតនៅកម្រិតមូលដ្ឋាន។ ទោះបីជាយ៉ាងណាក៏ដោយមិនទាន់មានភាពច្បាស់លាស់នៅឡើយទេថាតើកំណែទម្រង់នឹងមានរូបភាពយ៉ាងណាក្នុងការផ្តល់សេវាសាធារណៈ ជាពិសេសសំរាប់កម្មវិធីដែលគ្រប់គ្រងដោយក្រសួងខ្សែបណ្តោយ។ ទោះបីជាយ៉ាងនេះក៏ដោយ ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកម្ពុជាក្នុងការធ្វើវិមជ្ឈការការផ្តល់សេវាធារណៈ និងការផ្តលអំណាចដល់រដ្ឋបាលថ្នាក់ក្រោម នឹង ដោយមិនមានភាពសង្ស័យ បើកចំហទស្សនៈថ្មីមួយ និងពង្រីកជម្រើសអនុវត្តដ៏ទូលំទូលាយក្នុងពេលអនាគត។

**រូបភាពទី ៧.២. សេវាកម្ម PEOPLE**




**សេវាកម្ម PEOPLE**

សេវាច្រកចេញចូលតែមួយ (SWS) ដែលមានឈ្មោះថាសេវាប្រជាជន គឺជាច្រកចេញចូលតែមួយសំរាប់កម្មវិធីកិច្ចគាំពារសង្គម និងសេវាការងារនៅកម្រិតមូលដ្ឋាន

- គ្រួសារចុះឈ្មោះក្នុងកន្លែងតែមួយនៅកម្រិតថ្នាក់ក្រោមជាតិ
- ពលករសង្គមគិតគូរពីបញ្ហាគាត់ និងវាយតម្លៃតម្រូវការរបស់គាត់
- កញ្ចប់រួមមួយនៃកម្មវិធី (កិច្ចគាំពារសង្គម និងការងារ) ត្រូវបាស្នើរសំរាប់គ្រួសារទាំងនេះ ដែលត្រូវបានផ្តល់ជូនដោយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលដើម្បីឆ្លើយតបនឹងតម្រូវការរបស់ពួកគេ។

- អ្នកផ្តល់សេវាសាធារណៈ និងឯកជនផ្សេងៗ (HEF, PWP, TVET, អាហារូបករណ៍) រៀបចំការចុះឈ្មោះ វាយតម្លៃភាពងាយរងគ្រោះ វាយតម្លៃជំនាញ IEC និងបែងចែកមូលនិធិដល់សេវាប្រជាជន

| | |
|---|---|
| នឹងសាកល្បងនៅរដូវក្តៅខាងមុខនេះ | គម្រោងសាកល្បងសេវាកម្មច្រកចេញចូលតែមួយកំពុងត្រូវបានរៀបចំដោយ ILO មានគោលបំណងសាកល្បងយន្តការផ្តល់សេវាសង្គមរួមមួយក្រោមរដ្ឋបាលមូលដ្ឋានថ្មី។ |
| នេះចងភ្ជាប់ចំណងជាមួយនឹងទិន្នន័យដែលដូចគ្នា | គម្រោងសេវាកម្មច្រកចេញចូលតែមួយ (SWS) សម្របសម្រួលលំហូរនៃព័ត៌មានរវាងសេវា កិច្ចគាំពារសង្គម/មុខរបរ រដ្ឋបាលមូលដ្ឋាន ក្រសួងនិងនាយកដ្ឋានខ្សែបណ្តោយ និងផែនការសហការនៅកម្រិតក្រសួង។ |

- វាធានាថាអ្នកទទួលផលប្រយោជន៍មានលទ្ធភាពដ៏មានប្រសិទ្ធិភាពក្នុងការទទួលបានសេវា
- វាផ្ទេរទិន្នន័យទៅដល់ប្រព័ន្ធទិន្នន័យរួមមួយនៅកម្រិតជាតិ (ក្រសួងខ្សែបណ្តោយ និង SNEC/CARD/MOP/NCDD) សូមមើលបន្ថែមខាងក្រោម
- វាជាការឧបករណ៍សហការសំរាប់ការអនុវត្ត យុទ្ធសាស្រ្តជាតិមុខរបរនិងការងារ/កិច្ចគាំពារសង្គម
- សេវាច្រកចេញចូលតែមួយ (SWS) ជាទិន្នន័យនៃអ្នកទទួលផលប្រយោជន៍
- វាជម្រុញការចុះព័ត៌មានរបស់អ្នកទទួលផលប្រយោជន៍
- វាត្រូវបានធ្វើបច្ចុប្បន្នភាពយ៉ាងទៀតទាត់
- វាជាឧបករណ៍សំរាប់តាមដាន និងត្រួតពិនិត្យកម្មវិធី និងផលប៉ះពាល់ដល់អ្នកទទួលផលប្រយោជន៍

**រូបភាពទី ៧.៣. ទិន្នន័យរួម**




មុខងាររបស់សេវាកម្ម PEOPLE

សេវាប្រជាជន (PEOPLE Service)មានតួនាទីដូចខាងក្រោមៈ

បង្កើនការគ្រប់ដណ្តប់

- លទ្ធភាពក្នុងការទទួលបានកិច្ចគាំពារសង្គម និងការងារពាក់ព័ន្ធនឹងសេវាកម្មនឹងត្រូវបានសម្របសម្រួលតាមរយៈច្រកចូលតែមួយ ហើយប្រជាជននឹងស្វែងរកព័ត៌មានពីកម្មវិធីនៅទីនោះ ហើយការចុះឈ្មោះនឹងនៅកន្លែងតែមួយ។

បង្កើតទំនាក់ទំនង

- រវាងអន្តរាគមន៍កិច្ចគាំពារសង្គម ជាឧទាហរណ៍សុខភាពទារក និងមាតា និងជីវជាតិ រួមបញ្ចូលនឹងលទ្ធភាពក្នុងការទទួលបានការអប់រំ
- រវាងកិច្ចគាំពារសង្គម និងកម្មវិធីការងារ ជាឧទាហរណ៍លទ្ធភាពក្នុងការទទួលបានសេវាថែទាំសុខភាពសំរាប់អ្នកដែលចុះឈ្មោះក្រោម PWPs, TVET មីក្រូឥណទាន
  នេះគឺដើម្បីកាត់បន្ថយផលប៉ះពាល់ និងធានាការចាកផុតពីភាពក្រីក្រ និងកាត់បន្ថយចំណាយ និងសម្រេចបានស្ថេរភាពហិរញ្ញវត្ថុ។

ផ្តល់អំណាចដល់កម្រិតថ្នាក់ក្រោមជាតិ

- សេវាប្រជាជន (PEOPLE Service) នឹងត្រូវបានបង្កើតជាមួយរចនាសម្ព័ន្ធរដ្ឋាភិបាល

- ស្ថាប័នថ្នាក់ក្រោមជាតិតាមខេត្ត និងស្រុកនឹងរួមបញ្ចូលក្នុងការបង្កើត និងត្រួតពិនិត្យសេវាប្រជាជន (អភិបានរងខេត្ត OSWO នៅកម្រិតស្រុក CCWC នៅកម្រិតឃុំ)
- ស្ថេរភាពហិរញ្ញវត្ថុ

សម្របសម្រួលការសហការ និងសុខដុមនីយកម្ម

- ប្រើប្រាស់ ប្រព័ន្ធអត្តសញ្ញាណជនក្រីក្រ(ID poor) និងធ្វើបច្ចុប្បន្នកម្មទិន្នន័យ ID Poor
- ប្រមូលទិន្នន័យអំពីអ្នកទទួលផលប្រយោជន៍ ការផ្តល់កិច្ចគាំពារសង្គម និងសេវាការងារព្រមទាំងការប្រើប្រាស់នូវសេវាកម្មទាំងនេះ
- ផ្ទេរទិន្នន័យទៅក្នុងប្រព័ន្ធទិន្នន័យរួមមួយនៅកម្រិតកណ្តាល ដែលជាៈ ក្រសួងខ្សែបណ្តោយ និងផែនការសម្របសម្រួលគោលនយោបាយ (SNEC/CARD/MOP/NCDD)

នៅតែមានបញ្ហាក្នុងការអភិវឌ្ឍន៍មួយចំនួនពាក់ព័ន្ធទៅនឹងសេវាប្រជាជន។ បញ្ហាទាក់ទងជាមួយផលិតផល និងសេវាដែលបានផ្តល់ ការបង្កើតស្ថាប័ន និងបញ្ហាប្រតិបត្តិការ និងហិរញ្ញវត្ថុ។ ទាំងនេះនឹងត្រូវបានបញ្ជាក់ក្នុងជំពូកទី ៧។

**ជំពូកទី ៧ ការអនុវត្តយុទ្ធសាស្ត្រ NSPS និង NES**

ជំពូកនេះនឹងផ្តល់អនុសាសន៍ និងខ្សែបន្ទាត់ពេលវេលាបន្ថែម ដោយបរិយាយល្អិតល្អន់។